ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការសិក្សាពីមុខសញ្ញាចំណាយការសិក្សារបស់សិស្ស កម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ

# THE STUDY ON STUDENTS' EXPENDITURES AT LOWER SECONDARY SCHOOL IN KAMPONG SPEU PROVINCE


វ៉ាន់ សំរេច

VANN SAMRACH


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

# ការសិក្សាពីមុខសញ្ញាចំណាយការសិក្សារបស់សិស្ស កម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ

# THE STUDY ON STUDENTS' EXPENDITURES AT LOWER SECONDARY SCHOOL IN KAMPONG SPEU PROVINCE


**វ៉ាន់ សំរេច**

VANN SAMRACH


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល**

**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០២០-២០២២**


**គ្រូណែនាំគោល ៖ បណ្ឌិត ឡាយ សុវិជ្ជា**

**គ្រូណែនាំរង ៖ បណ្ឌិត ឈិញ ស៊ីថា**

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា “**ការសិក្សាពីមុខសញ្ញាចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ**” សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ឬខ្លឹមសារណាមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃសុក្រ ១១កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២

**ហត្ថលេខា**

**ទ៉ាន់ សំរេច**

# លិខិតបញ្ជាក់

| | |
|---|---|
| **បណ្ឌិត ឡាយ សុវិជ្ជា** | ជាគ្រូណែនាំគោល |
| **បណ្ឌិត ឈិញ ស៊ីថា** | ជាគ្រូណែនាំរង |

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **វ៉ាន់ សំរេច** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ការសិក្សាពីមុខសញ្ញាចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ**" ប្រាកដមែន។

ថ្ងៃអាទិត្យ ១៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២២

| | |
|---|---|
| ...................................... | ...................................... |
| **បណ្ឌិត ឡាយ សុវិជ្ជា** | **បណ្ឌិត ឈិញ ស៊ីថា** |
| ប្រធានការិយាល័យស្រាវជ្រាវ | អ្នកស្រាវជ្រាវជាន់ខ្ពស់ RUPP |
| និងវិភាគគោលនយោបាយ | |

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៣៧០២៥ អយក.ខទន

(ការសម្ងាត់)

## លិខិតឧទ្ទេសនាម

យោងៈ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំង ជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ ទី៩ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំៈ

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ឧទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ | ណាត ប៊ុនរឿន | ឧទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម | យក់ ង៉ុយ | ឧទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម | លាង សេងហាក់ | ឧទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម | ម៉ក់ ង៉យ | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | សមាជិក |
| ៧-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-ឯកឧត្តមបណ្ឌិត | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ១០-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទធាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ហេង គ្រេង | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | សមាជិក |
| ១៥-លោកស្រីបណ្ឌិត | បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១៦-លោកបណ្ឌិត | អ៊ែ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ១៧-លោកបណ្ឌិត | មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈិញ ស៊ីថា | អ្នកឯកទេសអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | នី វដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

កន្លែងទទួល៖

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វជអ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ..៣៧៦២៦..អយក.ទខន

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោកបណ្ឌិត | ឡាយ សុវិជ្ជា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ៥-លោកបណ្ឌិត | សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកបណ្ឌិត | ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៨-លោកបណ្ឌិត | ឈិញ នីដា | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៩-លោកបណ្ឌិត | អ៊ុំ ចាន់ចំណាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | កាង ស៊ុងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | មឿន លិនណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | គួយ សូគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោកស្រីបណ្ឌិត | ឡឹយ សុគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោក | ប៉ូ ប៊ុន្នួន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | សឿ សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០.លោក | ថាច់ សន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១.លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២.លោកស្រី | សេង សច្ចា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣.លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤.លោកស្រី | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥.លោកស្រី | ឯម សុភាលក្ស្មី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែកត្ដិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

កន្លែងទទួល៖

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្ដីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វជអ

# សេចក្តីថ្លែងអំណរគុណ

ជាកិច្ចចាប់ផ្តើម ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកអ្នកមានគុណទាំងពីររួមមានលោកឪពុក សឿង វ៉ាន់ អ្នកម្តាយ ប៊ុន សុគន្ធា ដែលបានបំពេញតួនាទីប្រកបដោយព្រហ្មវិហារធម៌ ដោយការផ្តល់កំណើត ចិញ្ចឹមបីបម គ្រប់គ្រង ថែរក្សា បារម្ភពីអនាគត ផ្តល់ការអប់រំ ដំបូន្មាន និងគាំទ្រពេញទំហឹងចំពោះការសិក្សារបស់កូនរហូតមកដល់ពេលនេះនិងថ្ងៃខាងមុខ។ ទន្ទឹមនឹងនេះ សូមថ្លែងអំណរគុណពន់ពេកដល់ បងប្រុស វ៉ាន់ វាសនា បងស្រីវ៉ាន់ សុជាតា ប្អូនស្រី វ៉ាន់ វត្តី និងអ៊ំ ពូ មីង និងសាច់ញាតិដែលជាសមាជិកគ្រួសារ ជាបងប្អូន ជាអ្នកគាំទ្រ ជាអ្នកលើកទឹកចិត្ត និងនៅពីក្រោយភាពជោគជ័យពិសេសការសិក្សារបស់ខ្ញុំកន្លងមកនេះ។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ **លោកបណ្ឌិត ឡាយ សុទិដ្ឋា** ជាគ្រូណែនាំគោល ដែលបានបង្ហាញផ្លូវលើដំណើរការសរសេរនិក្ខេបបទនេះ ទាំងការពន្យល់ ការណែនាំ ផ្តល់គន្លឹះ ផែនទីគំនិត ចែករំលែកបទពិសោធន៍ និងដោះស្រាយបញ្ហាគ្រប់ពេលវេលាដោយការឆ្លើយតបយ៉ាងរហ័សបំផុត។ រួមជាមួយគ្នានេះ ខ្ញុំបាទក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោកបណ្ឌិត ឈិញ ស៊ីថា** ជាគ្រូណែនាំរងដែលបានផ្តល់បទពិសោធន៍ ប្រភពឯកសារស្រាវជ្រាវ ការណែនាំ និងគាំទ្រជ្រោមជ្រែងតាំងពីការចាប់ផ្តើមរហូតចុងបញ្ចប់។ លោកទាំងពីរ ជាពន្លឺបំភ្លឺគំនិតខ្ញុំបាទដែលអាចសម្រេចបាននូវកិច្ចការស្រាវជ្រាវមួយនេះ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណារ៉ា** នាយកវិទ្យាស្ថានជាតិអប់រំ លោក លោកស្រីសាស្ត្រាចារ្យទាំងអស់ ដែលបានខិតខំប្រឹងប្រែងបង្ហាត់បង្រៀន និងចំណាយពេលវេលាដ៏មានតម្លៃ ផ្តល់ចំណេះដឹង បទពិសោធន៍ កម្លាំងកាយចិត្តដល់និស្សិតគ្រប់រូប។

ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះគណៈគ្រប់គ្រងសាលារៀន លោកគ្រូអ្នកគ្រូ សិស្សានុសិស្សតាមសាលាគោលដៅទាំងអស់ និងមាតាបិតាអាណាព្យាបាលដែលបានចូលរួមសហការ ផ្តល់ព័ត៌មានសម្រាប់រូបខ្ញុំបាទយកមកធ្វើជាអំណះអំណាងលើស្នាដៃស្រាវជ្រាវ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណ ចំពោះ**ឯកឧត្តមបណ្ឌិតសភាចារ្យហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាដែលបានផ្តល់អាហារូបករណ៍ ទើបធ្វើឱ្យខ្ញុំបាទទទួលបានឱកាសសិក្សាបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំជំនាន់ទី៩ រហូតទទួលបានជោគជ័យលើការសិក្សានេះ។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធិពរជ័យជូនចំពោះលោកអ្នកមានគុណ ឯកឧត្តម លោក លោកស្រី សាស្ត្រាចារ្យ លោក លោកស្រី នាងកញ្ញា និងបងប្អូនមិត្តរួមជំនាន់ទាំងអស់ ទទួលបានពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**មាតិកា** **ទំព័រ**


**សេចក្តីអះអាងរបស់បេក្ខជន** ... i

**លិខិតបញ្ជាក់** ... ii

**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការពារនិក្ខេបបទ** ... iii

**សេចក្តីថ្លែងអំណរគុណ** ... vii

**បញ្ជីតារាង** ... xiv

**បញ្ជីអក្សរកាត់** ... xvi

**មូលន័យសង្ខេប** ... xvii

**ជំពូកទី១៖ សេចក្តីផ្តើម** ... 1

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ... 1

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ... 3

១.៣ គោលបំណងនៃការស្រាវជ្រាវ ... 4

១.៤ សំណួរស្រាវជ្រាវ ... 5

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ... 5

១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ... 6

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ... 6

**ជំពូកទី២៖ រំឭកទ្រឹស្តី** ... 8

២.១ បញ្ញត្តិ និងទ្រឹស្តីពាក់ព័ន្ធនឹងមុខសញ្ញាចំណាយការសិក្សា ... 8

២.១.១- និយមន័យពាក្យគន្លឹះ ... 8

២.១.១.ក- មុខសញ្ញាចំណាយ ... 8

២.១.១.ខ- មធ្យមសិក្សាបឋមភូមិ ... 8

២.១.២- ទ្រឹស្តីពាក់ព័ន្ធនឹងមុខសញ្ញាចំណាយការសិក្សា ... 9

២.២- សមាសភាពនៃចំណាយលើការសិក្សា ........ 13

២.៣ បញ្ហាប្រឈមនៃចំណាយការសិក្សា ........ 15

២.៣.១ បញ្ហាប្រឈមនៃចំណាយការសិក្សាក្នុងក្របខណ្ឌជាតិ ........ 15

២.៣.២ បញ្ហាប្រឈមនៃការចំណាយការសិក្សាក្នុងគ្រួសារ ........ 17

២.៤ កម្រិតនៃការចូលរួមលើចំណាយការសិក្សារបស់សិស្ស ........ 18

២.៤.១- ការចូលរួមពីរដ្ឋាភិបាល ........ 19

២.៤.២- ការចូលរួមពីអ្នកនយោបាយ ........ 20

២.៤.៣- ការចូលរួមពីអង្គការក្រៅរដ្ឋាភិបាល និងភ្នាក់ងារជំនួយខាងក្រៅ ........ 21

២.៤.៤- ការចូលរួមពីគ្រួសារ និងសហគមន៍ ........ 22

២.៤.៥- ការចូលរួមពីសាលារៀន ........ 24

២.៥ សារៈសំខាន់នៃការចូលរួមសម្របសម្រួលលើបន្ទុកចំណាយរបស់សិស្ស ........ 25

២.៦ ការចូលរួមស្ម័គ្រចិត្តរបស់មាតាបិតាលើចំណាយការសិក្សារបស់សិស្ស ........ 26

២.៧ ការជំរុញការចូលរួមអាណាព្យាបាល/សហគមន៍លើចំណាយការសិក្សា ........ 26

២.៨ ការស្រាវជ្រាវដែលពាក់ព័ន្ធនឹងមុខសញ្ញាចំណាយ ........ 32

**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ** ........ 35

៣.១ គម្រោងវិភាគ ........ 35

៣.២ ការប្រមូលទិន្នន័យ ........ 36

៣.៣ ឧបករណ៍ស្រាវជ្រាវ ........ 37

៣.៣.១- កម្រងសំណួរបំពេញសម្រាប់សិស្ស ........ 37

៣.៣.២- កម្រងសំណួរសម្ភាសន៍សម្រាប់មាតាបិតា/អាណាព្យាបាលសិស្ស ........ 39

៣.៣.៣- កម្រងសំណួរសម្ភាសន៍សម្រាប់គណៈគ្រប់គ្រងសាលារៀន ........ 40

៣.៣.៤- កម្រងសំណួរសម្ភាសន៍សម្រាប់គ្រូបង្រៀន ........ 40

៣.៣.៥- ការសង្កេត ..... 41
៣.៤ ការជ្រើសរើសភាគសំណាក ..... 41
៣.៥ ការវិភាគទិន្នន័យ ..... 42
**ជំពូកទី៤៖ លទ្ធផលនិងការពិភាក្សា** ..... 44
៤.១- ការវិភាគទិន្នន័យលើកម្រងសំណួរស្តីពីព័ត៌មានប្រជាសាស្ត្ររបស់សិស្ស មាតាបិតា គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន ..... 44
៤.១.១- ព័ត៌មានប្រជាសាស្ត្ររបស់សិស្សានុសិស្ស ..... 45
៤.១.២- ព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតា អាណាព្យាបាលសិស្ស ..... 46
៤.១.៣- ព័ត៌មានប្រជាសាស្ត្ររបស់គណៈគ្រប់គ្រងសាលារៀន ..... 51
៤.១.៤- ព័ត៌មានប្រជាសាស្ត្ររបស់គ្រូបង្រៀន ..... 53
៤.២- ការវិភាគទិន្នន័យលើកម្រងសំណួរស្តីពី មុខសញ្ញាចំណាយលើការសិក្សារបស់សិស្ស កម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ ..... 54
៤.២.១- មុខសញ្ញាចំណាយលើការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិតាម ការឆ្លើយតបរបស់សិស្ស ..... 55
៤.២.២- លទ្ធផលសរុបនៃការសិក្សាស្រាវជ្រាវលើមុខសញ្ញាចំណាយការសិក្សារបស់សិស្ស កម្រិតមធ្យមសិក្សាបឋមភូមិ តាមការឆ្លើយតបរបស់សិស្ស ..... 65
៤.២.៣- មុខសញ្ញាចំណាយលើការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិតាមការ ឆ្លើយតបរបស់មាតាបិតា/ អាណាព្យាបាលសិស្ស ..... 66
៤.២.៤- មុខសញ្ញាចំណាយលើការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិតាមការ ឆ្លើយតបរបស់ គណៈគ្រប់គ្រងសាលារៀន ..... 67
៤.២.៥- មុខសញ្ញាចំណាយលើការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិតាមការ ឆ្លើយតបរបស់គ្រូបង្រៀន ..... 68

៤.២.៦- មុខសញ្ញាចំណាយលើការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិតាមការ
សង្កេត ..... 69

៤.៣- ការពិភាក្សាលើមុខសញ្ញាចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ
ក្នុងខេត្តកំពង់ស្ពឺ ..... 69

៤.៤- ការវិភាគទិន្នន័យលើកម្រងសំណួរស្តីពី បញ្ហាប្រឈមលើចំណាយការសិក្សារបស់សិស្ស
កម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ ..... 72

៤.៤.១- បញ្ហាប្រឈមលើការចំណាយការសិក្សា តាមការឆ្លើយតបរបស់សិស្ស ..... 72

៤.៤.២- លទ្ធផលសរុបនៃការសិក្សាស្រាវជ្រាវលើបញ្ហាប្រឈមក្នុងការចំណាយការសិក្សា
តាមការឆ្លើយតបរបស់សិស្ស ..... 78

៤.៤.៣- ទិន្នន័យបែបគុណវិស័យស្តីពីបញ្ហាប្រឈមក្នុងការចំណាយការសិក្សារបស់សិស្ស ..... 80

៤.៥- ការពិភាក្សាពីបញ្ហាប្រឈមលើចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ
ក្នុងខេត្តកំពង់ស្ពឺ ..... 83

៤.៦- ការវិភាគទិន្នន័យកម្រងសំណួរស្តីពីការចូលរួមរបស់សាលារៀនក្នុងការកាត់បន្ថយលើ
ចំណាយការសិក្សារបស់សិស្សានុសិស្ស ..... 87

៤.៧- ការពិភាក្សាលើកម្រងសំណួរស្តីពីការចូលរួមរបស់សាលារៀន ក្នុងការកាត់បន្ថយលើ
ចំណាយការសិក្សារបស់សិស្សានុសិស្ស ..... 89

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាននិងសំណូមពរ** ..... 95

៥.១ សេចក្តីសន្និដ្ឋាន ..... 95

៥.២ សំណូមពរ ..... 98

ក. ក្រសួងអប់រំ យុវជន និងកីឡា ..... 98

ខ. សម្រាប់សាលារៀន ..... 98

គ. មាតាបិតា អាណាព្យាបាល និងសហគមន៍ ..... 99

ឃ. សម្រាប់សិស្សានុសិស្ស ..... 99

ង. សម្រាប់អ្នកសិក្សាស្រាវជ្រាវបន្ត ..... 99

**ឯកសារយោង** ..... 100

**ឧបសម្ព័ន្ធ** ..... 105

# បញ្ជីតារាង


| តារាង | បរិយាយ | ទំព័រ |
| --- | --- | --- |
| ៣.១ | ចំនួនភាគសំណាកនៃការស្រាវជ្រាវ | 42 |
| ៤.១ | តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់សិស្សានុសិស្ស | 45 |
| ៤.២ | តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតា អាណាព្យាបាលសិស្ស តាមតួនាទី | 46 |
| ៤.៣ | តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតា អាណាព្យាបាលសិស្ស តាមអាយុ | 46 |
| ៤.៤ | តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតា អាណាព្យាបាលសិស្សតាមមុខរបរ | 47 |
| ៤.៥ | តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតា អាណាព្យាបាលសិស្ស តាមទីកន្លែងរស់នៅ | 47 |
| ៤.៦ | តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតា អាណាព្យាបាលសិស្ស តាមកម្រិតវប្បធម៌ | 48 |
| ៤.៧ | តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតា អាណាព្យាបាលសិស្ស តាមសមាជិកគ្រួសាររស់នៅជាមួយ | 49 |
| ៤.៨ | តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតា អាណាព្យាបាលសិស្ស តាមចំនួនកូនកំពុងសិក្សា | 49 |
| ៤.៩ | តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតា អាណាព្យាបាលសិស្ស តាមសមាជិកដែលអាចរកចំណូលបាន | 50 |
| ៤.១០ | តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតា អាណាព្យាបាលសិស្ស តាមចំណូលសរុបប្រចាំខែ | 51 |
| ៤.១១ | តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់គណៈគ្រប់គ្រងសាលារៀន | 51 |
| ៤.១២ | តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់របស់គ្រូបង្រៀន | 53 |
| ៤.១៣ | មធ្យោបាយធ្វើដំណើររបស់សិស្សានុសិស្ស | 55 |
| ៤.១៤ | ការចំណាយលើការសិក្សាជាប្រចាំថ្ងៃ( គិតជារៀល/ដុល្លារ ) | 55 |
| ៤.១៥ | ការចំណាយលើការសិក្សាជាប្រចាំសប្តាហ៍( គិតជារៀល/ដុល្លារ ) | 56 |

| | | |
|---|---|---|
| ៤.១៦ | ការចំណាយលើការសិក្សាជាប្រចាំខែ(គិតជារៀល/ដុល្លារ) | 56 |
| ៤.១៧ | ការសិក្សាគួរក្រៅម៉ោងបន្ថែម (គិតជាម៉ោង) | 57 |
| ៤.១៨ | ការចំណាយពេលរៀនគួរក្រៅម៉ោង (គិតជាថ្ងៃ) | 58 |
| ៤.១៩ | ការចំណាយប្រាក់រៀនគួរក្រៅម៉ោងក្នុងមួយមុខវិជ្ជា (គិតជារៀល) | 58 |
| ៤.២០ | ការចំណាយប្រចាំថ្ងៃក្នុងមួយឆ្នាំសិក្សា | 59 |
| ៤.២១ | ការចំណាយថ្លៃសាលារៀនក្នុងមួយឆ្នាំសិក្សា | 60 |
| ៤.២២ | ការចំណាយដើមឆ្នាំសិក្សាក្នុងមួយឆ្នាំសិក្សា (ឯកសណ្ឋានសាលា) | 61 |
| ៤.២៣ | ការចំណាយដើមឆ្នាំសិក្សាក្នុងមួយឆ្នាំសិក្សា (ចំណាយលើសម្ភារៈសិក្សា) | 62 |
| ៤.២៤ | ការចំណាយដើមឆ្នាំសិក្សាក្នុងមួយឆ្នាំសិក្សា (ចំណាយលើការចុះឈ្មោះចូលរៀន) | 63 |
| ៤.២៥ | ការចំណាយបន្ថែមក្នុងមួយឆ្នាំសិក្សា | 64 |
| ៤.២៦ | លទ្ធផលសរុបលើមុខសញ្ញាចំណាយលើការសិក្សា | 65 |
| ៤.២៧ | ការចំណាយជាប្រចាំថ្ងៃ | 66 |
| ៤.២៨ | បញ្ហាប្រឈមលើផ្នែកសតិអារម្មណ៍និងភាពជឿជាក់ | 72 |
| ៤.២៩ | បញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើការចំណាយប្រចាំថ្ងៃ | 73 |
| ៤.៣០ | បញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើការចំណាយថ្លៃសារៀន | 74 |
| ៤.៣១ | បញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើការចំណាយដើមឆ្នាំសិក្សា (ឯកសណ្ឋានសាលា) | 75 |
| ៤.៣២ | បញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើការចំណាយដើមឆ្នាំសិក្សា (សម្ភារៈសិក្សា) | 76 |
| ៤.៣៣ | បញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើការចំណាយដើមឆ្នាំសិក្សា (ការចុះឈ្មោះចូលរៀន) | 77 |
| ៤.៣៤ | បញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើការចំណាយបន្ថែម | 77 |
| ៤.៣៥ | បញ្ហាប្រឈមលើការសម្រេចចិត្ត | 78 |
| ៤.៣៦ | ទិន្នន័យសរុបលើបញ្ហាប្រឈមក្នុងការចំណាយការសិក្សាតាមការឆ្លើយតបរបស់សិស្ស | 79 |
| ៤.៣៧ | ទិន្នន័យបែបគុណវិស័យស្ដីពីបញ្ហាប្រឈមក្នុងការចំណាយការសិក្សារបស់សិស្ស | 80 |
| ៤.៣៨ | ទិន្នន័យបែបគុណវិស័យស្ដីពីការចូលរួមរបស់សាលារៀនក្នុងការកាត់បន្ថយលើ ចំណាយការសិក្សារបស់សិស្ស | 87 |

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| PAP | : | Priority Action Plan |
| SOB | : | School Operational Budgets |
| IES | : | Institute of Education Sciences |
| NEP | : | NGO Education Partnership |
| GDP | : | Gross Domestic Product |
| EFA | : | Education for All |
| ESP | : | Education Strategic Plan |
| ESSP | : | Education Sector Support Project |
| ADB | : | Asian Development Bank |
| WB | : | World Bank |
| KAPE | : | Kampuchea Action to Promote Education |
| OECD | : | Organization for Economic Co-operation and Development |
| UN | : | United Nations |
| UNICEF | : | United Nations International Children's Emergency Fund |
| UNDP | : | United Nations Development Programme |
| UNFPA | : | United Nations Fund for Population Activities |
| UNESCO | : | United Nations Educational, Scientific and Cultural Organization |

# មូលន័យសង្ខេប

គោលនយោបាយជាតិនិងគោលនយោបាយអប់រំ បានកំណត់ការផ្តល់ជូនសេវាអប់រំយ៉ាងតិច៩ឆ្នាំ ដោយឥតគិតថ្លៃនៅសាលារៀនសាធារណៈ ក្នុងគោលបំណងលើកស្ទួយនិងជំរុញឱ្យកុមារគ្រប់រូបទទួលបានឱកាសសិក្សានៅសាលារៀន។ ទោះបីជាយ៉ាងនេះក្តី មាតាបិតា អាណាព្យាបាលនៅតែមានការចំណាយលើការសិក្សារបស់កូនទាំងការចំណាយដោយផ្ទាល់ និងប្រយោល។ កាលបើការចំណាយកាន់តែច្រើននឹងជះឥទ្ធិពលអវិជ្ជមានដល់សេដ្ឋកិច្ច អារម្មណ៍ និងការសម្រេចចិត្តរបស់សិស្សនិងឪពុកម្តាយជាមិនខាន។ ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវ បានផ្តោតលើមុខសញ្ញាចំណាយអំឡុងពេលសិក្សារបស់សិស្ស បញ្ហាប្រឈមលើចំណាយការសិក្សានិងការចូលរួមរបស់សាលារៀនក្នុងការកាត់បន្ថយចំណាយការសិក្សារបស់សិស្សានុសិស្ស ជាពិសេសសិស្សមានជីវភាពខ្វះខាតនៅកម្រិតមធ្យមសិក្សាបឋមភូមិ ខេត្តកំពង់ស្ពឺ។ ដើម្បីធានាបានលទ្ធផលនៃការស្រាវជ្រាវនេះកាន់តែស៊ីជម្រៅនិងមានភាពច្បាស់លាស់អាចជឿជាក់បាន អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រតាមបែបបរិមាណវិស័យ និងគុណវិស័យក្នុងការប្រមូលទិន្នន័យយកមកវិភាគ ដែលទទួលបានពីសិស្ស មាតាបិតា អាណាព្យាបាល គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន នៅសាលាមធ្យមសិក្សាបឋមភូមិចំនួនបី ក្នុងខេត្តកំពង់ស្ពឺ សរុបចំនួន ១៧៣ នាក់។ ទន្ទឹមនឹងនេះ ការសង្កេតតាមសាលារៀនគោលដៅ ត្រូវបានសង្កេតយ៉ាងយកចិត្តទុកដាក់។

ជាលទ្ធផល ការសិក្សាស្រាវជ្រាវនេះ បានបង្ហាញថាមុខសញ្ញាចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាខេត្តកំពង់ស្ពឺ មានបួនសំខាន់ៗគឺ ទីមួយ៖ ការចំណាយប្រចាំថ្ងៃ (លើអាហារបរិភោគ/នំចំណី ការរៀនគួរក្រៅម៉ោង ចំណតកង់ ចំណតម៉ូតូ មធ្យោបាយធ្វើដំណើរ)។ ទីពីរ៖ ការចំណាយថ្លៃសាលារៀន (លើគ្រូបង្រៀន ឯកសារបង្រៀន/ទិញមេរៀនគ្រូ ក្រដាសប្រឡង/ឯកសារប្រឡង សៀវភៅតាមដានការអង្គាសមូលនិធិ អគ្គិសនី ការផាកពិន័យអវត្តមាន និងការមករៀនយឺតជាទឹកប្រាក់)។ ទីបី៖ ការចំណាយដើមឆ្នាំសិក្សា លើឯកសណ្ឋានសាលា (ដូចជា ឯកសណ្ឋានប្រចាំថ្ងៃ ឯកសណ្ឋានកីឡា ស្បែកជើងប៉ាត់តា ស្បែកជើងកីឡា កាតសិស្ស) លើសម្ភារៈសិក្សា (ដូចជា កាបូបស្ពាយ សៀវភៅសរសេរ សៀវភៅអាន សៀវភៅលំហាត់ ប៊ិក ខ្មៅដៃ បន្ទាត់... ក្របសៀវភៅ) លើការចុះឈ្មោះចូលរៀន (ដូចជា

ពាក្យសុំចូលរៀន និងរូបថត)។ ទីបួន៖ លើការចំណាយបន្ថែម (លើការផ្គត់ផ្គង់សម្ភារៈសិក្សា ការផ្គត់ផ្គង់ថ្នាក់រៀន ការជួសជុលកង់/ម៉ូតូ និងការរៀបចំកម្មវិធី)។ ក្នុងចំណោមនោះ ការចំណាយដែលច្រើនជាងគេគឺការចំណាយប្រចាំថ្ងៃ។ ទន្ទឹមនឹងនេះ ការចំណាយលើការសិក្សារបស់សិស្សគឺស្ថិតក្នុងបញ្ហាប្រឈមកម្រិតមធ្យម ជាពិសេសលើផ្នែកសេដ្ឋកិច្ចតែម្តង។ លទ្ធផលបានបង្ហាញថាក្រុមគ្រួសារសិស្សបានចំណាយលើការសិក្សារបស់កូនក្នុងម្នាក់ប្រមាណ ១០.៧២ ភាគរយនៃចំណាយការប្រើប្រាស់ប្រចាំខែ ដែលបានសរបញ្ជាក់ថាការចំណាយនេះស្ថិតក្នុងបញ្ហាប្រឈមគួរឱ្យព្រួយបារម្ភផងដែរ។ វាកាន់តែពិបាកសម្រាប់គ្រួសារដែលមានស្ថានភាពក្រីក្រលំបាក ប្រាក់ចំណូលមានកម្រិត ជាប់បំណុល និងមានកូនច្រើនកំពុងសិក្សានៅសាលារៀនធ្វើឱ្យការចំណាយកើនទ្វេគុណ។ បញ្ហាប្រឈមទាំងនេះ ផ្តល់ឥទ្ធិពលអវិជ្ជមានទាំងទំនុកចិត្តរបស់សិស្សនិងសម្រេចចិត្តរបស់ឪពុកម្តាយផង។ សាលារៀនពិតជាសំខាន់ក្នុងការដោះស្រាយដោយផ្ទាល់ និងការទាញចំណាប់អារម្មណ៍សហគមន៍ ភាគីពាក់ព័ន្ធពេញចិត្តក្នុងការចូលរួមជាមួយសាលារៀន។ គណៈគ្រប់គ្រងសាលារៀននិងគ្រូបង្រៀនតែងតែប្រើយុទ្ធវិធី ដើម្បីកៀរគរសហគមន៍ សប្បុរសជនចូលរួមក្នុងកិច្ចដំណើរការសាលារៀនប្រកបដោយទំនុកចិត្តនិងតម្លាភាព។ តួយ៉ាង បានផ្តល់ជូនសម្ភារៈសិក្សា ថវិកា និងស្មារតី លើកទឹកចិត្ត ណែនាំ កាត់បន្ថយការចំណាយក្នុងសាលារៀន គ្រប់គ្រងតម្លៃការលក់ចំណីក្នុងសាលា យន្តការបញ្ជ្រាបដល់អាណាព្យាបាលរៀបចំអាហារពីផ្ទះ រឹតបន្តឹងការរអែង្គាសក្នុងថ្នាក់ កំណត់អត្តសញ្ញាណសិស្សក្រីក្រពិតប្រាកដ និងគិតដល់សិស្សជួបការលំបាកជាអាទិភាព ។

ជារួមមក ការសិក្សាស្រាវជ្រាវនេះបានរកឃើញពីស្ថានភាពនៃមុខសញ្ញាចំណាយសំខាន់ៗ និងបញ្ហាប្រឈមលើការចំណាយការសិក្សារបស់សិស្សានុសិស្សក្នុងខេត្តកំពង់ស្ពឺកំពុងជួប ព្រមទាំងបានផ្តល់នូវបទពិសោធ គំនិត ព័ត៌មាន សម្រាប់ថ្នាក់ដឹកនាំសាលារៀន ដើម្បីស្វែងរកយុទ្ធវិធីក្នុងការចូលរួមកាត់បន្ថយចំណាយលើការសិក្សារបស់សិស្សានុសិស្ស ពិសេសផ្តោតយកចិត្តទុកដាក់ចំពោះសិស្សដែលមានជីវភាពខ្វះខាតនិងប្រឈមមុខការបោះបង់ការសិក្សា។ ការសិក្សានេះមានសារៈសំខាន់មិនមែនត្រឹមសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺប៉ុណ្ណោះទេ ប៉ុន្តែវាក្លាយជាព័ត៌មានដ៏មានប្រយោជន៍ក្នុងវិស័យអប់រំទាំងមូល ដើម្បីជាមូលដ្ឋានក្នុងការកំណត់បញ្ហាចំគោលដៅនិងដោះស្រាយបញ្ហាទាន់ពេលវេលា។

## Abstract

National policy and education policy set out to provide free education services for at least nine years in public schools to promote and encourage all children to have access to education at school. However, parents still have to pay for their children's education, both directly and indirectly. As more money is spent, it will negatively affect the economy, emotions, and decisions of students and parents. In this study, the researchers focused on the issues of students 'study time, the challenges of school expenses, and the involvement of schools in reducing the cost of students' education, especially poor students at the lower secondary level in Kampong Speu province. To ensure the results of this research are more in-depth and reliable, the researchers used quantitative, quantitative, and qualitative methods to collect and analyze data obtained from students, parents, guardians, school management, and teachers. They are teaching at 3 lower secondary schools in Kampong Speu province, a total of 173 students. On the other hand, observations are carefully observed.

As a result, this study shows that the study expenses of secondary school students in Kampong Speu province have four main reasons: First: Daily expenses (on food/snacks, part-time study, bicycle parking, motorcycle parking, transportation). Second: School expenses (on teachers, teaching materials/purchasing lessons, teachers, exam papers/exam papers, tracking books, fundraising, electricity, fines, absences, and late arrivals in cash). Third: Spending early school year on school uniforms (such as daily uniforms, sports uniforms, sneakers to school, sports shoes, and student cards) on study materials (Such as backpacks, notebooks, reading books, exercise books, pens, pencils,

lines... book covers) on Enrollment (such as application form and photo). Fourth: Additional costs (on the supply of study materials, classroom supplies, bicycle/motorcycle repairs, and program design). Among them, the highest cost is daily expenses. At the same time, the cost of students' education is at a moderate level, especially in the economic field. The results show that the student family spends about 10.72% of their child's education on monthly expenses, which indicates that these costs are also a serious challenge. It is even more difficult for families with poor conditions, low incomes, debt, and many children in school to double the cost. These challenges negatively impact student confidence and parental decisions. The school is very important to directly address and engage the community, Stakeholders appreciate the school's involvement. School management and teachers always use tactics to mobilize the philanthropic community to participate in the school process with confidence and transparency. For example, the provision of study materials, budgets, and motivation to provide a good feeling, reduce unnecessary school expenses, restrict class fundraising that is not beneficial for students, identify really poor students, and think Students face difficulties as a priority.

Overall, this study found the situation of the main expenditures and challenges on the study expenses of students in Kampong Speu province as well as provided experiences, ideas, and information for school leaders to find strategies in Participation in reducing the cost of study of students, especially focusing on students who have a poor standard of living and face dropout. This study is critical not only for lower secondary schools in Kampong Speu but also to be useful information in the education sector as a whole as a basis for identifying targeted issues and solving problems promptly.

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

គ្រប់បណ្តាប្រទេសអភិវឌ្ឍ បាននឹងកំពុងបន្តកិច្ចខិតខំប្រឹងប្រែងរៀបចំផែនការគោលនយោយជាតិរបស់ខ្លួនដើម្បីរុញច្រានសេដ្ឋកិច្ច សង្គមឆ្ពោះទៅរកការរីកចម្រើននាពេលអនាគត ជាពិសេសក្នុងបរិបទប្រទេសដែលស្ថិតក្នុងដំណើរការកំពុងអភិវឌ្ឍរួមមានកម្ពុជានិងប្រទេសដទៃទៀតរឹតតែខិតខំស្ទុះស្ទារយ៉ាងសកម្មលើគ្រប់វិស័យ។ ក្នុងលក្ខខណ្ឌចាំបាច់ ប្រទេសកម្ពុជាបានជ្រើសយកការអប់រំ គឺជាយុទ្ធសាស្រ្តសំខាន់ជាងគេ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា២០១៦-២០៣០ សំដៅប្រែក្លាយកម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នាឆ្នាំ២០៥០ ហើយបានចាត់ទុកការអប់រំ ជាដំណោះស្រាយតែមួយគត់ សម្រាប់អភិវឌ្ឍធនធានមនុស្សដែលជាតម្រូវការចាំបាច់និងជំរុញឱ្យមាននវានុវត្តន៍ និងអភិវឌ្ឍន៍ខ្លាំងក្លាពីសេដ្ឋកិច្ចពឹងផ្អែកលើកម្លាំងពលកម្មទៅជាសេដ្ឋកិច្ចផ្អែកលើចំណេះដឹង (ក្រសួងអប់រំយុវជននិងកីឡា, ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤, ២០១៩)។ យោងតាមច្បាប់ស្តីពីការអប់រំ (២០០៧) បានចែងថាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលបានការអប់រំយ៉ាងតិច៩ឆ្នាំប្រកបដោយគុណភាពដោយឥតបង់ថ្លៃនៅសាលារៀនសាធារណៈ។ ហើយរដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប" (ក្រុមប្រឹក្សាធម្មនុញ្ញ, ២០១៥)។

ដើម្បីឆ្លើយតបនឹងគោលនយោបាយជាតិ ទើបក្រសួងអប់រំ យុវជន និងកីឡាបានខិតខំប្រឹងប្រែងដាក់ចេញនូវគោលនយោបាយអប់រំពីរសំខាន់គឺទី១៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌និងបរិយាបន្ននិងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ទី២៖ ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ក្រសួងអប់រំ បានកំណត់វត្ថុបំណងចំពោះមុខដោយធានាថាយុវជន និងកុមារកម្ពុជាគ្រប់រូបមានឱកាសស្មើភាពគ្នាក្នុងការទទួលបាន

ការអប់រំប្រកបដោយគុណភាពស្របតាមរដ្ឋធម្មនុញ្ញ ពោលគឺប្រកាន់យកគោលការណ៍មិនរើសអើងអំពីស្ថានភាពគ្រួសារ ភូមិសាស្ត្រ ពូជសាសន៍ សាសនា ភាសា យេនឌ័រ និងកាយសម្បទានោះឡើយ (ក្រសួងអប់រំយុវជននិងកីឡា., ២០១៨)។ អាទិភាពទី១ ក្នុងចំណោមអាទិភាពគោលនយោបាយ៥ ត្រូវបានដាក់ចេញសម្រាប់ឆ្នាំ២០៣០ គឺកុមារីនិងកុមារាគ្រប់រូបទទួលបានការគាំពារ និងការអប់រំកុមារតូចនិងការអប់រំមត្តេយ្យសិក្សាប្រកបដោយគុណភាព និងបញ្ចប់ការអប់រំកម្រិតមូលដ្ឋាន (បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ) ដោយឥតគិតថ្លៃប្រកបដោយសមធម៌ និងគុណភាពដែលទទួលបានលទ្ធផលសិក្សាប្រកបដោយប្រសិទ្ធភាពនិងភាពឆ្លើយតប។ ក្នុងនោះ ចំណុចដែលត្រូវផ្តោតយកចិត្តទុកដាក់ គឺនៅកម្រិតមធ្យមសិក្សាបឋមភូមិដែលជាកិច្ចការបន្ទាន់ដោយបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធអប់រំតាមរយៈការកាត់បន្ថយអត្រាបោះបង់ការសិក្សា និងអត្រារៀនត្រួតថ្នាក់ (ក្រសួងអប់រំយុវជននិងកីឡា, ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤, ២០១៩) ដែលស្របជាមួយនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៥ បានចែងថារដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលាសាធារណៈសម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ។

សាលាមធ្យមសិក្សាបឋមភូមិជាថ្នាលពង្រីក និងពង្រឹងការរៀនជំនាញដែលទទួលបានពីបឋមសិក្សា និងត្រូវបានកំណត់ជាកត្តាដ៏សំខាន់ក្នុងការទទួលបានប្រាក់ចំណូលពីឯកជន និងសង្គមដោយបង្កើតឱកាសវិនិយោគនានា។ ភូមិសិក្សានេះ គឺជាការផ្តល់នូវជំនាញសម្រាប់កុមារមួយចំនួន ក្នុងការទទួលបានការងារធ្វើ ខណៈកុមារភាគច្រើននឹងប្រើប្រាស់ជំនាញទាំងនោះសម្រាប់សិក្សាបន្ត និងជាលទ្ធផលនៃការបញ្ចូលគ្នាសម្រាប់កុមារនិងយុវជនដែលបាត់បង់ឱកាសក្នុងការទទួលបានការងារតាមលទ្ធភាព (ហង់ជួនណារ៉ុន, ២០១៦)។

ដោយមើលឃើញពីកម្រិតសំខាន់នេះហើយទើបធ្វើឱ្យក្រសួងអប់រំ យុវជននិងកីឡានៅតែបន្តកិច្ចខិតខំប្រឹងប្រែងបង្កើនអត្រាបញ្ចប់ការសិក្សាសម្រាប់ការអប់រំកម្រិតមូលដ្ឋាន ជាពិសេសផ្តោតលើក្រុមសិស្សមកពីគ្រួសារដែលមានជីវភាពក្រីក្រ និងជួបបញ្ហាប្រឈម កាត់បន្ថយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា តាមរយៈការអនុវត្តកម្មវិធីសកម្មភាព និងការពង្រឹងគុណភាពអប់រំ ដោយផ្តោតសំខាន់

លើប្រសិទ្ធភាពនៃការដឹកនាំនិងគ្រប់គ្រងរបស់គណៈគ្រប់គ្រងតាមសាលារៀន ដូចជាការកំណត់តួនាទីភារកិច្ចនាយកសាលាដែលត្រូវតែអ្នកមានជំនាញទាំងការគ្រប់គ្រង និងដឹកនាំប្រែក្លាយសាលារៀនទៅជាកន្លែងមួយកាន់តែប្រសើរឡើងសម្រាប់សិស្ស រួមជាមួយការបង្កើនការចូលរួមពីភាគីពាក់ព័ន្ធនានាជាអាទិ៍សហគមន៍ មាតាបិតា អាណាព្យាបាលរបស់សិស្សានុសិស្ស (ហង់ជួនណារ៉ុន, ២០១៦)។ ក្រៅពីនេះ យោងតាមអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន (២០០៨) បានកំណត់ពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនដោយប្រកាន់ខ្ជាប់សីលធម៌ក្នុងការប្រកបវិជ្ជាជីវៈ លើកកម្ពស់គុណភាព ប្រសិទ្ធភាពអប់រំ មិនលម្អៀង គ្មានការគំរាមគំហែងលើកាយចិត្តដែលធ្វើឱ្យប៉ះពាល់ប្រយោជន៍អ្នកសិក្សា មិនអនុញ្ញាតគ្រូបង្រៀនឱ្យមានការរ៉ែអង្គាសប្រាក់ឬធ្វើអាជីវកម្មក្នុងថ្នាក់រៀនឡើយ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

បើទោះបីជា ប្រទេសមានគោលនយោបាយជាតិឬគោលនយោបាយអប់រំជាច្រើនបានកំណត់ការផ្តល់ជូនសេវាអប់រំសាធារណៈឥតបង់ថ្លៃយ៉ាងណាក្តី ក៏ប៉ុន្តែភាពជាក់ស្តែងត្រូវមានការចំណាយ ដោយមួយផ្នែកធំគឺត្រូវបានរដ្ឋជាអ្នកទទួលរ៉ាប់រង និងមួយផ្នែកទៀតត្រូវធ្លាក់ទៅលើក្រុមគ្រួសារ។ ជាពិសេស ការចំណាយដោយផ្ទាល់និងដោយប្រយោលនៃការអប់រំនេះ បានកើនឡើងយ៉ាងខ្លាំងក្នុងកម្រិតបឋមភូមិនិងទុតិយភូមិ (WorldBank, 2005)។ ដ្បិតមានការអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព (PAP) នៅឆ្នាំ ២០០០ និងថវិកាដំណើរការសាលារៀន (SOB) បានជួយកាត់បន្ថយចំណាយផ្ទាល់របស់គ្រួសារបានមួយកម្រិតក៏ដោយ ក៏ចំណាយផ្សេងទៀតនៅតែខ្ពស់ដដែល (ហង់ជួនណារ៉ុន, ២០១៦) ដែលឥទ្ធិពលនេះប៉ះពាល់ដល់ការទទួលបានសេវាអប់រំប្រកបដោយគុណភាពនិងសមធម៌។ ជាទឡ្ហីករណ៍ ផ្អែកលើផលសម្រេចបានក្នុងអនុវិស័យការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស ឆ្នាំសិក្សា២០២០-២០២១ បានបង្ហាញថា អត្រាឆ្លងភូមិសិក្សានៅមធ្យមសិក្សាបឋមភូមិ ៧៨,២ភាគរយ ថយ៣,១ភាគរយ ស្រី៧៩,៦ភាគរយ ថយ២,៨ភាគរយ។ អត្រានៃការចុះឈ្មោះចូលរៀននៅមានកម្រិតទាប ការបោះបង់ការសិក្សាមានកម្រិតខ្ពស់ ដែលជាទូទៅគឺដោយសារឱកាសទទួលបានការងាយធ្វើ ចម្ងាយពីសាលាទៅផ្ទះនៅតំបន់ជនបទ បញ្ហាពាក់ព័ន្ធនានាក្នុងការអប់រំនៅមធ្យមសិក្សាបឋមភូមិ និងអ្វីដែលកាន់តែពិសេសគឺការ

ចំណាយផ្ទាល់នៃការអប់រំ(សៀវភៅ ឯកសណ្ឋាន ការធ្វើដំណើរ) និងការចំណាយក្រៅផ្លូវការ ជាបញ្ហាដែលធ្វើឱ្យកំណើនអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិទទួលបានគុណផលទាប (ហង់ ជួនណារ៉ុន, ២០១៦)។

ការចំណាយរបស់គ្រួសារសម្រាប់ការអប់រំ កើនឡើងនៅពាសពេញពិភពលោក ប៉ុន្តែកំណើននេះលេចធ្លោខ្លាំងក្នុងប្រទេសកម្ពុជា ពីព្រោះថារដ្ឋាភិបាលមិនមានធនធានគ្រប់គ្រាន់ហើយមិនអាចបំពេញតម្រូវការបានទាំងអស់។ ប្រសិនបើការអប់រំ គឺជាចំណាយដ៏ច្រើនបំផុតរបស់គ្រួសារ នោះការរារែកចិត្តក្នុងការបញ្ជូនកូនទៅរៀននឹងក្លាយជាទម្លាប់នៃការគិតប្រចាំថ្ងៃរបស់ឪពុកម្តាយ ខណៈដែលគ្រួសារមួយចំនួនពិសេសគ្រួសារជួបការលំបាក មានចំណូលទាប ចំណាយច្រើន ជាប់បំណុល បានគិតពីផលប្រយោជន៍និងការខាត់បង់ដើម្បីដឹងថាការបញ្ជូនកូនទៅសាលារៀនមានប្រយោជន៍កម្រិតណា។ ពួកគេនឹងថ្លឹងថ្លែងបន្តថា តើផលប្រយោជន៍សេដ្ឋកិច្ចទទួលបានពីការរៀនសូត្រអាចមានទម្ងន់ជាងការសរុបចំណាយរបស់គ្រួសារសិស្សទាំងការចំណាយផ្ទាល់និងប្រយោលដែរឬទេ? (Bray and Seng, 2005)។

សរុបជារួមមក នៅពេលដែលមុខសញ្ញាចំណាយលើការសិក្សារបស់សិស្សច្រើនជាងចំណូលក្នុងគ្រួសារ នោះវានឹងនាំឱ្យកើតមាននូវបញ្ហាប្រឈម ដែលចាំបាច់ត្រូវស្វែងរកគ្រប់មធ្យោបាយដើម្បីដោះស្រាយបញ្ហាទាំងនេះទាន់ពេលវេលាតាមលទ្ធភាព។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងមានគោលបំណងសំខាន់បីគឺ៖

១.ចង់ដឹងពីមុខសញ្ញាចំណាយអំឡុងពេលសិក្សារបស់សិស្សានុសិស្សកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ។

២.សិក្សាពីបញ្ហាប្រឈមលើចំណាយការសិក្សារបស់សិស្សានុសិស្សកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ។

៣.ស្វែងរកលទ្ធភាពដែលសាលារៀនអាចចូលរួមដើម្បីកាត់បន្ថយចំណាយការសិក្សារបស់សិស្សានុសិស្ស ជាពិសេសសិស្សមានជីវភាពខ្វះខាតនៅកម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបនឹងគោលបំណងនៃការសិក្សាស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវបានលើកឡើងនូវសំណួរស្រាវជ្រាវចំនួនបីគឺ៖

១.តើមុខសញ្ញាចំណាយលើការសិក្សារបស់សិស្សានុសិស្សកម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺមានអ្វីខ្លះ?

២.តើមានបញ្ហាប្រឈមអ្វីខ្លះ លើចំណាយការសិក្សារបស់សិស្សានុសិស្សកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ?

៣.តើមានមធ្យោបាយអ្វីខ្លះ ដែលសាលារៀនអាចចូលរួមកាត់បន្ថយលើចំណាយការសិក្សារបស់សិស្សានុសិស្សក្នុងខេត្តកំពង់ស្ពឺ ជាពិសេសសិស្សមានជីវភាពខ្វះខាត?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ នឹងផ្តល់ជូនជាឯកសារសម្រាប់បង្ហាញពីស្ថានភាពនៃមុខសញ្ញាចំណាយ និង បញ្ហាប្រឈមលើចំណាយការសិក្សារបស់សិស្សានុសិស្សកំពុងជួបប្រទះ និងអាចផ្តល់នូវបទពិសោធន៍ គំនិត ព័ត៌មាន សម្រាប់ថ្នាក់ដឹកនាំសាលារៀនស្វែងរកលទ្ធភាពដើម្បីកាត់បន្ថយចំណាយលើការសិក្សារបស់សិស្សានុសិស្ស ពិសេសផ្តោតយកចិត្តទុកដាក់ចំពោះសិស្សដែលមានជីវភាពខ្វះខាតនិងប្រឈមមុខការបោះបង់ការសិក្សា។

លទ្ធផលដែលទទួលបានពីការស្រាវជ្រាវនេះ នឹងក្លាយជាព័ត៌មានដ៏មានប្រយោជន៍ក្នុងវិស័យអប់រំក្នុងការកំណត់បញ្ហាចំគោលដៅនិងដោះស្រាយបញ្ហាទាន់ពេលវេលា និងជាមូលដ្ឋានក្នុងការថ្លឹងថ្លែងចំពោះ គោលនយោបាយស្តីពីការផ្តល់សេវាអប់រំជាមូលដ្ឋានដោយឥតគិតថ្លៃដល់មនុស្សគ្រប់រូបនិងភាពជាក់ស្តែង ដើម្បីទទួលបានទាំងគុណភាពប្រកបដោយសមធម៌និងបរិយាបន្ន។

អ្នកស្រាវជ្រាវប្រាកដថា ការសិក្សាប្រធាននេះនឹងបានផ្តល់នូវបេកគំហើញថ្មីមួយសម្រាប់ចូលរួមវិភាគទាន ជាទុនក្នុងការសំរួលដល់អ្នកសិក្សាជំនាន់ក្រោយៗឱ្យមានការសិក្សាកាន់តែស៊ីជម្រៅលម្អិតដើម្បីបម្រើប្រយោជន៍វិស័យអប់រំបន្ថែមទៀត។

## ១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីឱ្យការសិក្សាស្រាវជ្រាវលើប្រធានបទបានល្អ និងវិភាគបានគ្រប់ជ្រុងជ្រោយទៅលើប្រធានបទស្តីពី៖ ការសិក្សាពីមុខសញ្ញាចំណាយលើការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ ខេត្តកំពង់ស្ពឺ អ្នកសិក្សាស្រាវជ្រាវបានកំណត់យកអនុវិទ្យាល័យចំនួនបីក្នុងខេត្តកំពង់ស្ពឺ។ ចំពោះទិន្នន័យដែលប្រមូលយកមកធ្វើការវិភាគដើម្បីបង្ហាញលទ្ធផលនៃការសិក្សាគឺមានការចូលរួមពីសិស្សានុសិស្សចំនួន១៣៥នាក់ គណៈគ្រប់គ្រងចំនួន៨នាក់ គ្រូបង្រៀនចំនួន១៥នាក់ ដោយជ្រើសរើសពីអនុវិទ្យាល័យឆាយធុបស្ថិតនៅក្នុងក្រុងច្បារមន អនុវិទ្យាល័យត្រពាំងឈូកស្ថិតនៅក្នុងស្រុកសំរោងទងនិងវិទ្យាល័យសម្តេចជាស៊ីមឱរ៉ាល់ស្ថិតនៅក្នុងស្រុកឱរ៉ាល់ និងមានការចូលរួមពីអាណាព្យាបាលសិស្សចំនួន១៥នាក់។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានបែងចែកជា៥ជំពូកធំៗ

**ជំពូកទី១៖** សេចក្តីផ្តើម នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានលើកឡើងពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ។

**ជំពូកទី២៖** រំឭកទ្រឹស្តី នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានប្រមូលយកនូវទ្រឹស្តីផ្សេងៗពាក់ព័ន្ធនឹងប្រធានបទ ពីអ្នកសិក្សាស្រាវជ្រាវមុនៗ មានទាំងឯកសារក្នុងស្រុកនិងក្រៅស្រុក អត្ថបទស្រាវជ្រាវជាតិនិងអន្តរជាតិ សៀវភៅ ឯកសារពាក់ព័ន្ធនានារបស់ក្រសួងអប់រំ យុវជននិងកីឡា និងឯកសារពាក់ព័ន្ធនានាដើម្បីបង្កើតនូវកម្រងស្នាដៃថ្មីនេះឡើង។

**ជំពូកទី៣៖** វិធីសាស្ត្រស្រាវជ្រាវ ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញពីគម្រោងវិភាគ ការប្រមូលទិន្នន័យ ឧបករណ៍ស្រាវជ្រាវ ការជ្រើសរើសភាគសំណាក និងការវិភាគទិន្នន័យ។

**ជំពូកទី៤៖** លទ្ធផលនិងការវិភាគ ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងយកទិន្នន័យដែលប្រមូលបានមកធ្វើការវិភាគ និងធ្វើការបកស្រាយឱ្យបានយ៉ាងក្បោះក្បាយ ដើម្បីរកឱ្យឃើញមុខសញ្ញាចំណាយ

បញ្ហាប្រឈមលើការចំណាយ និងលទ្ធភាពចូលរួមកាត់បន្ថយចំណាយការសិក្សារបស់សិស្សានុសិស្ស កម្រិតមធ្យមសិក្សាបឋមភូមិខេត្តកំពង់ស្ពឺ។

**ជំពូកទី៥៖** សេចក្ដីសន្និដ្ឋាននិងសំណូមពរ ជាជំពូកចុងក្រោយដែលអ្នកស្រាវជ្រាវត្រូវធ្វើសេចក្ដីសន្និដ្ឋានលើចំណុចរួមទាំងអស់ដែលបានវិភាគ ផ្ដល់ជាយោបល់ទៅលើចំណុចត្រូវកែលម្អ ព្រមទាំងលើកជាសំណូមពរដល់ក្រសួងអប់រំ យុវជន និងកីឡា គណៈគ្រប់គ្រងសាលា ភាគីពាក់ព័ន្ធក្នុងគោលបំណងជានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ននិងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ជាពិសេសចូលរួមកាត់បន្ថយចំណាយទាំងផ្ទាល់និងប្រយោល។

# ជំពូកទី២

# រំឭកទ្រឹស្ដី

# ជំពូកទី២

# រំឭកទ្រឹស្តី

## ២.១- បញ្ញត្តិ និងទ្រឹស្តីពាក់ព័ន្ធនឹងមុខសញ្ញាចំណាយការសិក្សា

### ២.១.១- និយមន័យពាក្យគន្លឹះ

#### ២.១.១.ក- មុខសញ្ញាចំណាយ

មានអ្នកសិក្សាស្រាវជ្រាវជាច្រើនបានផ្តល់និយមន័យចំណាយផ្សេងៗគ្នា ដែលអ្នកប្រើប្រាស់អាចយកមកអនុវត្តតាមបរិបទដោយឡែកពីគ្នា។ ចំណាយគឺជាប្រតិបត្តិការ ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យថយចុះ។ ជាតុសំខាន់ៗនៃចំណាយរួមមាន៖ ចំណាយប្រាក់បៀវត្សនិងលាភការ ចំណាយប្រើប្រាស់ទំនិញនិងសេវាកម្ម ចំណាយលើការប្រាក់ ចំណាយលើការឧបត្ថម្ភធន ចំណោយលើអំណោយ ចំណាយលើឧបត្ថម្ភសង្គមកិច្ច និងចំណាយផ្សេងៗ (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ២០២១)។ ចំណាយ គឺជាការទូទាត់ឬការកើតឡើងនៃការទទួលខុសត្រូវជាថ្នូរនឹងទំនិញឬសេវាកម្មនានា (AccountingTools, 2022)។ ន័យស្រដៀងគ្នានេះដែរ ការចំណាយគឺជាសកម្មភាពនៃការប្រើប្រាស់ឬចំណាយលើថាមពល ពេលវេលា និងថវិកា ឬជាចំនួនទឹកប្រាក់សរុបដែលរដ្ឋាភិបាលឬបុគ្គលចំណាយ (Özkanca, Katia & Tim Carter, Goldstein, T. Kuru, 2022)។

ជារួមមក មុខសញ្ញាចំណាយ (Expenditures) ត្រង់ន័យនេះ សំដៅដល់ការចំណាយថវិការបស់មាតាបិតា អាណាព្យាបាលសម្រាប់ផ្គត់ផ្គង់ដោយផ្ទាល់ឬប្រយោលលើការសិក្សារបស់បុត្រធីតា។

#### ២.១.១.ខ- មធ្យមសិក្សាបឋមភូមិ

មធ្យមសិក្សាបឋមត្រូវបានកំណត់ដោយគិតត្រឹមតែថ្នាក់មធ្យមសិក្សាបឋមភូមិពីគ្រប់អនុវិទ្យាល័យ និងថ្នាក់មធ្យមសិក្សាបឋមភូមិពីវិទ្យាល័យទាំងអស់។ ចំនួនសាលារៀនមានថ្នាក់មធ្យមសិក្សាបឋមភូមិទាំងអស់១៧៧៧ (ក្រសួងអប់រំយុវជននិងកីឡា, ស្ថិតិនិងសូចនាករអប់រំសាធារណៈ២០២១-២០២២, ២០២២)។

មធ្យមសិក្សាបឋមភូមិ សំដៅដល់កម្រិតថ្នាក់ទី៧-៩ (NGO Education Partnership, 2007)។

## ២.១.២- ទ្រឹស្តីពាក់ព័ន្ធនឹងមុខសញ្ញាចំណាយការសិក្សា

យោងតាម តារាងហិរញ្ញវត្ថុស្តីពីចំណូលនិងចំណាយសម្រាប់សាធារណៈជននៃការអប់រំបឋមសិក្សា និងមធ្យមសិក្សារបស់មជ្ឈមណ្ឌលជាតិសម្រាប់ស្ថិតិអប់រំនៅIES បានបង្ហាញថាមុខងារនៃចំណាយលើការអប់រំរួមមាន៖ សេវាគាំទ្របុគ្គលិកបង្រៀន សេវាគាំទ្រសិស្ស រដ្ឋបាលទូទៅ ការគ្រប់គ្រងសាលារៀន ប្រតិបត្តិការនិងថែទាំ ការដឹកជញ្ជូនសិស្ស សេវាគាំទ្រផ្សេងៗ សេវាអាហារ និងការចំណាយជាក់ស្តែង (IES, 2020)។ ក្នុងន័យនេះ សំដៅដល់កញ្ចប់ចំណាយរបស់ជាតិសម្រាប់ការអប់រំជាមូលដ្ឋានដល់កុមារគ្រប់រូបទទួលបានឱកាសសិក្សារៀនសូត្រនៅឯសាលារៀន ប៉ុន្តែវាហាក់មិនទាន់បានគ្របដណ្តប់ទាំងស្រុងលើការចំណាយការសិក្សានៅឡើយ។ តួយ៉ាង យោងតាមលោក Bray(1999) សាលារៀនបានចាត់ទុកជាកន្លែងបណ្តុះបណ្តាលមនុស្សជំនាន់ក្រោយដើម្បីក្លាយជាធនធានបន្តវេនសម្រាប់ការអភិវឌ្ឍសង្គមជាតិ។ មានប្រទេសជាច្រើនបានបែងចែកសាលារៀនទៅជាសាធារណៈនិងឯកជន ប៉ុន្តែសាលារៀនទាំងនោះនៅតែមានទំនាក់ទំនងគ្នា ពោលសាលារៀនឯកជនទទួលបានធនធានសាធារណៈជាច្រើន ចំណែកឯសាលារៀនសាធារណៈក៏ទទួលបានធនធានឯកជនច្រើនផងដែរ។ នៅក្នុងប្រទេសកម្ពុជា សាលារៀនភាគច្រើនជាស្ថាប័នសាធារណៈដែលដំណើរការដោយរដ្ឋាភិបាល ប៉ុន្តែនៅក្នុងសាលារៀនស្ទើរតែទាំងអស់នៃផ្នែកហិរញ្ញវត្ថុបានមកពីគ្រួសារ សហគមន៍ និងប្រភពមិនមែនរដ្ឋាភិបាលផ្សេងទៀត។

យោងតាមលោក Micklewright (2000); Silova, Budiene, and Bray (2006) ការចំណាយលើវិស័យអប់រំសាធារណៈនៅប្រទេសភាគច្រើនក្នុងតំបន់បានធ្លាក់ចុះ ឯចំណាយឯកជនកាន់តែច្រើនស្ទើរគ្រប់ទីកន្លែងដូចជា៖ ថ្លៃសេវាសាលាឯកជន ការរួមចំណែករបស់សហគមន៍និងគ្រួសារសម្រាប់សាលារៀន (ការថែទាំង និងជួសជុលសាលារៀន) ការបង់ប្រាក់សម្រាប់សៀវភៅសិក្សា អាហារនៅសាលា និងសកម្មភាពក្រៅកម្មវិធីសិក្សា ការចំណាយលើតម្រូវការបន្ថែម (សម្លៀកបំពាក់ ស្បែកជើង និងការធ្វើដំណើរ) ការបង់ប្រាក់ក្រៅផ្លូវការនៅសាលារដ្ឋ អំណោយគ្រូ ការសូកប៉ាន់ដើម្បីទទួលបានលទ្ធផលប្រឡងល្អ (Lepisto and Kazimzade, 2008)។

យោងតាមលោក Bray and Seng (2005) បើផ្អែកតាមទស្សនៈតួនាទីរបស់រដ្ឋាភិបាលនិងការអប់រំជាសិទ្ធិមនុស្ស កុមារទាំងអស់គួរទទួលបានការអប់រំមូលដ្ឋានឱ្យបានកាន់តែច្រើននិងមានគុណភាពដោយឥតគិតថ្លៃ។ ប៉ុន្តែមានគំនិតគាំទ្រជាច្រើនមិនពិចារណារកការពិតថា ការចូលរៀនតែងមាននរណាម្នាក់ចំណាយ និងទទួលស្គាល់ថាប្រទេសដែលមានចំណូលទាប រដ្ឋាភិបាលជាច្រើនខ្វះខាតធនធានសម្រាប់ជានាសម្រេចសកលកម្មអប់រំឡើយ។ ប្រសិនបើផ្តល់ទំនិញ និងសេវាដោយឥតគិតថ្លៃនោះ អ្នកទិញឬអ្នកទទួលតែងតែមិនសូវឱ្យតម្លៃដល់ទំនិញឬសេវាទាំងនោះទេ។ ក្នុងស្ថានភាពជីវភាពនៃចំណូលប្រជាជនមិនស្មើគ្នា ដែលមានប្រជាពលរដ្ឋមួយចំនួនរកបានប្រាក់ចំណូលទាប ពិបាករកប្រាក់សម្រាប់ការចំណាយការសិក្សារបស់កូនៗ និងមានប្រជាពលរដ្ឋមួយចំនួនរកប្រាក់ចំណូលមធ្យមឬខ្ពស់ ហើយអាចចំណាយសម្រាប់ការរៀនសូត្ររបស់កូនៗបាន ដូចនេះ ការជួយផ្តល់ហិរញ្ញវត្ថុពិតជាសំខាន់ មិនត្រឹមតែជួយជំរុញឱ្យអ្នកប្រើប្រាស់ផ្តល់តម្លៃកាន់តែខ្ពស់ដល់សេវាប៉ុណ្ណោះទេ ថែមទាំងជួយកាត់បន្ថយតម្រូវការប្រើប្រាស់ធនធានរបស់រដ្ឋាភិបាល ជាពិសេសអាចជួយដល់ក្រុមដែលមានប្រាក់ចំណូលទាបផងដែរ។ ផ្ទុយពីទស្សនៈនេះ សេដ្ឋវិទូបានបង្ហាញពីភាពខុសគ្នារវាងចំណាយផ្ទាល់ និងចំណាយប្រយោលសម្រាប់ការរៀនសូត្រ។ ចំណាយផ្ទាល់រួមមានការចំណាយរបស់អ្នកផ្តល់ការអប់រំ និងការចំណាយផ្សេងៗរបស់គ្រួសារសិស្សទៅលើឯកសណ្ឋាន សៀវភៅ មធ្យោបាយធ្វើដំណើរនិងសម្ភារពាក់ព័ន្ធផ្សេងៗ។ ការចំណាយប្រយោល ជាតម្លៃនៃការលះបង់របស់សិស្ស ដើម្បីសាលារៀន។ ការចំណាយប្រយោលនេះជាបន្ទុកធ្ងន់ធ្ងរសម្រាប់គ្រួសារសិស្សមួយចំនួន ជាពិសេសគ្រួសារក្រីក្របំផុតអាចជាកត្តាសំខាន់ ក្នុងការសម្រេចចិត្តបញ្ជូនកូនទៅសាលាឬមិនបញ្ជូន។ មានក្រុមគ្រួសារមួយចំនួន បានធ្វើការប្រៀបធៀបរវាងផលប្រយោជន៍និងការខាតបង់ ដើម្បីដឹងថាការដែលពួកគេបញ្ជូនកូនទៅសិក្សានោះ មានប្រយោជន៍កម្រិតណា ហើយការចំណាយលើការសិក្សាមានសមតុល្យជាមួយនឹងចំណូលរបស់ពួកគេដែរឬទេ។ ក្នុងន័យនេះ ប្រសិនបើគ្មានតុល្យភាពសមស្របរវាងការចំណាយនិងចំណូលនោះទេ នោះវានឹងមានបញ្ហាលើការសម្រេចចិត្តរបស់មាតាបិតា អាណាព្យាបាលដូចគ្នា។ រដ្ឋាភិបាលមួយចំនួនកំណត់ទម្រង់នៃការចូលរួមចំណែករបស់គ្រួសារ ហើយមានការចូលរួមពីអាជ្ញាធរ និងទុកឱ្យអ្នកប្រើប្រាស់រកវិធីផ្សេងៗដើម្បីបំពេញចន្លោះខ្វះខាត ឬអ្នក

បង្កើតគោលនយោបាយរៀបចំយុទ្ធសាស្ត្រជាក់លាក់ពីលទ្ធភាពដែលអាចធ្វើបាន និងអ្នកចូលរួមលើចំណុចខាតខាតដើម្បីបំពេញបន្ថែម ដែលអាចជួយបានច្រើន ជាពិសេសសម្រួលដល់បន្ទុកគ្រួសារក្រីក្រផ្ទុយទៅវិញ ប្រសិនបើមិនមានការអន្តរាគមន៍ ការសម្រេចចិត្តរបស់មានតាបិតាសិស្សនឹងមានទំនោរលើការចំណាយផ្សេងៗ ជាងការចំណាយលើការអប់រំផងដែរ ។

យោងតាមលោក Bray and Seng (2005) លើកឡើងថានៅប្រទេសឧស្សាហកម្មជឿនលឿនមួយចំនួន ការចំណាយក្នុងសាលារៀនទាំងអស់ និងការចំណាយក្រៅសាលារៀនដូចជា ឯកសណ្ឋានមធ្យោបាយធ្វើដំណើរ ជាបន្ទុករបស់រដ្ឋាភិបាល។ រីឯបណ្តាប្រទេសផ្សេងទៀត រួមមានកម្ពុជាផងដែរគឺបន្ទុកនៃការចំណាយរបស់គ្រួសារសិស្សមានចំនួនច្រើនរហូតដល់ជាងពាក់កណ្តាល នៃការចំណាយសរុបលើការអប់រំសាធារណៈ ដែលចំណាយកម្រិតខ្ពស់នោះកើតឡើងក្នុងប្រទេសនៅតំបន់អាស៊ីផ្សេងទៀតដូចជា ប្រទេសភូមា (Mehrotra & Delamonica, 1998) ប្រទេសវៀតណាម (Truong et al. 1999) និងផ្នែកខ្លះទៀតនៃប្រទេសចិន (Bray et al. 2004) និងមានបញ្ហាប្រហាក់ប្រហែលគ្នានៅអាហ្វ្រិក និងប្រទេសផ្សេងទៀតក្នុងពិភពលោកផងដែរ (See e.g Colclough et al. 2003) ។ មានមតិគាំទ្រមួយចំនួនបានលើកឡើងពីការផ្តល់ហិរញ្ញប្បទានរបស់គ្រួសារ ប៉ុន្តែត្រូវបានមតិបដិសេធយល់ថាការធ្វើបែបនេះនឹងមានវិសមភាពកាន់តែធ្ងន់ធ្ងរ ខណៈពេលដែលគ្រួសារសិស្សខ្លះមានលទ្ធភាពហើយគ្រួសារសិស្សខ្លះទៀតមិនមានលទ្ធភាព។ ការចំណាយលើការអប់រំក្នុងប្រព័ន្ធកាន់តែខ្ពស់ ជាដើមចមដែលធ្វើឱ្យអត្រានៃការបោះបង់ការសិក្សាកើនឡើង។ អ្នកវិភាគគាំទ្រលើការធ្វើហិរញ្ញប្បទានរបស់គ្រួសារសម្រាប់ការអប់រំទទួលស្គាល់នូវចំណុចទាំងនេះ ប៉ុន្តែគុណសម្បត្តិនៃការធ្វើហិរញ្ញប្បទានមានច្រើនជាងគុណវិបត្តិ។ គ្រួសារសិស្សនិងសហគមន៍មានសិទ្ធិសម្រេចក្នុងការចំណាយប្រាក់ទៅលើការអប់រំ ដូចជាការចំណាយទៅលើផ្ទះសម្លៀកបំពាក់ អាហារ និងទំនិញផ្សេងៗ ហើយការណ៍នេះ វាបានជួយដល់សង្គមទាំងមូល។ នៅអំឡុង ៤ ទសវត្សដំបូង មុនសង្គ្រាមលោកលើកទី២ ទស្សនៈអន្តរជាតិដែលលេចធ្លោជាងគេគឺការអប់រំ គួរតែធ្វើឡើងដោយឥតគិតថ្លៃ ជាពិសេសការអប់រំមូលដ្ឋាន។ ទោះបីជាយ៉ាងណាក្តី នាពេលបច្ចុប្បន្ននេះ ការទទួលស្គាល់កាន់តែច្រើនឡើងនូវទស្សនៈ នៃការបែងចែកការចំណាយដែលដើរស្របគ្នាជាមួយនឹងការអនុវត្ត

ជាក់ស្តែង ជាពិសេសប្រទេសប្រទេសក្រីក្របានទាមទារឱ្យមានការចូលរួមវិភាគទានពីគ្រួសារសិស្សនិងសហគមន៍ជាច់ខាត។ យោងតាមរបាយការណ៍របស់សន្និសីទ(WCEFA 1999a, p.7) បានសង្កត់ធ្ងន់ពីសារៈសំខាន់នៃភាពជាដៃគូដែលត្រូវការចាំបាច់រវាងរដ្ឋាភិបាលជាមួយអង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន សហគមន៍មូលដ្ឋាន ក្រុមសាសនា និងគ្រួសារសិស្សផងដែរ។ សូម្បីរដ្ឋាភិបាលប្រទេសសិង្ហបុរីដែលមានលទ្ធភាពក្នុងការផ្តល់ការអប់រំយ៉ាងល្អដល់ពលរដ្ឋខ្លួន ក៏នៅតែលើកទឹកចិត្តឱ្យមានការចូលរួមវិភាគទានពីគ្រួសារសិស្សនិងសហគមន៍ផងដែរ។ តួយ៉ាង ក្នុងឆ្នាំ១៩៩៨ រដ្ឋាភិបាលបានបង្កើតនូវគម្រោងមួយដែលហៅកាត់ថា COMPASS គ្រាំទ្រសាលារៀនដោយសហគមន៍និងមាតាបិតាសិស្ស (Manzon, 2004) ដែលនេះជាការប្តេជ្ញាចិត្ត ក្នុងការកសាងនិងលើកកម្ពស់ភាពជាដៃគូរដើម្បីឱ្យដំណើរការអប់រំកាន់តែមានប្រសិទ្ធភាព។ តាមរយៈលោក Jimenez និង Paqueo (1996) បង្ហាញក្នុងប្រទេសហ្វីលីពីន និងតាមរយៈលោក James និងសហការី (1996)ក៏បានបង្ហាញការចូលរួមពីគ្រួសារសិស្សនិងសហគមន៍កើតឡើងប្រទេសឥណ្ឌូនេស៊ី ហើយក៏ប្រហែលជាអាចរកឃើញក្នុងប្រទេសកម្ពុជាដែរ។ ក្នុងប្រព័ន្ធអប់រំភាគច្រើន ចំណូលសាលារៀនបានមកពីការបង់ថ្លៃសាលារៀនរបស់សិស្ស និងមានពេលខ្លះប្រាក់នោះក៏អាចជាប្រាក់បង់ថ្លៃសៀវភៅ ការជួសជុល ថ្លៃសម្រាប់សកម្មភាពបន្ថែមនៅក្នុងសាលា ហើយមានពេលខ្លះសាលាលើកលែងថ្លៃទាំងនោះ ចំពោះគ្រួសារក្រីក្រ ឬបញ្ចុះថ្លៃចំណាយប្រភេទនេះសម្រាប់គ្រួសារដែលមានកូនលើសពីម្នាក់។ តាមរយៈ Urwick (2002, p.141) បានលើកឡើងថា នៅប្រទេសនីហ្សេរីយ៉ាជាទូទៅប្រាក់បង់ថ្លៃសាលាអាចចរចាគ្នាបាន។ មកដល់ឆ្នាំ២០០៤ ការបង់ប្រាក់របស់គ្រួសារសិស្ស ត្រូវបានកាត់បន្ថយដោយសារតែគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាល។ ដោយឡែក ការចំណាយក្រៅសាលាវិញ សាលារៀនជាច្រើនលើពិភពលោក តម្រូវឱ្យគ្រួសារទិញឯកសណ្ឋាន ហើយគ្រួសារមួយចំនួនត្រូវចំណាយថ្លៃអាហារនៅសាលា។ កុមារត្រូវការសម្លៀកបំពាក់ និងអាហារ ហើយឯកសណ្ឋានសិស្សមួយចំនួនទៀតសោតក៏មានតម្លៃថ្លៃជាងសម្លៀកបំពាក់ធម្មតា ជាពិសេសនៅពេលដែលឯកសណ្ឋានសិស្សតម្រូវឱ្យមានទាំងស្បែកជើង និងសម្ភារៈពិសេសផ្សេងទៀតដូចជាឧបករណ៍កីឡា។ ឯអាហារនៅសាលាក៏មានតម្លៃថ្លៃជាងអាហារនៅផ្ទះដែរ ប៉ុន្តែមិនមែនគ្រប់ករណីទាំងអស់នោះទេ។ ក្រៅពីនោះ ប្រាក់ចាយប្រចាំ

ថ្ងៃសម្រាប់ទិញនំចំណីនៅសាលារៀន មធ្យោបាយធ្វើដំណើរ ក៏ត្រូវបានចាត់ទុកជាការចំណាយសម្រាប់ការអប់រំផងដែរ។ ជាទូទៅប្រាក់ចាយប្រចាំថ្ងៃរបស់សិស្ស និងមធ្យោបាយធ្វើដំណើរ នៅមធ្យមសិក្សាមានចំនួនច្រើនជាងការចំណាយនៅបឋមសិក្សា ដោយមូលហេតុទី១ នៅពេលកុមារកាន់តែធំ ត្រូវការញ៉ាំនំចំណី និងប្រាក់ចាយប្រចាំថ្ងៃកាន់តែច្រើន ទី២ សាលាមធ្យមសិក្សានៅឆ្ងាយពីផ្ទះសិស្សជាងសាលាបឋមសិក្សា។ ការចំណាយដ៏ចម្បងមួយទៀតនៅប្រទេសកម្ពុជា ក៏ដូចជាបណ្ដាប្រទេសផ្សេងទៀត ជាការចំណាយទៅលើការរៀនគួរ។ នៅប្រទេសភាគច្រើន ការចំណាយបែបនេះត្រូវបានចាត់ទុកថាជាការចំណាយក្រៅសាលារៀន ដោយសារការរៀនគួរបន្ថែម ត្រូវធ្វើនៅកន្លែងណាមួយ ឬនៅផ្ទះគ្រូឬផ្ទះសិស្ស ផ្ទុយពីប្រទេសកម្ពុជាដែលភាគច្រើន ការរៀនគួរគឺធ្វើឡើងនៅក្រោយពេលរៀនចប់ថ្នាក់ចំនេះទូទៅក្នុងម៉ោងរដ្ឋគ្រូចាប់ផ្ដើមបង្រៀនក្រៅម៉ោងត្រូវបានធ្វើនៅសាលារៀនដែលកូនសិស្សរៀនតែម្ដង (See e.g. Bray 1999b, 2003a; Foondun 2002; Yoo 2002; Kwok 2004)។

## ២.២- សមាសភាពនៃចំណាយលើការសិក្សា

យោងតាមរបាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានបង្ហាញថាចំនួនទឹកប្រាក់ដែលបានចំណាយសម្រាប់ការសិក្សាអប់រំ ក្នុងអំឡុងពេលនៃឆ្នាំសិក្សាកន្លងមកសម្រាប់សមាជិកគ្រួសារនីមួយៗ ដែលបានចូលរៀនក្នុងប្រព័ន្ធអប់រំផ្លូវការ ការរៀនបន្ថែមជាលក្ខណៈឯកជនក្រៅម៉ោងក្រោយពេលចេញពីសាលា ឬក៏ការសិក្សាថ្នាក់ក្រៅប្រព័ន្ធ ត្រូវបានកត់ត្រាដាច់ដោយឡែកពីគ្នា។ ការចំណាយសរុបរួមមាន៧ប្រភេទដូចជា៖ ចំណាយថ្លៃសាលា ចំណាយថ្លៃគ្រូបង្រៀន ចំណាយថ្លៃសៀវភៅសិក្សា ចំណាយសម្ភារៈសិក្សាផ្សេងៗ ចំណាយលើការសិក្សាក្មេងដែលទៅសិក្សាឆ្ងាយពីផ្ទះ ការចំណាយថ្លៃធ្វើដំណើរ និងអំណោយជូនគ្រូ ប្រាក់វិភាគទានបង់សម្រាប់សាងសង់អគារ/ការអភិវឌ្ឍ (ក្រសួងផែនការ, ២០២០)។

តាមការស្រាវជ្រាវរបស់លោក Bray (1999) បានបែងចែកការចំណាយសំខាន់ៗលើការសិក្សារបស់សិស្សរួមមាន៖ ការរួមចំណែករបស់សាលា ចំណាយផ្ទាល់ខ្លួន ការចុះឈ្មោះចូលរៀន ការថែទាំ

សាលា ឯកសណ្ឋាន សម្ភារៈសាលាផ្សេងៗ ការបង្រៀនឯកជន ការធ្វើដំណើរ លុយហោប៉ៅ សម្ភារៈការិយាល័យ អំណោយជូនគ្រូជាដើម។

រីឯអ្នកស្រាវជ្រាវផ្សេងទៀត បានបែងចែកការចំណាយរួមមាន៖ ការចំណាយដោយផ្ទាល់ សំដៅលើចំណាយក្នុងគ្រួសាររបស់កុមារ ដូចជា ថ្លៃសាលា សៀវភៅ សម្ភារៈសិក្សា ឯកសណ្ឋាន និងការធ្វើដំណើរ។ ការចំណាយដោយប្រយោល សំដៅទៅលើការចំណាយលើអាហារ កន្លែងស្នាក់នៅ សម្លៀកបំពាក់ និងការចំណាយលើការបោះបង់ចំណូល (waiving costs) សំដៅលើបុគ្គលដែលបានបោះបង់ការរកប្រាក់ចំណូលដោយចូលរៀននៅគ្រឹះស្ថានអប់រំ ជាជាងការធ្វើការក្នុងការងារដែលគាត់អាចរកប្រាក់ចំណូលបានដោយការមានសកម្មភាពសេដ្ឋកិច្ច (Yolcu, 2011)។

ដោយឡែក បើយោងតាមការស្រាវជ្រាវរបស់ស្ថាប័ន ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP, 2007) បានរកឃើញថា ការចំណាយលើការសិក្សាអប់រំអាចបែងចែកជា៤ផ្នែករួមមាន៖

1. ការចំណាយប្រចាំថ្ងៃ៖ ជាចំណាយដែលសិស្សបានទូទាត់ជាប្រចាំដូចជា៖
   - ថ្លៃអាហារ
   - ថ្លៃចំណតរថយន្ត
2. ការចំណាយថ្លៃសាលារៀន៖ ផ្នែកនេះ សិស្សានុសិស្សបានចំណាយលើការសិក្សានៅសាលារៀនដូចជា៖
   - ថ្លៃគ្រូបង្រៀន
   - ថ្លៃបង្រៀនឯកជន
   - ឯកសារបង្រៀន
   - ឯកសារប្រឡង
3. ការចំណាយដើមឆ្នាំសិក្សា៖ សិស្សគ្រប់បានចំណាយនៅដើមឆ្នាំសិក្សានីមួយៗ ដូចជា៖
   - ឯកសណ្ឋានសាលា៖ ឯកសណ្ឋានសាលាប្រចាំថ្ងៃ សម្លៀកបំពាក់កីឡា និងស្បែកជើង

- សម្ភារៈសិក្សា៖ កាបូប សៀវភៅសរសេរ គម្របសៀវភៅ និងសម្ភារៈ/ឧបករណ៍ប្រើប្រាស់ផ្សេងៗទៀត
- ថ្លៃចុះឈ្មោះចូលរៀន៖ ទម្រង់ពាក្យសុំចុះឈ្មោះចូលរៀន រូបថត សៀវភៅកត់ត្រា ថ្លៃកីឡា និងចំណាយផ្សេងៗ

4. ការចំណាយបន្ថែម៖ មុខសញ្ញាចំណាយនៅត្រង់ផ្នែកនេះ គឺផ្តោតលើ៖
   - ការផ្គត់ផ្គង់សម្ភារៈសិក្សា
   - ការផ្គត់ផ្គង់ថ្នាក់រៀន
   - ការជួសជុលកង់/ម៉ូតូ
   - អំណោយគ្រូ
   - ការរៀបចំកម្មវិធី...។

## ២.៣ បញ្ហាប្រឈមនៃចំណាយការសិក្សា

### ២.៣.១ បញ្ហាប្រឈមនៃចំណាយការសិក្សាក្នុងក្របខណ្ឌជាតិ

យោងតាម Silova and Bray (2006) ការចំណាយនានាក្នុងវិស័យអប់រំត្រូវពឹងផ្អែកលើសេដ្ឋកិច្ចក្នុងប្រទេស វាអាចនឹងមានការពិបាក ប្រសិនបើសេដ្ឋកិច្ចសង្គមមានការប្រែប្រួលដោយជួបនូវវិបត្តិ។ ការធ្លាក់ចុះនៃសេដ្ឋកិច្ចបានជះឥទ្ធិពលដោយផ្ទាល់ទៅលើការចំណាយវិស័យអប់រំទូទាំងប្រទេស។ តួយ៉ាងនៅចុងសតវត្សរ៍ ឆ្នាំ២០០០ ការចំណាយការអប់រំជាភាគរយនៃផលិតផលក្នុងស្រុកសរុបបានប្រែប្រួលយ៉ាងខ្លាំងនៅទូទាំងតំបន់ ដោយប្រទេសភាគច្រើនក្នុងការសិក្សាចំណាយប្រហែល៤-៦% នៃផលិតផលក្នុងស្រុក(OECD) ខណៈដែលAzerbaijan, Georgia , Kazakhstan បានចំណាយក្រោម៣% នៃGDP (UNESCO Institute for Statistics 2009)។ បើក្រឡេកមកមើលបរិបទកម្ពុជាក្នុងឆ្នាំកន្លងថ្មីៗនេះ រាជរដ្ឋាភិបាលបានបង្កើនចំណាយសម្រាប់វិស័យអប់រំជារៀងរាល់ឆ្នាំរហូតដល់៨២៧,៣៧ លានដុល្លារក្នុងឆ្នាំសិក្សា ២០១៩-២០២០ បើធៀបនឹងឆ្នាំសិក្សា ២០១៤-២០១៥ ថវិកាកើនឡើង២,៥ដង។ ប៉ុន្តែដោយសារជំងឺកូវីដ១៩បានបង្កផលប៉ះពាល់យ៉ាងច្រើនមកលើនិន្នាការនេះ ហើយវាទំនងនឹងបន្តផលប៉ះ

ពាល់ដល់សេដ្ឋកិច្ចកម្ពុជា និងចំណាយលើវិស័យអប់រំ ជាពិសេសនៅក្នុងឆ្នាំ២០២១-២០២៣ (ក្រសួងអប់រំយុវជននិងកីឡា, 2021)។ ព្រឹត្តការណ៍សហគមន៍ ២០ កុម្ភៈ ២០២១ បង្កឱ្យមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់ សុខភាព សង្គម សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ (អគ្គនាយកដ្ឋានពន្ធដារ, ២០២២)។ ដោយឡែក ការចំណាយលើវិស័យអប់រំក្នុងប្រទេសកំពុងអភិវឌ្ឍមួយចំនួន នឹងមានការថយចុះរហូត១០% ក្រោយការស្តារឡើងវិញពីការរាតត្បាតជាសកលនេះ (Al-Samarrai, 2020)។ ហើយការកាត់បន្ថយប្រាក់ចំណូល ដើម្បីបំពេញតម្រូវការសម្រាប់ការចំណាយផ្នែកសុខភាពកាន់តែច្រើន នឹងធ្វើឱ្យគ្រួសារមួយចំនួនមានការលំបាកក្នុងការចំណាយលើការអប់រំ។

យោងតាមផែនទីបង្ហាញផ្លូវ ការអប់រំមធ្យមសិក្សាកម្ពុជាឆ្នាំ២០៣០ នៃក្រសួងអប់រំ យុវជននិងកីឡា (២០២១)បានបង្ហាញថា រដ្ឋាភិបាលកម្ពុជា បានផ្តើមកាត់បន្ថយចំណាយរហូតដល់៥០% ដើម្បីផ្តល់មូលនិធិទ្រទ្រង់វិស័យសំខាន់ៗដូចជា៖ វិស័យអប់រំ និងសុខាភិបាល។ ជំនួយសម្រាប់វិស័យអប់រំដែលបានពីដៃគូអភិវឌ្ឍន៍និងអង្គការមិនមែនរដ្ឋាភិបាលក៏ទំនងមានការថយចុះផងដែរ មានន័យថាសេវាចាំបាច់សំខាន់ៗមួយចំនួននឹងរងផលប៉ះពាល់អវិជ្ជមាន ក្នុងករណីដែលរដ្ឋាភិបាលពុំអាចទទួលរ៉ាប់រងកង្វះថវិកានេះបាន។ ការថយចុះនូវចំណូលគ្រួសារ នឹងធ្វើឱ្យប្រជាពលរដ្ឋជាច្រើនគ្រួសារជួបការលំបាកក្នុងការរ៉ាប់រងចំណាយសេវាអប់រំ។ ចំណាយទាំងនេះ ស្រូបយកថវិកាគ្រួសារនៅក្នុងប្រទេសដែលមានចំណូលទាបក្នុងភាគរយមួយខ្ពស់ជាងអ្នកដែលរស់នៅក្នុងប្រទេសដែលមានចំណូលខ្ពស់។

ប្រភពចំណូលដ៏យូរអង្វែងរបស់រដ្ឋាភិបាលគឺការប្រមូលពន្ធ។ ប្រព័ន្ធពន្ធដារត្រូវបានកែលំអច្រើន ប៉ុន្តែការប្រមូលពន្ធដើម្បីឆ្លើយតបនឹងតម្រូវការសេវាសាធារណៈ និងភារកិច្ចរបស់រដ្ឋាភិបាលមិនអាចធ្វើបាននៅរយៈពេលខ្លីទេ។ ក្នុងប្រព័ន្ធអប់រំ តម្រូវការឱ្យមានការកែលំអគុណភាពនៅគ្រប់ភូមិសិក្សា និងមានការពង្រីកនៅមធ្យមសិក្សា និងឧត្តមសិក្សាដែលទាំងនេះជាតម្រូវការដែលរដ្ឋាភិបាលត្រូវឆ្លើយតប បន្ថែមលើវិស័យសេដ្ឋកិច្ច សង្គមនិងវិស័យដទៃទៀត។ ដូចនេះ ប្រភពធនធានរបស់រដ្ឋាភិបាលនឹងនៅតែមានការខ្វះខាត (នាយកដ្ឋានបណ្តុះបណ្តាលនិងស្រាវជ្រាវ, ២០០៩)។

ពិនិត្យលើទឡ្ហីករណ៍ខាងលើនេះបង្ហាញថា ស្ថានភាពសេដ្ឋកិច្ចទាបបានរងផលប៉ះពាល់ដល់សង្គម និងគ្រួសារ ហើយនាំយកបញ្ហាអាកប្បកិរិយាដែលជះឥទ្ធិពលដល់ការសិក្សារបស់កុមារថែមទៀត។ ក្នុងន័យនេះ បញ្ហាប្រឈមនៃសង្គមសេដ្ឋកិច្ចធ្លាក់ក្នុងវិបត្តិមិនមែនជាមូលហេតុតែមួយ ដែលធ្វើឱ្យរដ្ឋាភិបាលមិនមានលទ្ធភាពនោះទេ ប៉ុន្តែពេលខ្លះទោះស្ថិតក្នុងស្ថានភាពល្អប្រសើរហើយក៏ដោយ ក៏ប្រទេសមួយចំនួនពិសេសប្រទេសក្រីក្រ និងប្រទេសកំពុងអភិវឌ្ឍនៅតែជួបបញ្ហាលើចំណាយការចំណាយវិស័យអប់រំសាធារណៈផងដែរ ពោលភាពខ្វះខាតនេះរងគ្រោះដោយសារភាពគ្មានសមតុល្យរវាងចំណូល និងការចំណាយជាតិ ឬបញ្ហាផ្សេងៗ។

### ២.៣.២ បញ្ហាប្រឈមនៃការចំណាយការសិក្សាក្នុងគ្រួសារ

យោងតាម (Lvailo, L., Huot, C., Sodeth, L., Paavo, E., Timothy, J., Emre, O., Suhas, P., Leah, A., ២០១១) ចំណាយផ្ទាល់របស់គ្រួសារចំពោះការអប់រំមានទំហំធំ ហើយចំណាយដ៏ច្រើននេះមានបន្ទុកធ្ងន់មកលើគ្រួសារ។ ឪពុកម្តាយឬអាណាព្យាបាលបានចំណាយពេលវេលាច្រើនលើសលប់ទៅលើការរកចំណូលផ្គត់ផ្គង់គ្រួសារ ពួកគាត់មានពេលតិចតួចបំផុតសម្រាប់មើលថែបីបាច់កូនៗរបស់គាត់។ គួបផ្សំនឹងការយល់ដឹងរបស់ពួកគាត់នៅមានកម្រិតផងនោះ ម្ល៉ោះហើយគ្រួសាររបស់គាត់កាន់តែមានលទ្ធភាពតិចតួចក្នុងការការពារកុមារពីហានិភ័យ បញ្ជូនកូនៗទៅសាលាជាប្រចាំ ធានាឱ្យពួកគេទទួលបានអាហារប្រកបដោយជីវជាតិ និងសេវាចាំបាច់ផ្សេងៗទៀត។ ឧបសគ្គសំខាន់ៗដែលរាំងស្ទះដល់ការទទួលបានការអប់រំ និងកិច្ចការពារកុមារក្នុងសាលារៀន រួមមានការបង្រៀនមានគុណភាពទាប ការដាក់ទណ្ឌកម្មលើរូបរាងកាយ ការសំឡុត គំរាមគំហែង និងការខ្វះខាតសម្ភាររូបវន្តសម្រាប់បំពេញតម្រូវការរបស់កុមារពិការ ភាពក្រីក្រ និងភាពចាំបាច់ក្នុងការបង់ប្រាក់ក្រៅផ្លូវការដែលក្នុងនោះមានចំនួន៥៣% ត្រូវបានចំណាយលើគ្រូបង្រៀន (Unicef, 2018)។

ចំពោះក្រុមគ្រួសារដែលមានស្ថានភាពលំបាក ចំណូលទាបជាបញ្ហារាំងដល់ការចូលរួមលើការអប់រំរបស់កូនៗ និងបានជះឥទ្ធិពលអវិជ្ជមានលើលទ្ធផលសិក្សាផងដែរ។ គ្រួសារទាំងអស់ មិនមែនសុទ្ធតែមានលទ្ធភាពនិងការសម្រេចចិត្តក្នុងការបញ្ជូនកូនទៅសាលារៀនដូចគ្នានោះទេ។ ការអប់រំរបស់កុមារគឺត្រូវ

បានពឹងផ្អែកលើស្ថានភាពសេដ្ឋកិច្ចគ្រួសារនីមួយៗ ពេលគ្រួសារដែលមានចំណូលទាបគឺពិបាកក្នុងជំរុញកូនៗឱ្យទទួលបានការអប់រំនៅសាលាល្អៗ ឬបន្តការសិក្សាខ្ពស់នោះឡើយ (Lin,T., & Lv, H., 2017)។

យោងតាម (Samarrai, ២០២០) ជំងឺរាតត្បាត COVID-19 បានធ្វើឱ្យប៉ះពាល់ដល់សុខភាពនិងប្រាក់ចំណូលគ្រួសារជាច្រើនជាពិសេសគ្រួសារក្រីក្រ ដែលការធ្លាក់ចុះនៃប្រាក់ចំណូលគ្រួសារនិងកាត់បន្ថយការវិនិយោគនានា រួមទាំងក្នុងវិស័យអប់រំផងដែរ។ នៅទូទាំងពិភពលោក ២០% នៃការចំណាយលើការសិក្សាត្រូវបានរ៉ាប់រងដោយគ្រួសារ។ ការចំណាយរបស់គ្រួសារលើការអប់រំក្នុងប្រទេសដែលមានប្រាក់ចំណូលទាបគឺ២៩ភាគរយ ចំណែកឯប្រទេសដែលមានប្រាក់ចំណូលខ្ពស់គឺ១៨%។ ការចំណាយរបស់គ្រួសារលើការអប់រំក្នុងប្រទេសខ្លះ៦៧% ដូចជាប្រទេសកម្ពុជា ៥៩% អ៊ូហ្គង់ដា៥៤% ហ្គាតេម៉ាឡា៤៩% ប៉េរូ ៣០% វៀតណាម៣០% ទួរគី១៤% អង់គ្លេស១២% អ៊ីតាលី ១២.៨% កាណាដា៨% ស្វីស៥% បែលហ្ស៊ិក និងដាណឺម៉ាក៤% លុចសំបួរ១% អូទ្រីសនិងគុយបា១% ហ្វូឡង់និងស៊ុយអែត០%។ ទិន្នន័យបង្ហាញថា ការចំណាយលើការសិក្សារបស់គ្រួសារក្នុងប្រទេសដែលមានចំណូលខ្ពស់គឺការចំណាយមានកម្រិតទាប។ ដូចនេះ អាចបកស្រាយបានថា ប្រទេសដែលមានចំណូលទាបនិងមធ្យមត្រូវបានចំណាយលើការសិក្សាទាប និងមានបន្ទុកគ្រួសារខ្ពស់។ ដោយកម្រិតនៃប្រាក់ចំណូលរបស់គ្រួសារនៅក្នុងប្រទេសដែលមានកម្រិតទាបនិងមធ្យម ប្រាកដណាស់ថាគ្រួសារនីមួយៗនឹងពិចារណាលើការចំណាយផ្សេងៗដើម្បីឆ្លើយតបនឹងការចំណាយលើការសិក្សារបស់ពួកគេ (Selda and Ozturk, 2021)។

## ២.៤ កម្រិតនៃការចូលរួមលើចំណាយការសិក្សារបស់សិស្ស

យោងតាមច្បាប់ស្តីពីការអប់រំ (២០០៧) មាត្រា៤៤ ការចូលរួម ការកៀរគរ និងគ្រប់គ្រងធនធានសម្រាប់ការអប់រំគឺៈ បុគ្គលបុព្វជិត គ្រួសារ សហគមន៍ អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នរដ្ឋ និងឯកជនទាំងអស់ មានសិទ្ធិចូលរួម និងផ្តល់ធនធានយ៉ាងពេញលេញទាំងធនធានមនុស្សទាំងសម្ភារៈ ឬថវិកា ក្នុងគោលបំណងដើម្បីគាំទ្រ និងអភិវឌ្ឍវិស័យអប់រំ។ យោងតាម នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ (២០០៩) សាលារៀនជាកន្លែងសម្រាប់អប់រំ និងបណ្តុះបណ្តាលមនុស្សគ្រប់វ័យនៅក្នុងសហគមន៍ដើម្បីអភិវឌ្ឍបុគ្គលិកលក្ខណៈបុគ្គល គ្រួសារ សហគមន៍ និងសង្គម។ ដំណើរ

ការសាលារៀនល្អ សិស្សបានរៀនសូត្រ មានចំណេះដឹង មានសីលធម៌ ក្លាយជាមនុស្សល្អពេញលេញអាចជួយគ្រួសារ បម្រើសហគមន៍និងប្រទេសជាតិ។ ទន្ទឹមនឹងនេះ ដើម្បីគាំទ្រដល់ដំណើរការសាលារៀន និងជំរុញការសិក្សារបស់សិស្សគឺត្រូវការផ្សារភ្ជាប់ទំនាក់ទំនងនិងការចូលរួមពីសហគមន៍ជាតិ និងសហគមន៍អន្តរជាតិ។ សហគមន៍ជាតិសំដៅដល់ គណៈគ្រប់គ្រងសាលា គ្រូបង្រៀន បុគ្គលិក កម្មករ សិស្សានុសិស្ស មាតាបិតាសិស្ស គណៈកម្មការទ្រទ្រង់សាលារៀន សមាគមជាតិ ប្រជាជនទូទៅ អាជ្ញាធរដែនដី រដ្ឋអំណាចភូមិ ឃុំ ស្រុក រាជធានី ខេត្ត ព្រះសង្ឃ អាចារ្យវត្ត ដូនជី ទាហាន ប៉ូលីស កងរាជអាវុធហត្ថ មន្ត្រីរាជការក្នុងស្ថាប័នផ្សេងៗ។ សហគមន៍អន្តរជាតិ សំដៅដល់ ទីភ្នាក់ងារផ្តល់ជំនួនជាពហុភាគីដល់ប្រព័ន្ធអប់រំ អ្នកផ្តល់ជំនួយទ្វេភាគី ការផ្តល់ជំនួយតាមរយៈអង្គការក្រៅរដ្ឋាភិបាល។ សរុបជារួមមក ការចូលរួមចំណែកពីតួអង្គសំខាន់ៗទាំងនេះលើកិច្ចដំណើរការសាលារៀន មានន័យថាជាការចូលរួមដ៏ច្រើនលើការសិក្សារបស់សិស្សទាំងការចំណាយផ្ទាល់និងចំណាយប្រយោល។

យោងតាមលោក Bray (1999) ប្រភពចំណាយសំខាន់ៗលើការសិក្សារបស់សិស្សបានកើតឡើងពីរដ្ឋាភិបាល អ្នកនយោបាយ អង្គការក្រៅរដ្ឋាភិបាល និងភ្នាក់ងារជំនួយខាងក្រៅ គ្រួសារនិងសហគមន៍សាលារៀនតាមរយៈប្រាក់ចំណូលផ្ទាល់ខ្លួនឬការកៀរគរសប្បុរសជន។

### ២.៤.១- ការចូលរួមពីរដ្ឋាភិបាល

រាជរដ្ឋាភិបាល បានខិតខំប្រឹងប្រែងក្នុងការរៀបចំគោលនយោបាយជាតិជាច្រើនក្នុងគោលបំណងរុញច្រានសេដ្ឋកិច្ចជាតិឆ្ពោះទៅមុខជានិច្ច។ តួយ៉ាង ក្របខណ្ឌគោលនយោបាយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចឱ្យបានចក្ខុវិស័យឆ្នាំ២០៥០ របស់រដ្ឋាភិបាលកម្ពុជានិងពាំនាំមកនូវភាពរុងរឿង សាមគ្គីភាព ចំណេះដឹងខ្ពស់ភាពរីកចម្រើន និងវប្បធម៌រស់រវើក ភាពគ្មានភាពក្រីក្រដោយប្រជាជនកម្ពុជាទាំងអស់រស់នៅក្នុងភាពសុខដុមរមនា (រាជរដ្ឋាភិបាលកម្ពុជា, ២០១៨)។

យោងតាមច្បាប់ស្តីពីការអប់រំ (២០០៧) រដ្ឋត្រូវជំរុញនិងផ្តល់ការលើកទឹកចិត្តចំពោះសប្បុរសជនតាមភាពសមស្របនិងចាំបាច់ដោយទទួលស្គាល់ការអប់រំជាការវិនិយោគមួយដ៏ល្អបំផុត។

យោងតាម NEP (2015) រដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការរៀបចំផែនការសកម្មភាពក្នុងគោលបំណងជំរុញវិស័យអប់រំ ដោយបានបានកំណត់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជាទីពីរគឺដើម្បីសម្រេចបាននូវការអប់រំជាមូលដ្ឋានរយៈពេល៩ឆ្នាំ ឆ្នាំ២០១៥។ ក្នុងនោះឃើញមានឯកសារគោលនយោបាយអប់រំសំខាន់ៗចំនួនបីគឺ៖ EFA ESP ESSP បញ្ជាក់បានពីចេតនារបស់រដ្ឋាភិបាលដើម្បីសម្រេចបានគោលដៅមួយនេះផងដែរ។ ចំពោះរាជរដ្ឋាភិបាលត្រូវបានចំណាយសំខាន់ៗលើគ្រូបង្រៀន ផ្ទុយពីស្ថានភាពប្រទេសបង់ក្លាដែស ចិន និងប្រទេសម៉ាឡាវី ដែលចំនួនគ្រូបង្រៀនជាច្រើនត្រូវបានជួលដោយសហគមន៍មូលដ្ឋាន និងចំណាយទៅលើប្រាក់បន្ថែមដល់សាលារៀនក្រោមទម្រង់ជាការបណ្តុះបណ្តាលគ្រូ ប្រាក់សោធននិវត្តន៍ និងការគ្រប់គ្រងប្រព័ន្ធទាំងមូល ដែលអាចប៉ាន់ប្រមាណពី២០ទៅ៣០ ភាគរយនៃការចំណាយផ្ទាល់នៃប្រាក់បៀវត្សរ៍គ្រូបង្រៀន។ ក្រៅពីនេះ រដ្ឋាភិបាលបានផ្តល់អាគារនិងសម្ភារៈផ្សេងៗជាច្រើនទៀត (Bray, 1999)។ ថវិកាឆ្នាំ២០២២ ត្រូវបានរៀបចំឡើងដោយផ្អែកលើអភិក្រមគ្រឹះជាយុទ្ធសាស្ត្រ៥ ដែលអភិក្រមទី៤គឺបន្តនិរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងបន្តជំរុញអនុវត្តកម្មវិធីកែទម្រង់សំខាន់របស់រដ្ឋាភិបាល ដើម្បីពង្រឹងភាពប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ច សំដៅធានាស្ថិរភាពកំណើន គាំទ្រដល់ការស្តារសេដ្ឋកិច្ច និងឆ្លើយតបតាមការសន្យាទៅនឹងសេចក្តីត្រូវការរបស់ប្រជាជន ព្រមទាំងពង្រឹងគ្រឹះក្នុងការកសាងស្ថាប័ន សមត្ថភាពវិស័យសាធារណៈក្នុងគោលដៅពង្រីកវិសាលភាពនិងគុណភាពនៃសេវាធារណៈនិងសេវាយុត្តិធម៌។ ក្នុងនោះ ការចំណាយថវិកាសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០២២ ស្មើនឹង ៣,៣៨២,៦៥៨ លានរៀល (អគ្គនាយកដ្ឋានពន្ធដារ, ២០២២)។

### ២.៤.២- ការចូលរួមពីអ្នកនយោបាយ

តាមការស្រាវជ្រាវរបស់លោក Bray (1999) បង្ហាញថាអ្នកនយោបាយ បានបំពេញតួនាទីសង្គមក្នុងការផ្តល់មូលនិធិសាលារៀនលើសពីអ្វីដែលបានរកឃើញនៅក្នុងប្រទេសដទៃទៀត។ ការចូលរួមរបស់អ្នកនយោបាយ ភាគច្រើនមិនប្រកាសពីប្រភពនៃមូលនិធិរបស់ពួកគេក្នុងលក្ខណៈច្បាស់លាស់ ជាពិសេសផ្នែកមួយនៃហិរញ្ញវត្ថុបានមកពីប្រភពជំនួស រួមទាំងការបរិច្ចាគរបស់អ្នកជំនួញក្នុងគោលបំណងគាំទ្រគណបក្សនយោបាយ ឬបុគ្គល។ ផ្អែកតាមទិន្នន័យបង្ហាញថា ក្នុងចំណោមសាលារៀន ៧៧ មានសាលា

រៀន៣១ ស្មើនឹង ៤០.៣ ភាគរយ បានទទួលអាគារសិក្សាឬគ្រឿងសង្ហារឹមពីអ្នកនយោបាយម្នាក់ឬច្រើន នាក់ក្នុងអំឡុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០។ ជាធម្មតាអាគារសិក្សាមានតម្លៃចន្លោះ ១៥,០០០ ដុល្លារអាមេរិច ទៅ២៥,០០០ ដុល្លារអាមេរិច និងសិស្សម្នាក់ជាមធ្យមទទួលបាន៣.៥០ ដុល្លារអាមេរិច។

### ២.៤.៣- ការចូលរួមពីអង្គការក្រៅរដ្ឋាភិបាល និងភ្នាក់ងារជំនួយខាងក្រៅ

ស្ថិតក្នុងស្ថានភាពប្រទេសក្រីក្របប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវបានចាប់អារម្មណ៍ខ្លាំងដោយបណ្តាប្រទេសនានាក្នុងការចូលរួមលើសកម្មភាពមិនយកកម្រៃ ពិសេសផ្នែកវិស័យអប់រំ។ តួយ៉ាង សហគមន៍អន្តរជាតិដូចជាទីភ្នាក់ងារផ្តល់ជំនួយជាពហុភាគីដល់ប្រព័ន្ធអប់រំ ADB សហប្រជាជាតិ UN រួមមាន (UNICEF UNDP UNFPA UNESCO) ធនាគារពិភពលោក WB សហគមន៍អឺរ៉ុបEU។ អ្នកផ្តល់ជំនួយទ្វេភាគី បារាំង អូស្ត្រាលី ជប៉ុន អង់គ្លេស អាល្លឺម៉ង់ ចិន រុស្ស៊ី វៀតណាម និងការផ្តល់ជំនួយតាមរយៈអង្គការក្រៅរដ្ឋាភិបាលដូចជា៖ Redd Barna(ប្រទេសន័រវែស្សន៍) SCN (Save Children Norway) អង្គការសង្គ្រោះកុមារកម្ពុជាន័រវែស្សន៍ Care International JSRC-JIVC-Japan ASAC-Japan Tops (Taipei Overseas Peace Service) Enfant du Cambodge ICS Assemblies of Gods Pour un Sourire d'Enfant SIPAR Quaker Service Australia Lutheran World Service Don Bosco Foundation VSO(Voluntary Service Overseas) World Vision New Humanity ដែលការចូលរួមទាំងនេះ ពិតជាបានសម្រាលបន្ទុកចំណាយរបស់រដ្ឋាភិបាល និងការចំណាយក្រុមគ្រួសារជាច្រើន (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ, ២០០៩)។ ជាក់ស្តែង អង្គការក្រៅរដ្ឋាភិបាល និងភ្នាក់ងារជំនួយខាងក្រៅបានផ្តល់ជាធនធានមនុស្ស បច្ចេកទេស ហិរញ្ញវត្ថុ ដែលភាគច្រើនបានបញ្ចូលទៅក្នុងកម្រិតសាលារៀន ដូចជា៖ World Vision Redd Barna UNICEF World Bank SIDA និង អង្គការពហុភាគីធំៗជាច្រើនទៀត។ សកម្មភាពទាំងនោះ ត្រូវបានបង្ហាញឱ្យឃើញពីការចូលរួមពិសេសលើការសាងសង់អាគារ ដោយក្នុងចំណោមសាលារៀនទាំង៧៧ មានសាលារៀន៤៣ ស្មើនឹង៥៥.៨ ភាគរយ និងមានការប៉ាន់ស្មានកម្រិតទូទាំងប្រទេសដោយសិស្សម្នាក់ទទួលបាន៧.០ ដុល្លារអាមេរិច។ ក្រៅពីការសាងសង់មានជាការផ្តល់ជូននូវសម្ភារៈបន្ថែមទៀតដូចជា បង្គន់អនាម័យ បណ្ណាល័យ និងអណ្តូងជាដើម (Bray, 1999)។

### ២.៤.៤- ការចូលរួមពីគ្រួសារ និងសហគមន៍

សហគមន៍ ដើរតួយ៉ាងសំខាន់ក្នុងវិស័យអប់រំដែលមិនអាចខ្វះបានឡើយ (Miller-Grandvaux, Yolande & Yolder, 2002)។ សហគមន៍នៅទីនេះសំដៅលើមាតាបិតាសិស្ស រដ្ឋអំណាច និងតំណាងសហគមន៍ដែលជាសមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន។ សហគមន៍អាចអនុវត្តសកម្មភាពដែលមានការឯកភាពនៅក្នុងផែនការកែលម្អសាលារៀនប្រចាំឆ្នាំ ឬដោយមានការប្តេជ្ញាចិត្តពីសហគមន៍នៅក្នុងឆ្នាំសិក្សា ដែលក្នុងសកម្មភាពសំខាន់ៗទាំងនោះគឺសហគមន៍អាចជួយរកមូលនិធិសាលារៀន តួយ៉ាងការជួយផ្តល់ធាតុចូលដល់សាលារៀន ជាប្រាក់ សម្ភារៈសិក្សាដល់សិស្ស ផ្តល់វត្ថុធាតុដើមសម្រាប់ធ្វើសង្ហារឹមឬថ្នាក់រៀន (ក្រសួងអប់រំយុវជននិងកីឡា, សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន, ២០១៨)។ សាលារៀនដំណើរការល្អ គឺអាស្រ័យដោយមានថវិកាទ្រទ្រង់ ដូចនេះ សហគមន៍ត្រូវចូលរួមយ៉ាងសកម្មក្នុងការស្វែងរកថវិកាសម្រាប់ឧបត្ថម្ភដល់សាលារៀន តាមរយៈបុណ្យផ្សេងៗ (បុណ្យរស្មីសាមគ្គីជាតិ បុណ្យផ្កា បុណ្យកំសាន្តផ្សេងៗ បុណ្យអង្គាសបច្ច័យ បុណ្យកឋិនទានជាដើម) ឬការសុំវិភាគទានជាប្រាក់ ស្រូវ សម្ភារៈផ្សេងៗ ការប្រើទុនបង្កើនឬទុនបង្វិលដោយទំនាក់ទំនងជាមួយសប្បុរសជន ក្រុមហ៊ុន រដ្ឋអំណាច... និងតាមរយៈសកម្មភាពផ្សេងៗដូចជាបង្កើតកន្លែងរមណីយដ្ឋាន កន្លែងទេសចរណ៍ ធ្វើសិប្បកម្ម សកម្មភាពសិល្បៈ និងទំនាក់ទំនងជាមួយអង្គការអន្តរជាតិ ក្រៅរដ្ឋាភិបាល។ ការចូលរួមរបស់សហគមន៍ពិតជានាំមកនូវភាពងាយស្រួលក្នុងការសម្រេចគោលដៅអប់រំជាតិ (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ, ២០០៩)។

ទំហំនៃការចូលរួមវិភាគទានរបស់គ្រួសារបង្ហាញថា មាតាបិតាសិស្សមានចំណែកដ៏ធំអំពីគុណភាពនិងប្រសិទ្ធិភាពនៃការផ្តល់សេវាអប់រំ (Lvailo, L., Huot, C., Sodeth, L., Paavo, E., Timothy, J., Emre, O., Suhas, P., Leah, A., ២០១១)។ ការចំណាយជាក់ស្តែង ដែលត្រូវបានគ្រួសារអ្នកទទួលរ៉ាប់រងដោយផ្ទាល់លើការទិញសម្ភារៈការិយាល័យ ឯកសណ្ឋាន និងសម្ភារៈផ្សេងៗទៀត ដូចជាការទិញសៀវភៅសិក្សាគោលបន្ថែមសម្រាប់ជំនួសការខ្វះខាតដែលសាលារៀនផ្តល់ជូន សៀវភៅសរសេរ សម្លៀកបំពាក់ ឯកសណ្ឋានជាចាំបាច់ ស្បែកជើងសាលា ឬស្បែកជើងកីឡា។ ក្រៅពីនេះ ការបង់ថ្លៃបង្រៀនបន្ថែម

ជាការចំណាយដ៏សំខាន់សម្រាប់គ្រួសារខ្មែរ ដែលភាគច្រើនត្រូវបានគេនិយមហៅថាគួរក្រៅម៉ោង ពេល ឪពុកម្ដាយ អាណាព្យាបាលនឹងត្រូវបង់ថ្លៃខាងក្រៅសម្រាប់គ្រូបង្រៀនដែលយកពេលវេលាក្រៅម៉ោង សិក្សាមកបង្រៀនបន្ថែមដល់កូនៗរបស់ពួកគេ។ ចូលរួមចំណែកក្នុងការប្រមូលថវិកាក្នុងកម្មវិធីបុណ្យ នានា វាជារឿងសាមញ្ញនៃការរៃអង្គាសថវិកាសហគមន៍សម្រាប់សាលារៀន ដែលគេតែងនិយមហៅពិធី បុណ្យផ្កាសាមគ្គី។ ទន្ទឹមនឹងនេះ សាលារៀនជាច្រើនបានស្នើសុំចំពោះមាតាបិតា អាណាព្យាបាលនិង សមាជិកសហគមន៍ផ្ដល់ជាកម្លាំងពលកម្ម ឬសម្ភារៈសម្រាប់សាងសង់អាគារ តាមរយៈការចំណាយពេល វេលាចូលរួមដោយផ្ទាល់លើកិច្ចការងារសាលា ការចូលរួមប្រជុំនានា ឬអាចចូលរួមបរិច្ចាគជាស៊ីម៉ង់ត៍ ឈើ ខ្សាច់ ឥដ្ឋ គ្រឿងសង្ហារឹម និងសម្ភារៈកីឡា (Bray, 1999)។ ចំពោះដំណើរការសាលារៀន និងលទ្ធផល សិក្សារបស់សិស្សនឹងទទួលបានប្រសិទ្ធភាពកម្រិតទាប ប្រសិនបើពុំមានការចូលរួមជួយជ្រោមជ្រែងពី សំណាក់ឪពុកម្ដាយ (Menon, 2013)។

ការចូលរួមរបស់មាតាបិតាអាណាព្យាលនិងសហគមន៍ជាធាតុចាំបាច់ក្នុងការកាត់បន្ថយបន្ទុករដ្ឋាភិ បាល និងជំរុញដល់គុណភាពអប់រំ។ យោងតាមរបាយការណ៍ KAP (២០២២) ដែលបានអនុវត្តកម្មវិធី សាលារៀនជំនាន់ថ្មី បានបន្តការអនុវត្តសកម្មភាពឆ្នាំទី៧ ក្នុងឆ្នាំ២០២២ ដែលបានដាក់ចេញបញ្ញត្តិនិរន្ត ភាពពីកម្មវិធីក្នុងស្រុកឱ្យបានច្រើនតាមដែលអាចធ្វើបាន ដើម្បីកាត់បន្ថយថវិកាគាំពីរដ្ឋាភិបាល។ ពេល បច្ចុប្បន្ន សាលារៀនចំនួន៦០ភាគរយ សម្រេចបានមូលនិធិពីសហគមន៍ក្នុងតំបន់ ដែលមានចំនួន៥០ ភាគរយ ឬលើសនេះ នៃថវិកាដំណើរការសាលារៀនប្រចាំឆ្នាំ។ ហិរញ្ញវត្ថុពីសហគមន៍នឹងបន្តកើនឡើង ដល់ចំណុចមួយដែលសាលារៀនទាំងអស់គួរតែអាចមាននិរន្តភាពផ្ទាល់ខ្លួន (អង្គការសកម្មភាពសម្រាប់ ការអប់រំនៅកម្ពុជា(ខេប), ២០២២)។

សរុបជារួម ការចូលរួមរបស់គ្រួសារនិងសហគមន៍ពិតជាមានសារៈសំខាន់ណាស់សម្រាប់ការគាំទ្រ កុមារ យុវជន និងវិស័យអប់រំកម្ពុជា មិនមែនត្រឹមតែជាការចូលរួមថវិកាប៉ុណ្ណោះទេ ប៉ុន្តែជាការចូលរួមគ្រប់ សកម្មភាពលើដំណើរការអភិវឌ្ឍសាលារៀន ដែលសកម្មភាពទាំងនេះមិនអាចកាត់ផ្ដាច់ចេញពីគ្នាបាន នោះឡើយ។

### ២.៤.៥- ការចូលរួមពីសាលារៀន

យោងតាមច្បាប់អប់រំស្តីពីការអប់រំ (២០០៧) អ្នកគ្រប់គ្រងគ្រឹះស្ថានសិក្សា មានសិទ្ធិក្នុងការកៀរគរធនធានស្របច្បាប់នានាពីគ្រប់ប្រភពដើម្បីអភិវឌ្ឍគ្រឹះស្ថានសិក្សា។ ការផ្តល់ធនធានត្រូវធ្វើតាមការស្ម័គ្រចិត្ត និងឥតលក្ខខណ្ឌ។ សាលារៀនត្រូវមានគណៈកម្មការគ្រប់គ្រងសាលារៀនដែលជារចនាសម្ព័ន្ធផ្លូវការដើម្បីគ្រប់គ្រងការអនុវត្តប្រចាំថ្ងៃនៃការគ្រប់គ្រងតាមសាលារៀន។ គណៈកម្មការគ្រប់គ្រងសាលារៀនមានសមាសភាពចំនួនប្រាំមួយរូបដែលជាមន្ត្រីក្រុមការងារគ្រប់គ្រងតាមសាលារៀននៃក្រសួងអប់រំ យុវជន និងកីឡា ក្រុមគ្រូបង្គោលមុខវិជ្ជាថ្នាក់ជាតិ គ្រូបង្រៀននិងបុគ្គលិកសាលារៀន តំណាងមាតាបិតា រួមបញ្ចូលទាំងគ្រួសារ អ្នកក្រ និងយ៉ាប់យឺន និងសហគមន៍ ដែលមានប្រធានភូមិ អ្នកមានប្រជាប្រិយភាព សមាជិកក្រុមប្រឹក្សាឃុំសង្កាត់។ គណៈកម្មការគ្រប់គ្រងសាលារៀននេះហើយ ជាអ្នកកសាងគ្រឹះសម្រាប់ការស្វែងរកមូលនិធិ (ក្រសួងអប់រំយុវជននិងកីឡា, សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន, ២០១៨)។

សាលារៀនជាអ្នកកសាងទំនាក់ទំនងជាមួយសហគមន៍ ហើយការចូលរួមរបស់សហគមន៍ជួយឱ្យសម្រេចគោលដៅអប់រំជាតិ។ ដូច្នេះ ហើយបានជានាយកសាលារៀនចំណាយពេលវេលាច្រើន និងរិះរកគ្រប់យុទ្ធវិធីទាក់ទាញសហគមន៍ឱ្យសប្បាយរីករាយចូលរួមគ្រប់សកម្មភាពក្នុងការអភិវឌ្ឍសាលារៀនរបស់ខ្លួនឱ្យបានឆាប់រហ័សសមស្របតាមការរីកចម្រើនក្នុងសហស្សវត្សថ្មីនេះ (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ, ២០០៩)។

យោងតាម Bray and Seng (2005) សាលារៀននៅកម្ពុជាមានប្រភពចំណូលផ្សេងៗដែលបានមកពីការជួលទីតាំងលក់អាហារឱ្យអ្នកលក់ និងទីធ្លាសាលារៀនសម្រាប់ផ្ញើកង់ នៅចន្លោះម៉ោងសិក្សារដ្ឋសាសារៀនជួលបន្ទប់ឬអាគារសិក្សាឱ្យឯកជន និងមានសាលារៀននៅជនបទអាចរកប្រាក់បន្ថែមបានតាមរយៈការលក់បន្លែបង្ការដែលដាំក្នុងសាលារៀននិងតាមវិធីផ្សេងៗទៀត។ ស្របតាមការស្រាវជ្រាវរបស់លោក (Bray, 1999) សាលារៀនមួយចំនួនមានលទ្ធភាពទទួលបានចំណូលបន្ថែម ដែលបង្កើតឡើងដោយខ្លួនឯង តួយ៉ាងក្នុងចំណោមសាលារៀន៧៧ មានសាលារៀន១៦ ស្មើនឹង២០.៨ ភាគរយ នៃប្រាក់

ចំណូលបានពីកសិដ្ឋាន និងសួនច្បារ ដោយសាលាខ្លះបានចិញ្ចឹមត្រីក្នុងស្រះសាលារបស់ខ្លួនដែលនេះជារឿងគួរឱ្យចាប់អារម្មណ៍ផងដែរ ។

## ២.៥ សារៈសំខាន់នៃការចូលរួមសម្របសម្រួលលើបន្ទុកចំណាយរបស់សិស្ស

ការចំណាយលើការសិក្សារបស់សិស្សជារឿងចាំបាច់ដែលត្រូវដោះស្រាយ ជាពិសេសការចំណាយក្រៅផ្លូវការឬចំណាយមិនចាំបាច់នានាដើម្បីសម្រួលបន្ទុកគ្រួសារក្រីក្រដែលមានចំណូលទាប ចៀសវាងការលើកឡើងនូវមតិអវិជ្ជមាននានារបស់មាតាបិតាមកលើស្ថាប័នអប់រំ និងជំរុញដល់ប្រសិទ្ធភាពនៃការអប់រំដល់កុមារបានកាន់តែប្រសើរ។ ឧទាហរណ៍ ការបន្តឱ្យមានបង់ប្រាក់ឯកជន(រៀនក្រៅម៉ោង) ដែលមាននៅអ៊ឺរ៉ុបខាងកើតនិងអាស៊ីកណ្ដាល វាមានសារៈសំខាន់ក្នុងការត្រួតពិនិត្យបន្ថែមទៀតនូវបទប្បញ្ញតិនៃការបង្រៀនឯកជននេះ ដើម្បីកាត់បន្ថយវិសមភាពសេដ្ឋកិច្ចសង្គម និងកាត់បន្ថយហានិភ័យនៃអំពើពុករលួយនៅក្នុងសាលារៀន។ ក្នុងន័យនេះ រាជរដ្ឋាភិបាល មន្ត្រីអប់រំ កម្រិតសាលារៀនអាចយកមកពិចារណាពីការបង្រៀនឯកជនក្នុងសាលាជំនួសដោយការបង្រៀនបន្ថែមក្នុងម៉ោងរដ្ឋ ជាប្រយោជន៍ដល់ការកាត់បន្ថយបញ្ហាតម្លាភាពនៃការផ្ដល់ពិន្ទុលម្អៀងរវាងសិស្សបានរៀននិងមិនបានរៀនឯកជនផងដែរ។ ទន្ទឹមនឹងនេះ វាជាឱកាសសម្រាប់អ្នកបង្កើតគោលនយោបាយសិក្សាឈ្វេងយល់ពីតម្រូវការរបស់សិស្សដែលស្ម័គ្រចិត្តឬបង្ខំសិក្សាឯកជន ដើម្បីត្រួតពិនិត្យឡើងវិញនូវគុណភាពអប់រំ វង្វាយតម្លៃ និងធ្វើកំណែទម្រង់ជាប្រព័ន្ធដូចជា ការបង្កើតកម្មវិធីសិក្សា ស្តង់ដាកម្មវិធីសិក្សា ធានាបាននូវសៀវភៅសិក្សាគោលគ្រប់គ្រាន់ និងការកែលម្អបរិយាកាសសិក្សានៅក្នុងសាលារៀន (Silova, 2010)។

នៅពេលដែលស្ថានភាពសេដ្ឋកិច្ចគ្រួសារទន់ខ្សោយ ការសម្រេចចិត្តបញ្ជូនកូនទៅសាលានឹងត្រូវបានពិចារណាយ៉ាងតានតឹង ដូចនេះការរក្សាតុល្យភាពរវាងការចំណាយនិងចំណូលរបស់គ្រួសារតាមរយៈការប្រើប្រាស់មធ្យោបាយផ្សេងៗដូចជា៖ ការធានាផ្ដល់ហិរញ្ញប្បទានដល់ប្រព័ន្ធអប់រំយ៉ាងហោចណាស់សម្រាប់ការចំណាយផ្ទាល់នៃប្រព័ន្ធអប់រំ ការចូលរួមពីអាជ្ញាធរ ឬការកំណត់ភាពជាក់លាក់ពីលទ្ធភាពដែលរដ្ឋាភិបាលអាចធ្វើបានរួចកំណត់ថានរណាជាអ្នកបំពេញចន្លោះខ្វះខាតបន្ថែម ពិតជាសំខាន់ ព្រោះកាលបើបានរៀបចំគោលនយោបាយច្បាស់លាស់បែបនេះ គឺអាចជួយកាត់បន្ថយបន្ទុកយ៉ាងធ្ងន់ធ្ងររបស់ប្រជា

ជនក្រីក្រ។ ប្រសិនបើគ្មានអន្តរាគមន៍ណាមួយទេ គ្រួសារសិស្សអាចសម្រេចចិត្តដោយមានទំនោរទៅលើការចំណាយអាទិភាពផ្សេងៗ ជាជាងការមានទំនោរចិត្តទៅលើចំណាយការសិក្សារបស់សិស្សមិនខាន (Bray and Seng, 2005)។

## ២.៦ ការចូលរួមស្ម័គ្រចិត្តរបស់មាតាបិតាលើចំណាយការសិក្សារបស់សិស្ស

ក្នុងបរិបទប្រទេសកំពុងអភិវឌ្ឍន៍ ការចូលរួមហិរញ្ញប្បទានគ្រួសារនិងសហគមន៍ចំពោះវិស័យអប់រំគឺជារឿងចម្បងដែលជំរុញ ពង្រីកបរិមាណ និងលើកកម្ពស់គុណភាពអប់រំ។ ប្រសិនបើគ្មានការចូលរួមពីគ្រួសារ និងសហគមន៍ទេ សាលារៀនមួយចំនួននឹងមិនអាចដំណើរការបានឡើយ។ ប្រសិនបើអ្វីៗគ្រប់យ៉ាងត្រូវបានផ្តល់ជូនឥតគិតថ្លៃពីរដ្ឋាភិបាល ទំនងជាមិនមានការចាប់អារម្មណ៍ការចូលរួមរបស់គ្រួសារ និងសហគមន៍លើការសិក្សារបស់កុមារនោះឡើយ (Bray and Seng, 2005)។ តាមរយៈ លោក (Epstein, 2022) បានលើកឡើងថា ការចូលរួមរបស់មាតាបិតាចំពោះការសិក្សាអប់រំបុត្រធីតាមាន៦ប្រភេទ ដែលក្នុងនោះការស្ម័គ្រចិត្តរបស់ឪពុកម្តាយ ការម្រេចចិត្ត និងការសហការគ្នាជាមួយសហគមន៍គឺជាប់ទាក់ទងនឹងសេដ្ឋកិច្ចគ្រួសារ ប៉ុន្តែវាជាសិទ្ធិនិងករណីកិច្ចក្នុងការកសាងអនាគតពួកគេឱ្យក្លាយជាពលរដ្ឋពេញលេញដែលជាគ្រឹះរឹងមាំរបស់សង្គមជាតិ។ ត្រង់ន័យនេះ អ្វីដែលធ្វើឱ្យឪពុកម្តាយគិតថាការអប់រំជាការវិនិយោគដ៏សំខាន់ និងបានចូលរួមដោយស្ម័គ្រចិត្តចំពោះការសិក្សារបស់កូនៗ គឺដោយសារការមើលឃើញពីគុណតម្លៃនៃការអប់រំ ដែលបានជះឥទ្ធិពលវិជ្ជមានដល់បុត្រធីតា គ្រួសារ សង្គម។ ប្រសិនបើគ្រប់ក្រុមគ្រួសារ បានចូលរួមចំណែកយ៉ាងសស្រាក់សស្រាំ និងមានការសហការគ្រប់សកម្មភាពទាំងធនធានពេលវេលា និងធនធានហិរញ្ញវត្ថុ នោះវានឹងជះឥទ្ធិពលល្អបំផុតសម្រាប់លទ្ធផលសិក្សារបស់កុមារ (Hom, 2008)។

## ២.៧ ការជំរុញការចូលរួមអាណាព្យាបាល/សហគមន៍លើចំណាយការសិក្សា

ស្ថិតក្នុងបរិបទប្រទេសកម្ពុជា វត្តមាននៃការចូលរួមរបស់មាតាបិតាគឺត្រូវបានជំរុញនិងលើកទឹកចិត្តដោយច្បាប់ គោលនយោបាយជាតិ គោលនយបាយអប់រំ និងលិខិតបទដ្ឋាននានា។ ការបង្កើនភាពជាដៃគូរវាងសាលារៀននិងគ្រួសារសិស្សពិតជាសំខាន់ ដូច្នេះសាលាត្រូវតែខិតខំបង្កើនភាពស្និទ្ធស្នាលជាមួយ

គ្រួសារសិស្សកាន់តែប្រសើរ ប្រសិនបើទំនាក់ទំនងមួយនេះល្អវានឹងធ្វើឱ្យឪពុកម្តាយសិស្សពេញចិត្ត បើឪពុកម្តាយសិស្សមានការពេញចិត្តចំពោះសាលារៀនកាន់តែខ្លាំង នោះកូនសិស្សនិងទទួលបានជោគជ័យលើការសិក្សាកាន់តែខ្លាំង (Sylvie and Isabelle, 2022)។ ការជំរុញលើកទឹកចិត្តមាតាបិតាអាណាព្យាបាលរបស់សិស្សក្នុងការចូលរួមនានាអាចធ្វើបានតាមរយៈការបង្កើតកម្មវិធីសាលារៀន ព្រឹត្តិការណ៍សាលា ការចូលរួមប្រជុំ ការបង្កើនទំនុកចិត្ត តម្លាភាព គណនេយ្យភាព ជាពិសេសការផ្តល់ព័ត៌មានអំពីការសិក្សារបស់កូនសិស្ស គឺកាន់តែបង្ហាញឱ្យអាណាព្យាបាលរបស់យល់ថាសាលារៀន លោកគ្រូអ្នកគ្រូ គណៈគ្រប់គ្រងសាលាបានយកចិត្តទុកដាក់ចំពោះការសិក្សារបស់កូនៗពួកគេបំផុត (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ, ២០០៩)។

គ្រួសារជាកោសិការបស់សង្គម ឬអាចនិយាយបានថាជាកោសិកាសហគមន៍។ សាលារៀនមិនអាចស្ថិតនៅដាច់ដោយឡែកតែឯកឯងដោយគ្មានទំនាក់ទំនងជាមួយគ្រួសារ សហគមន៍បាននោះឡើយ។ ដូចនេះ អ្នកអនុវត្តផ្ទាល់ជាមួយសិស្ស សំដៅដល់សាលារៀនគឺត្រូវធ្វើយ៉ាងណាបង្កើនចំណាប់អារម្មណ៍ ទាក់ទាញការចូលរួមពីសហគមន៍ជាអាទិ៍៖

- **ការរៀបចំគណៈកម្មការ និងក្រុមប្រឹក្សានានារបស់សាលារៀន៖** ដើម្បីសម្រេចបានទៅតាមទិសដៅអប់រំជាតិ និងទិសដៅសម្រាប់ទាំងអស់គ្នា នាយកសាលារៀនឬគណៈគ្រប់គ្រងមិនអាចសម្រេចជោគជ័យលើភារកិច្ចធំធេងនោះបានឡើយ។ ដូចនេះ សាលារៀនត្រូវរៀបចំគណៈកម្មការ និងក្រុមប្រឹក្សានានាដើម្បីជួយនាយកលើការងារគ្រប់គ្រង ការស្វែងរកថវិកា និងការងារអប់រំកុមារ យុវជន ឱ្យមានដំណើរការទៀងទាត់ និងសកម្មក្នុងវិស័យអប់រំ។
- **ការផ្សព្វផ្សាយ៖** ការផ្សព្វផ្សាយស្តីពីសហគមន៍ចូលរួមក្នុងការអភិវឌ្ឍសាលារៀនមានសារៈបំផុត ដោយនាយកសាលាត្រូវតែមានយុទ្ធវិធីល្អៗ ដើម្បីឱ្យការផ្សព្វផ្សាយនោះទទួលបានលទ្ធផល។ ទី១. ខ្លឹមសារដែលត្រូវផ្សព្វផ្សាយ ដូចជាសារៈសំខាន់នៃទំនាក់ទំនងរវាងសាលារៀននិងសហគមន៍ បញ្ញត្តិសាលារៀន សហគមន៍និងទំនាក់ទនងសាលារៀននិងសហគមន៍ តួនាទីនិងភារកិច្ចរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀន គោលការណ៍នៃការអភិវឌ្ឍទំនាក់ទំនង

សាលារៀននិងសហគមន៍ យុទ្ធវិធីរបស់នាយកសាលារៀន ដើម្បីទាក់ទាញសហគមន៍ឱ្យចូលរួមក្នុងការអភិវឌ្ឍសាលារៀន តម្រូវការនិងផែនការរបស់សាលារៀន គោលដៅអប់រំជាតិ បញ្ញត្តិកម្រងសាលារៀន លិខិតណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ការទទួលនិងការប្រើប្រាស់ថវិកា លទ្ធផលសិក្សារបស់សិស្ស បទពិសោធរបស់សហគមន៍នានា ខ្លឹមសារសន្និបាតអប់រំជាតិ សន្និបាតអប់រំខេត្ត-ស្រុក ខ្លឹមសារសោលាអន្តរជាតិ ការអប់រំសម្រាប់ទាំងអស់គ្នា ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និន្នាការអប់រំពិភពលោកក្នុងសហស្សវត្សថ្មី កម្មវិធីសិក្សា បទបញ្ជាផ្ទៃក្នុងសាលារៀន សិទ្ធិកុមារនិងយុវជន និងគោលវិធីសិស្សមជ្ឈមណ្ឌល។ ទី២៖ រូបភាពផ្សព្វផ្សាយដូចជា៖ ការប្រជុំ (ការប្រជុំដើមឆ្នាំសិក្សា ការប្រជុំដំណាច់ឆមាសទី១ ការប្រជុំដំណាច់សិក្សា) ការចុះសាកសួរផ្ទាល់ដល់គ្រួសារសិស្ស ការអញ្ជើញមាតាបិតាសិស្សមកសាលារៀន ការបង្កើតសៀវភៅទំនាក់ទំនងជាមួយគ្រួសារសិស្ស និងផ្លាស់ប្តូរសំបុត្រស្នាមជាមួយមាតាបិតាសិស្ស ការចូលរួមក្នុងពិធីបុណ្យទាន ការផ្សព្វផ្សាយតាមបណ្តាអង្គភាពព័ត៌មានមហាជន។

- **ការកំណត់ផែនការ និងកម្មវិធីការងារ៖** នាយកសាលារៀនត្រូវកំណត់ផែនការ និងកម្មវិធីការងារសាលារបស់ខ្លួនឱ្យបានច្បាស់លាស់ ដូចជាការប្រជុំគណៈកម្មការទ្រទ្រង់សាលារៀន (៣ដងក្នុងមួយឆ្នាំគឺ ដើមឆ្នាំសិក្សា ដំណាច់ឆមាសទី១ និងដំណាច់ឆ្នាំសិក្សា) ការប្រជុំក្រុមប្រឹក្សាអប់រំ (២ដងក្នុងមួយឆ្នាំគឺប្រជុំមុនបវេសនកាលដើម្បីផ្សព្វផ្សាយលិខិតណែនាំ សារាចរផ្សេងៗ ស្តីពីការងារអប់រំ និងប្រជុំនៅដំណាច់ឆ្នាំសិក្សា ដើម្បីពិនិត្យការអនុវត្តការងារអប់រំមួយឆ្នាំសិក្សា) ការប្រជុំគណៈកម្មការសាងសង់ (ដើម្បីអនុវត្តការងារជួសជុល និងសាងសង់តាមការចាំបាច់របស់សាលារៀន) ប្រជុំគណៈកម្មការកម្រងសាលារៀន (ប្រជុំមួយខែម្តង មានសហគមន៍ចូលរួម ដើម្បីកសាងផែនការតាមដានការអនុវត្តផែនការ និងការប្រើប្រាស់ថវិកា)។
- **ការចាត់តាំងសកម្មភាពក្រៅថ្នាក់ ក្រៅសាលា៖** សកម្មភាពក្រៅថ្នាក់ឬក្រៅសាលារៀនជួយបំពេញបន្ថែមការងារអប់រំដល់កុមារ និងយុវជន ទាំងចំណេះដឹង បំណិន និងសីលធម៌រស់នៅ ដើម្បីឱ្យកុមារនិងយុវជនទាំងនោះក្លាយជាពលរដ្ឋល្អ។ សកម្មភាពទាំងនោះរួមមាន៖ ក្លឹបសិក្សា

(សាលាអាចស្វែងរកសិស្សពូកែ ឬអ្នកមានចំណេះវិជ្ជាក្នុងភូមិឃុំ អាចជាមាតាបិតា យុវជន ប្រជាជន ដើម្បីជួយបង្រៀនដល់កុមារ យុវជននៅក្នុងភូមិដែលបានជួបប្រជុំជាក្រុមតូច ៥-៦នាក់ ក្នុងពេលទំនេរក្រៅសាលារៀន) ក្លឹបវប្បធម៌សិល្បៈ (នាយកសាលារៀនត្រូវសហការជាមួយ ស្ថាប័នជំនាញរបស់អាជ្ញាធរដែនដី និងអង្គការក្រៅរដ្ឋាភិបាលដើម្បីជួយឧបត្ថម្ភចាត់តាំងឱ្យ មានកម្មវិធីប្រគុំតន្ត្រី សំដែងសិល្បៈ បង្រៀនភ្លេង របាំដល់កុមារ យុវជន ដែលមាននិស្ស័យ សិល្បៈ ជាមួយក្រុមតូចៗ នៅភូមិ ឃុំ) ក្លឹបកីឡា(នាយកសាលារៀនត្រូវសហការជាមួយគណៈ កម្មការ អាជ្ញាធរដែនដី និងអង្គការក្រៅរដ្ឋាភិបាល បង្កើតទីធ្លាក្នុងភូមិ ឃុំ បំផុសឱ្យកុមារ និង យុវជនលេងកីឡាហាត់ប្រាណ លេងល្បែងប្រជាប្រិយ កីឡាប្រជាប្រិយពីសំណាក់កីឡាករ ឬអ៊ំ ចាស់ៗ ដែលមានចំណេះដឹងក្នុងវិស័យកីឡានិងល្បែងប្រជាប្រិយខ្មែរ)។

– **សិក្ខាសាលាការងារសហគមន៍៖** សហគមន៍បានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសាលារៀន នាយកសាលារៀនត្រូវទំនាក់ទំនងជាមួយប្រធានកម្រងសាលារៀន ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុក ខណ្ឌ ប្រធានមន្ទីរអេយករាជធានី ខេត្ត ដើម្បីរៀបចំធ្វើសិក្ខាសាលាសហ គមន៍តាមកម្រងសាលារៀនក្នុងគោលបំណង៖ ដកស្រង់បទពិសោធនិងផ្សព្វផ្សាយមេរៀនបទ ពិសោធចែកជូនគ្នាទៅវិញទៅមក ពង្រឹងឥទ្ធិពលសហគមន៍ឱ្យកាន់តែខ្លាំងក្លាដើម្បីឱ្យមានការ រីកចម្រើនប្រហាក់ប្រហែលគ្នានៅទូទាំងប្រទេស ជួយផ្តល់យោបល់ដោះស្រាយការលំបាកគ្នា ទៅវិញទៅមក រិះរកគន្លឹះរីកចម្រើនសម្រាប់អនុវត្តផ្ទាល់នៅក្នុងមូលដ្ឋានរបស់ខ្លួនក្នុងការពង្រឹង កម្លាំងអប់រំទាំងបីគឺ៖ សាលារៀន គ្រួសារ និងសហគមន៍ លើកកម្ពស់ការយល់ដឹងអំពីតួនាទី និងភារកិច្ចរបស់សហគមន៍ក្នុងវិស័យអប់រំឱ្យកាន់តែទូលំទូលាយ លើកកម្ពស់ស្មារតីទទួលខុស ត្រូវកាន់តែខ្ពស់ក្នុងរួមចំណែកអប់រំថែទាំកុមារពិសេសកុមារទីទ័លក្រជួបការលំបាក កុមារជន ជាតិភាគតិចនៅជនបទឱ្យក្លាយជាពលរដ្ឋមានប្រយោជន៍សម្រាប់សហគមន៍វិញ យល់ច្បាស់ពី កាតព្វកិច្ចចំពោះការអប់រំកូនចៅដើម្បីប្រមូលកុមារចូលរៀន មានស្មេរភាពបានជាអតិបរមារួម ចំណែកកាត់បន្ថយអត្រាត្រួតថ្នាក់ អត្រាបោះបង់ការសិក្សា ការពឹងផ្អែកកម្លាំងកុមារ យុវជនក្នុង

ការងារពលកម្ម បង្កើនកិច្ចសហប្រតិបត្តិការរវាងសហគមន៍សាលារៀន ជាមួយអង្គការជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលជាម្ចាស់អំណោយ បង្កើនតម្លាភាពរវាងសាលារៀន កម្រងសាលារៀន ជាមួយសហគមន៍ ពិសេសលើការគ្រប់គ្រងថវិកាសាលារៀន កម្រងសាលារៀនធ្វើឱ្យបរិស្ថានសង្គមកាន់តែមានទំនុកចិត្តចូលរួមជួយវិស័យអប់រំកាន់តែកុះករ ពង្រីកការយល់ដឹងអំពីកាតព្វកិច្ចរបស់មាតាបិតា ចំពោះបុត្រធីតា ជំរុញកូនចៅឱ្យមករៀនខំរៀននិងកាត់បន្ថយការពឹងផ្អែកកម្លាំងពលកម្មរបស់កូន ពង្រីកទស្សនៈនិងសកម្មភាពរបស់សហគមន៍ឱ្យយល់កាន់តែច្បាស់ថា ការងារសហគមន៍ពុំមែនស្ថិតនៅត្រឹមតែរកថវិកាកសាងសាលារៀនប៉ុណ្ណោះទេ។

- **ការរៀបចំសកម្មភាពឬព្រឹត្តការណ៍ផ្សេងៗដើម្បីទាក់ទាញសហគមន៍៖** ជារៀងរាល់ឆ្នាំសាលារៀនតែងតែមានសកម្មភាពឬព្រឹត្តិការណ៍ផ្សេងៗដែលជួយជំរុញឱ្យការអប់រំកុមារ យុវជនមានសន្ទុះឆ្ពោះទៅរកការរីកចម្រើនទាំងផ្លូវកាយ បញ្ញា និងចិត្តគំនិត។ សកម្មភាពឬព្រឹត្តិការណ៍ទាំងនោះរួមមាន៖ រៀបចំបុណ្យបវេសនកាល (នាយកសាលារៀនធ្វើលិខិតអញ្ជើញសហគមន៍ឱ្យចូលរួមមានមាតាបិតាសិស្ស គណៈកម្មការទ្រទ្រង់សាលា ព្រះសង្ឃ និងអាជ្ញាធរដែនដីដើម្បីឱ្យបានដឹងពីដំណើរការសិក្សារបស់កុមារនិងយុវជន) រៀបចំពិធីចែករង្វាន់ជូនសិស្សពូកែ (នៅដំណាច់ឆ្នាំសិក្សា នាយកសាលារៀនបានរៀបចំពីធីចែករង្វាន់ដល់សិស្សពូកែ ដោយអញ្ជើញសហគមន៍ឱ្យចូលរួមដើម្បីឱ្យពួកគាត់បានយល់ដឹងពីលទ្ធផលសិក្សារបស់កូនចៅ) រៀបចំពិធីសម្ពោធអគារសិក្សា (ការសាងសង់សាលារៀនតែងមានការជួយឧបត្ថម្ភពីសហគមន៍ សប្បុរសជនក្នុងនិងក្រៅប្រទេស ពីរដ្ឋាភិបាលជាដើម ដូចនេះនាយកសាលាត្រូវសហការជាមួយសហគមន៍អញ្ជើញគាត់ឱ្យមកជួយរៀបចំនិងចូលរួមក្នុងពិធីសម្ពោធនោះ) រៀបចំបុណ្យទិវាកុមារអន្តរជាតិ (នាយកសាលាត្រូវអញ្ជើញមាតាបិតាសិស្សអាជ្ញាធរមូលដ្ឋានឱ្យគាត់មកចូលរួមស្តាប់ខ្លឹមសារបុណ្យទិវាកុមារអន្តរជាតិ) រៀបចំបុណ្យទិវាយុវជនអន្តរជាតិ (ត្រូវបានរៀបចំកម្មវិធីនិងសមាសភាពចូលរួមដូចទិវាកុមារអន្តរជាតិដែរ តែត្រូវមានការប្រឡងប្រណាំងស្នាដៃយុវជននិងជូនរង្វាន់បន្ថែមទៀត) រៀបចំបុណ្យក្នុងសាលារៀន (ការជួសជុលអគារ ឬកែលម្អសោភ័ណ

ភាពសាលារៀនទាមទារឱ្យនាយកសាលារៀនសហការជាមួយសហគមន៍ផ្តើមធ្វើបុណ្យផ្កា ឬបុណ្យផ្សេងៗដើម្បីប្រមូលបច្ច័យមកបម្រើតាមតម្រូវការខាងលើ ដូចនេះនាយកសាលារៀនត្រូវក្តាប់សភាពការណ៍ឱ្យបាន និងខំទាក់ទាញសហគមន៍ជាមួយបច្ច័យបានច្រើនក្នុងពិធីបុណ្យ) រៀបចំពិព័រណ៍ស្នាដៃសិស្ស (សម្ភារៈផ្សេងៗដែលជាស្នាដៃរបស់សិស្ស ដូចជាសម្ភារៈសិប្បកម្ម សម្ភារៈដេរប៉ាក់ ផ្ទាំងគំនូរផ្សេងៗ លោកនាយកត្រូវប្រមូលយកមកដាក់តាំងពិព័រណ៍ដើម្បីឱ្យសិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ មាតាបិតា អាជ្ញាធរដែនដី និងភ្ញៀវដទៃទៀតបានចូលទស្សនានិងលក់ជូនភ្ញៀវយកថវិកាមកបំពេញកង្វះខាតរបស់សាលារៀន) រៀបចំការសំដែងសិល្បៈ (ចម្រៀង របាំប្រពៃណី រឿងកំប្លែងផ្សេងៗ ដែលសាលារៀនបានបង្ហាត់ត្រូវយកមកសំដែងនៅពេលបុណ្យទានរបស់សាលា ឬក្នុងពិធីចែករង្វាន់ជូនសិស្សពូកែនាដំណាច់ឆ្នាំសិក្សា នាយកត្រូវអញ្ជើញសហគមន៍ឱ្យចូលរួមទស្សនាឱ្យបានច្រើនកុះករ ដើម្បីឱ្យពួកគាត់បានឃើញ និងជួយលើវិស័យសិល្បៈឬជំនួយផ្សេងៗតាមលទ្ធភាព) រៀបចំប្រកួតកីឡា (នាយកសាលាត្រូវតែមានទំនាក់ទំនងជាមួយសហគមន៍ដោយបំផុសឱ្យជួយជាសម្ភារថវិកាដល់ក្រុមកីឡា និងអញ្ជើញសហគមន៍ឱ្យមកទស្សនាការប្រកួតកីឡាតាមមូលដ្ឋានដែលគាត់រស់នៅ) ការរៀបចំទស្សនកិច្ច (មានសកម្មភាពសិក្សាជាច្រើនដែលកុមារនិងយុវជនមិនអាចរៀននៅក្នុងថ្នាក់បាន។ ដូចនេះនាយកសាលាត្រូវរៀបចំទស្សនកិច្ចសិក្សាដល់ទីកន្លែងដូចជាៈ មេរៀនសិប្បកម្មត្បាញកន្ទេល ក្រមា ហូល ផាមួង ការចិញ្ចឹមសត្វមាន់ ទា ជ្រូក ការធ្វើឥដ្ឋក្បឿង ធ្វើអំបិល ស៊ីម៉ងត៍... ឬទីតាំងទស្សនកិច្ចណាដែលសិស្សងាយស្រួលចុះសិក្សា សុវត្ថិភាព) រៀបចំសកម្មភាព ពលកម្មផលិត និងសកម្មភាពសង្គម (នាយកសាលារៀនត្រូវសហការជាមួយសហគមន៍ ពិសេសប្រជាពលរដ្ឋដែលចេះបច្ចេកទេសជាំងុះដើម្បីបង្ហាត់បង្ហាញសិស្សឱ្យចេះ និងអាចអនុវត្តបាន ចំណែកឯសកម្មភាពផ្សេងៗ ដូចជាអនាម័យកន្លែងសាធារណៈ ពលកម្មលើកផ្លូវលំ សុទ្ធសឹងជារឿងល្អដែលបានបង្ហាញពីទំនាក់ទំនងគ្នាសាលារៀននិងសហគមន៍)។

## ២.៨ ការស្រាវជ្រាវដែលពាក់ព័ន្ធនឹងមុខសញ្ញាចំណាយ

យោងតាមការស្រាវជ្រាវ អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០២០ បានរួមបញ្ចូលផ្នែក (ម៉ូឌុល) មួយដែលអាចមានលទ្ធភាពក្នុងការបង្កើតចេញនូវសូចនាករស្តីពីការសិក្សាអប់រំមានដូចជា៖ អក្ខរកម្ម ការទទួលបានការអប់រំ ការចុះឈ្មោះចូលរៀនក្នុងសាលារដ្ឋ សាលាឯកជន និងការចំណាយលើការសិក្សា។ សំណួរទាក់ទងនឹងការសិក្សាអប់រំនេះ ត្រូវបានធ្វើឡើងជាមួយមេគ្រួសារ ដែលសមាជិកទាំងនោះមានអាយុចាប់ពី៣ឆ្នាំឡើងទៅ ត្រូវបានរាប់បញ្ចូលសម្រាប់ការធ្វើសម្ភាសន៍។ ទិន្នន័យសិក្សាអប់រំជាផ្លូវការនៅក្នុងប្រទេសកម្ពុជា គឺផ្អែកយ៉ាងសំខាន់លើព័ត៌មានរដ្ឋបាលដែលបានរៀបចំនៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ក្រៅពីនោះ ក៏មានការសាកសួរក្នុងជំរឿននិងអង្កេតផ្សេងៗ ដូចជាជំរឿនទូទៅនូវប្រជាសាស្ត្រនៃប្រទេសកម្ពុជា អង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា អង្កេតចន្លោះជំរឿនប្រជារាស្ត្រនៅកម្ពុជា។ ការសិក្សានេះ បានប្រើប្រាស់នូវឧបករណ៍វាស់វែង ផ្អែកលើធាតុចំណាយ៧ប្រភេទរួមមាន៖ ចំណាយថ្លៃសាលា ចំណាយថ្លៃគ្រូបង្រៀន ចំណាយថ្លៃសៀវភៅសិក្សា ចំណាយសម្ភារៈសិក្សាផ្សេងៗ ចំណាយលើការសិក្សារបស់ក្មេងដែលទៅសិក្សាឆ្ងាយពីផ្ទះ ការចំណាយថ្លៃធ្វើដំណើរ និងអំណោយជូនគ្រូ ប្រាក់វិភាគទានបង់សម្រាប់សាងសង់អគារ/ការអភិវឌ្ឍ។ លទ្ធផលដែលទទួលបានពីការស្រាវជ្រាវនេះ បង្ហាញឱ្យឃើញគម្លាតនៃការចំណាយតាមកម្រិតថ្នាក់និងឆ្នាំផងដែរ។ ការចំណាយលើការអប់រំមានភាពខុសគ្នាច្រើនរវាងកម្រិតខុសគ្នានៃការអប់រំ។ នៅឆ្នាំ២០១៩/២០ ចំណាយលើការសិក្សាអប់រំរបស់គ្រួសារមានចំនួន៦១៨ ពាន់រៀល គិតជាមធ្យមសម្រាប់កម្រិតថ្នាក់មត្តេយ្យ។ ការចំណាយចំនួន៦៥១ ពាន់រៀល គិតជាមធ្យមសម្រាប់ថ្នាក់បឋមសិក្សា។ សម្រាប់ការអប់រំនៅអនុវិទ្យាល័យគឺមានចំនួនប្រមាណ១.១៤២ ពាន់រៀល គិតជាមធ្យម ហើយក្នុងកម្រិតខ្ពស់បំផុតគឺ និស្សិតបញ្ចប់ការសិក្សា គឺមានចំនួនប្រមាណ៥.៥៤៨ ពាន់រៀល គិតជាមធ្យម។ ក្នុងនោះថ្លៃដើមចំណាយនៃការសិក្សាអប់រំនៅឆ្នាំ២០១៩/២០ បានកើនឡើង បើប្រៀបធៀបទៅនឹងការចំណាយក្នុងឆ្នាំ២០១៤។ ផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវនេះ ក៏បានបង្ហាញថាការចំណាយសម្រាប់ការសិក្សានៅកម្រិតខ្ពស់គឺបានកើនឡើងផងដែរ (ក្រសួងផែនការ, ២០២០)។

យោងតាមការស្រាវជ្រាវ ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ក្រោមមូលនិធិអង្គការឃ្លាំមើលការអប់រំអាស៊ីខាងត្បូងប៉ាស៊ីហ្វិក (២០០៧)សិក្សាពីផលប៉ះពាល់នៃថ្លៃសាលាក្រៅផ្លូវការលើការចំណាយគ្រួសារ ដោយបានបង្ហាញពីគោលបំណងនៃរបាយការណ៍គឺដើម្បីស្វែងយល់ពីចំនួននៃថ្លៃសិក្សាក្រៅផ្លូវការដែលត្រូវបានបង់ដោយឪពុកម្ដាយបញ្ជូនកូនទៅសាលារៀនជារៀងរាល់ឆ្នាំ ផលប៉ះពាល់លើការចំណាយគ្រួសារនៃការរក្សាកុមារនៅក្នុងសាលា និងការយល់ឃើញរបស់ឪពុកម្ដាយអំពីការបង់ថ្លៃទាំងនេះ។ ការស្រាវជ្រាវសម្រាប់របាយការណ៍នេះត្រូវបានធ្វើឡើងក្នុងខេត្តចំនួនបួនក្នុងប្រទេសកម្ពុជាគឺរាជធានីភ្នំពេញ បាត់ដំបង កំពត និងតាកែវ។ ការសិក្សានេះរកឃើញថា ជារៀងរាល់ឆ្នាំឪពុកម្ដាយចំណាយលើការសិក្សា៤ផ្នែកសំខាន់ៗរួមមាន៖ ការចំណាយប្រចាំថ្ងៃ គឺជាមធ្យម ១៩៥,៩០០រៀល (48ដុល្លារ) ការចំណាយថ្លៃសាលារៀនគឺជាមធ្យម១៥១,៥០០រៀល(37ដុល្លារ) ការចំណាយដើមឆ្នាំសិក្សា ជាមធ្យម៧៧,៨០០រៀល (19ដុល្លារ) និងការចំណាយបន្ថែមចំនួន ១៨,៦០០រៀល (4,50 ដុល្លារ) ហើយការចំណាយនេះមានការប្រែប្រួលតាមតំបន់។ ការចំណាយកើនឡើងក្នុងកំឡុងពេលដែលកុមារកំពុងសិក្សាពីកម្រិតថ្នាក់ទី 1-3, 4-6, 7-9 ដែលភាគរយរៀងគ្នាកើនឡើង ៥០%ទៅ៧៦% ជាមូលហេតុនាំឱ្យកុមារបោះបង់ការសិក្សាពីព្រោះឪពុកម្ដាយរបស់ពួកគេគ្មានសមត្ថភាពបញ្ជូនកូនទៅសាលា។ ក្រៅពីនេះ គុណភាពសិក្សា ហើយក៏ដោយសារកុមារត្រូវធ្វើការរកប្រាក់ដើម្បីជួយផ្គត់ផ្គង់គ្រួសារក៏កត្តាសំខាន់នៃការបោះបង់ផងដែរ។

តម្លៃនៃការអប់រំរបស់កូនៗត្រូវពឹងផ្អែកលើស្ថានភាពសេដ្ឋកិច្ចគ្រួសារ។ បើឪពុកម្ដាយមានសេដ្ឋកិច្ចល្អ នោះនឹងមានទំនោរទៅលើការអប់រំល្អ ហើយអាចនឹងរំពឹងថាកូនៗរបស់ពួកគេទទួលបានការអប់រំកម្រិតខ្ពស់។ ដោយឡែក ឪពុកម្ដាយដែលមានវិបត្តិសេដ្ឋកិច្ច អាចរំពឹងថាកូនៗរបស់ពួកគេដែលដល់អាយុចូលរៀននឹងជួយការងាររកប្រាក់ដើម្បីគ្រួសារ ព្រោះដោយសារពួកគេត្រូវគិតពីជីវិតជាមុនសិន។ នេះជាហេតុដើមចមដែលបណ្ដាលឱ្យអត្រាបោះបង់ខ្ពស់ក្នុងចំណោមកុមារក្រីក្រនិងជួបការលំបាក។ កាលណាចំណាយក្រៅផ្លូវការកាន់តែច្រើន អ្វីដែលពិបាកចំពោះកុមារក្រីក្រកំពុងជួបវិបត្តិគ្រួសារ ពួកគេនឹងលែងចាត់ទុកការអប់រំជាកន្លែងផ្ដល់ចំណេះឥតបង់ប្រាក់ទៀតឡើយ ផ្ទុយពីនេះពួកគេនឹងយល់ថាការអប់រំជាទំនិញសម្រាប់តែអ្នកមានលទ្ធភាពទៅវិញ។ ដូចនេះ កុមារទាំងនោះនឹងទទួលរងផងប៉ះពាល់ដល់ផ្លូវ

អារម្មណ៍ និងការសម្រេចចិត្តដោយពួកគេយល់ឃើញខ្លួនឯងថាមិនស័ក្តិសមនឹងទទួលបានការអប់រំនោះឡើយ ដែលបញ្ហាមួយនេះជាប្រភពនៃដើមចមកាន់តែធ្វើឱ្យពួកគេពិបាកក្នុងការចាកចេញពីភាពក្រីក្របានផងដែរ ( NGO Education Partnership, 2007 )។

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវស្តីពី "ការសិក្សាពីមុខសញ្ញាចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ ខេត្តកំពង់ស្ពឺ" មានគោលបំណង ចង់ដឹងពីមុខសញ្ញាចំណាយអំឡុងពេលសិក្សានិងបញ្ហាប្រឈមលើចំណាយការសិក្សារបស់សិស្សានុសិស្សកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ ព្រមទាំងស្វែងរកលទ្ធភាពដែលសាលារៀនអាចចូលរួម ដើម្បីកាត់បន្ថយចំណាយលើការសិក្សារបស់សិស្សានុសិស្ស ជាពិសេសសិស្សមានជីវភាពខ្វះខាតនៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ។ វិធីសាស្ត្រនៃការស្រាវជ្រាវគឺអនុវត្តតាមបែបបរិមាណវិស័យនិងគុណវិស័យ។

## ៣.១ គម្រោងវិភាគ

អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់វិធីសាស្ត្រនៃការស្រាវជ្រាវគឺអនុវត្តតាមបែបបរិមាណវិស័យនិងគុណវិស័យរួមបញ្ចូលគ្នា ពីព្រោះវិធីសាស្ត្រទាំងនេះធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវអាចប្រើប្រាស់ដើម្បីប្រមូលនិងវិភាគទិន្នន័យបានច្បាស់លាស់និងស៊ីជម្រៅជាងការប្រើប្រាស់វិធីសាស្ត្រតែមួយ។ នៅក្នុងការសិក្សាស្រាវជ្រាវតាមវិធីសាស្ត្របែបបរិមាណវិស័យ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរបែបទម្រង់បិទនិងបំពេញចម្លើយខ្លីៗ ដើម្បីអនុញ្ញាតឱ្យអ្នកចូលរួមឆ្លើយមានចម្លើយជ្រើសរើសនិងងាយស្រួលបំពេញចំណេញពេលវេលា។ ដោយឡែក ការសិក្សាស្រាវជ្រាវតាមវិធីសាស្ត្របែបគុណវិស័យ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរបែបទម្រង់បើកសម្រាប់សម្ភាសន៍ ដើម្បីបំពេញនិងស្វែងរកនូវព័ត៌មានកាន់តែជាក់លាក់ថែមទៀត។ ការចុះប្រមូលទិន្នន័យគឺធ្វើនៅអនុវិទ្យាល័យឆាយធុប អនុវិទ្យាល័យត្រពាំងឈូក និង វិទ្យាល័យសម្តេចជាស៊ីមឱ៉ាល់ និងមាតាបិតាសិស្សក្នុងតំបន់ទីរួមខេត្ត តំបន់ប្រជុំជន និងតំបន់ដាច់ស្រយាល ហើយក្រុមគោលដៅបំពេញកម្រងសំណួរមាន៣ប្រភេទគឺ៖ គណៈគ្រប់គ្រងសាលារៀន សិស្ស និងមាតាបិតាសិស្ស។ ស្របតាមផែនការនៃការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងកម្មវិធីសិក្សាព្រមទាំងនិក្ខេបបទមានរយៈពេលកំណត់ច្បាស់លាស់ អ្នកសិក្សាស្រាវជ្រាវអាចបញ្ចប់ការសរសេរនិក្ខេបបទនិងឡើងការពារកិច្ចការស្រាវជ្រាវនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២ តាមផែនការគ្រោងទុក។

## ៣.២ ការប្រមូលទិន្នន័យ

ក្រោយពីទទួលបានលិខិតអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា លេខ២៣៤១ អយក.វជអ ចុះសុក្រ ១៣រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ ចាត់តាំងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ នៃវិទ្យាស្ថានជាតិអប់រំ ឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ។

បន្ទាប់ពីបានឆ្លងយោបល់ជាមួយគ្រូណែនាំគោល និងគ្រូណែនាំរងរួចមក អ្នកសិក្សាស្រាវជ្រាវបានរៀបចំកម្រងសំណួរ ដើម្បីចុះប្រមូលទិន្នន័យ។ មុននឹងសម្រេចជ្រើសរើសយកកម្រងសំណួរជាផ្លូវការ អ្នកស្រាវជ្រាវបានយកកម្រងសំណួរសាកល្បងនោះឱ្យសិស្សបំពេញចំនួន៥នាក់ និងមាតាបិតាសិស្ស៥នាក់ ក្នុងគោលបំណងដើម្បីជានាអំពីប្រសិទ្ធភាពនៃកម្រងសំណួរដែលអាចប្រមូលទិន្នន័យបាន។ ក្រោយពីរកឃើញចំណុចខ្វះខាត អ្នកសិក្សាស្រាវជ្រាវក៏បានពិគ្រោះជាមួយគ្រូដឹកនាំ ដើម្បីកែលម្អនូវកម្រងសំណួរឡើងវិញ។

អ្នកសិក្សាស្រាវជ្រាវ បានចុះជួបជាមួយគណៈគ្រប់គ្រងសាលារៀនដោយផ្ទាល់ដើម្បីជូនលិខិតឧទ្ទេសនាមនិងលិខិតសុំចុះប្រមូលទិន្នន័យ ព្រមទាំងសុំការអនុញ្ញាតជួបជាមួយក្រុមគោលដៅដើម្បីផ្តល់កម្រងសំណួររួមមានគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសិស្សានុសិស្ស។ ក្នុងដំណើរការនេះ ជាដំបូងអ្នកសិក្សាស្រាវជ្រាវបានជួបជាមួយសិស្សដែលបានកំណត់ចំនួនតាមផែនការ រួចផ្តល់ជូនកម្រងសំណួរក្រោមការពន្យល់ណែនាំច្បាស់លាស់ពីអ្នកសិក្សាស្រាវជ្រាវនូវគោលបំណងនៃការស្រាវជ្រាវ និងស្នើសុំឱ្យសិស្សផ្តល់ព័ត៌មានពិតជាក់ស្តែងផងដែរ។ បន្ទាប់ពីបញ្ចប់ការប្រមូលទិន្នន័យ អ្នកសិក្សាស្រាវជ្រាវបានបន្តការសម្ភាសជាមួយនឹងគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនទៀត។ អ្នកសិក្សាស្រាវជ្រាវបានអនុវត្តដូចគ្នា គ្រប់សាលាគោលដៅ ដោយបានកំណត់ពេលវេលាជាក់លាក់។ ដោយឡែក ការសម្ភាសជាមួយមាតាបិតាសិស្សគឺត្រូវបានធ្វើឡើងក្រោយការចុះប្រមូលទិន្នន័យពីសិស្សានុសិស្ស គណៈគ្រប់គ្រងសាលារៀននិងគ្រូបង្រៀនរួចរាល់ ស្របតាមពេលកំណត់ក្រោមកិច្ចសហការល្អពីអាជ្ញាធរដែនដីនិងភាគីពាក់ព័ន្ធផងដែរ។

ការចុះប្រមូលទិន្នន័យ កម្រងសំណួរនិងសម្ភាសន៍ គឺមានរយៈពេលមួយសប្តាហ៍ ហើយអ្នកសិក្សាស្រាវជ្រាវបានប្រមូលកម្រងសំណួរពីអ្នកឆ្លើយតបទៅតាមការកំណត់ជាក់លាក់។

## ៣.៣ ឧបករណ៍ស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី "ការសិក្សាពីមុខសញ្ញាចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ ខេត្តកំពង់ស្ពឺ" អ្នកស្រាវជ្រាវបានប្រើប្រាស់សំណួរ៣ប្រភេទ ក្នុងចុះប្រមូលទិន្នន័យតាមបែបបរិមាណវិស័យនិងគុណវិស័យ ពីគណៈគ្រប់គ្រងសាលារៀន សិស្ស និងមាតាបិតាសិស្ស ដោយផ្អែកលើឯកសារពាក់ព័ន្ធនានាដូចជា សមាសភាគនៃមុខសញ្ញាចំណាយការសិក្សា បញ្ហាប្រឈមលើការចំណាយរបស់សិស្សនិងមាតាបិតា សារៈសំខាន់នៃការចូលរួមរបស់មាតាបិតានិងសាលារៀន តាមទ្រឹស្តីរបស់អ្នកស្រាវជ្រាវផ្សេងៗដូចជា៖ NEP (2007); Bray (1999); ក្រសួងផែនការ (២០២០); Silova (2010); Micklewright (2000); Silova, Budiene, and Bray (2006); Bray and Seng (2005); See e.g. Bray (1999b), (2003a); Foondun (2002); Yoo (2002); Kwok (2004); Yolcu, (2011) ជាដើម ដើម្បីសិក្សាពីមុខសញ្ញាចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ។

អ្នកសិក្សាស្រាវជ្រាវបានបង្កើតឧបករណ៍ស្រាវជ្រាវជាពីរទម្រង់គឺកម្រងសំណួរសម្រាប់បំពេញ និងកម្រងសំណួរសម្រាប់សម្ភាសដែលក្នុងនោះមានកម្រងសំណួរសម្រាប់ឱ្យសិស្សបំពេញ និងកម្រងសំណួរសម្រាប់សម្ភាសគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងមាតាបិតាសិស្ស។ កម្រងសំណួរទាំងនេះ បានបែងចែកដូចតទៅ៖

### ៣.៣.១- កម្រងសំណួរបំពេញសម្រាប់សិស្ស

កម្រងសំណួរដែលប្រើសម្រាប់សិស្សចែកចេញជា៤ផ្នែកគឺ៖

**ផ្នែកទី១៖** ព័ត៌មានប្រជាសាស្ត្រ

មាន៤សំណួរ ដែលទាក់ទងនឹង ភេទ អាយុ កម្រិតថ្នាក់ និងឈ្មោះសាលារៀន។

**ផ្នែកទី២៖** ការឆ្លើយតបរបស់សិស្សទៅលើមុខសញ្ញាចំណាយការសិក្សា

មាន៧សំណួររងតូច ដែលទាក់ទងនឹងមធ្យោបាយធ្វើដំណើររបស់សិស្ស ចំណាយលើការសិក្សាប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ ពេលវេលារៀនគួរក្រៅម៉ោងគិតជាមុខវិជ្ជា ពេលវេលារៀនគួរក្រៅម៉ោងគិតជាថ្ងៃ និងការចំណាយប្រាក់រៀនគួរក្រៅម៉ោង។ ហើយមានសមាសភាគចំនួន៤ ដែលទាក់ទងនឹងការចំណាយគឺការចំណាយប្រចាំថ្ងៃ(៥សំណួរ) ការចំណាយថ្លៃសាលា(៨សំណួរ) ការចំណាយដើមឆ្នាំសិក្សា(៣ចំណុចស្មើនឹង១៥សំណួរ) និងការចំណាយបន្ថែម(៥សំណួរ)។

**ផ្នែកទី៣៖** បញ្ហាប្រឈមលើចំណាយការសិក្សារបស់សិស្ស

មានសមាសភាគចំនួន៣ ដែលទាក់ទងនឹងផលជះនៃមុខសញ្ញាចំណាយការសិក្សាគឺ សតិអារម្មណ៍និងភាពជឿជាក់(៩សំណួរ) សេដ្ឋកិច្ច (៣៤សំណួរ) និងការសម្រេចចិត្ត (៥សំណួរ)។ នៅត្រង់ផ្នែកនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើកម្រិតចង្អុលបង្ហាញនៃកម្រងសំណួរនីមួយៗមានចំនួន៥កម្រិតពីតិចបំផុត(១)ទៅខ្លាំងបំផុត(៥)។ រូបមន្តនិងកម្រិតចង្អុលបង្ហាញតាម Likert Scal មានដូចខាងក្រោម៖

១ គឺ តិចបំផុត

២ គឺ តិច

៣ គឺ មធ្យម

៤ គឺ ខ្លាំង

៥ គឺ ខ្លាំងបំផុត

ការបកស្រាយទៅលើការគណនាពិន្ទុ ពីការប្រមូលទិន្នន័យ ដើម្បីវិភាគលើពិន្ទុមធ្យមភាគនៃសូចនាករនីមួយៗ គឺមានរូបមន្តដូចខាងក្រោម (Wannatawee, K., Worakham, P., Panya, P. 2017)

$$\frac{\text{ពិន្ទុខ្ពស់បំផុត - ពិន្ទុទាបបំផុត}}{\text{ចំនួនកម្រិតចង្អុលបង្ហាញ}} = \frac{5-1}{5} = \frac{4}{5} = 0.80$$

1.00 – 1.80 មានន័យថា បញ្ហាប្រឈមលើចំណាយការសិក្សារបស់សិស្សតិចបំផុត

1.81 – 2.60 មានន័យថា បញ្ហាប្រឈមលើចំណាយការសិក្សារបស់សិស្សមានតិច

2.61 – 3.40 មានន័យថា បញ្ហាប្រឈមលើចំណាយការសិក្សារបស់សិស្សគឺមធ្យម

3.41 – 4.20 មានន័យថា បញ្ហាប្រឈមលើចំណាយការសិក្សារបស់សិស្សគឺខ្លាំង

4.21 – 5.00 មានន័យថា បញ្ហាប្រឈមលើចំណាយការសិក្សារបស់សិស្សគឺខ្លាំងបំផុត

អ្នកស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់សិស្សផ្នែកទី៣ ដើម្បីឱ្យការប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់និងគ្រប់ជ្រុងជ្រោយ។

**ផ្នែកទី៤៖** ការបង្ហាញទស្សនៈរបស់សិស្សលើការចំណាយការសិក្សា

អ្នកស្រាវជ្រាវបានបង្កើតទម្រង់កម្រងសំណួរដើម្បីឱ្យសិស្សឆ្លើយ ក្នុងគោលបំណងចង់បានការប្រមូលទិន្នន័យកាន់តែជាក់លាក់ ទំនុកចិត្ត និងព័ត៌មានគ្រប់ជ្រុងជ្រោយ។ ផ្នែកនេះមាន៤សំណួរ ដែលទាក់ទងនឹងចំណាយការសិក្សារបស់សំខាន់ៗច្រើនជាងគេ ការបញ្ចេញមតិយោបល់របស់សិស្សពីការចូលរួមរបស់សាលារៀន សារៈសំខាន់នៃការចូលរួមកាត់បន្ថយចំណាយ និងសំណូមពររបស់សិស្សជុំវិញការចូលរួមចំណែកកាត់បន្ថយចំណាយនៅសាលារៀន។

**៣.៣.២- កម្រងសំណួរសម្ភាសសម្រាប់មាតាបិតា/អាណាព្យាបាលសិស្ស**

កម្រងសំណួរដែលប្រើសម្រាប់សម្ភាសមាតាបិតា/អាណាព្យាបាលសិស្សចែកចេញជា៤ផ្នែកគឺ៖

**ផ្នែកទី១៖** ព័ត៌មានប្រជាសាស្ត្រ

មាន៩សំណួរ ដែលទាក់ទងនឹងតួនាទី អាយុ មុខរបរ ទីកន្លែងរស់នៅ កម្រិតវប្បធម៌ សមាជិកគ្រួសាររស់នៅជាមួយ ចំនួនកូនកំពុងសិក្សា សមាជិកអាចរកចំណូល និងចំណូលសរុបប្រចាំខែ។

**ផ្នែកទី២៖** ការឆ្លើយតបរបស់មាតាបិតាទៅលើមុខសញ្ញាចំណាយការសិក្សា

មាន២សំណួរ ដែលទាក់ទងនឹងការចំណាយប្រចាំថ្ងៃលើការសិក្សារបស់កូនៗ និងការទទួលបានព័ត៌មានអំពីការចំណាយលើការសិក្សាទាំងនោះ។

**ផ្នែកទី៣៖** បញ្ហាប្រឈមរបស់មាតាបិតាលើចំណាយការសិក្សា

មាន៤សំណួរ ដែលទាក់ទងនឹងស្ថានភាពរបស់កុមារស្ថិតនៅក្នុងឬក្រៅសាលា កាតព្វកិច្ចរបស់សិស្សនៅក្នុងគ្រួសារក្រៅពីការរៀនសូត្រ ការយល់ឃើញរបស់មាតាបិតាលើចំណាយការសិក្សា និងផលជះនៃការចំណាយមកលើការសម្រេចចិត្តរបស់មាតាបិតា។

**ផ្នែកទី៤៖** ការចូលរួមរបស់មាតាបិតាលើចំណាយការសិក្សា

មាន២សំណួរ ដែលទាក់ទងនឹងការបង្ហាញមតិយោបល់របស់មាតាបិតាពីសារៈសំខាន់នៃការចូលរួមលើចំណាយការសិក្សារបស់សិស្ស និង សំណូមពរនានារបស់មាតាបិតាទៅកាន់សាលារៀន ជុំវិញការចំណាយការសិក្សារបស់សិស្ស។

**៣.៣.៣- កម្រងសំណួរសម្ភាសសម្រាប់គណៈគ្រប់គ្រងសាលារៀន**

កម្រងសំណួរដែលប្រើសម្រាប់សម្ភាសន៍គណៈគ្រប់គ្រងសាលារៀនចែកចេញជា៣ផ្នែកគឺ៖

**ផ្នែកទី១៖** ព័ត៌មានប្រជាសាស្រ្ត

មាន៦សំណួរ ដែលទាក់ទងនឹង តួនាទី ភេទ អាយុ ទីកន្លែងបម្រើការងារ កម្រិតវប្បធម៌ និងបទពិសោធន៍ការងារ។

**ផ្នែកទី២៖** ការឆ្លើយតបរបស់គណៈគ្រប់គ្រងលើការចំណាយរបស់សិស្ស

មាន៤សំណួរ ដែលទាក់ទងនឹងបទពិសោធន៍និងការចូលរួមការងារដូចជា ការយល់ឃើញយល់ពីការចំណាយរបស់សិស្ស ផលវិបាកលើការចំណាយរបស់សិស្ស ការរៀបចំផែនការក្នុងការចូលរួមចំណែកកាត់បន្ថយចំណាយការសិក្សា និងការអនុវត្តលើសកម្មភាពនានាជុំវិញការចូលរួមកាត់បន្ថយចំណាយការសិក្សារបស់សិស្ស។

**ផ្នែកទី៣៖** សារៈសំខាន់នៃការចូលរួមរបស់សាលារៀនលើចំណាយការសិក្សារបស់សិស្ស

មាន២សំណួរ ដែលទាក់ទងទៅនឹង សារៈសំខាន់នៃការចូលរួមរបស់សាលារៀន និងការរៀបចំផែនការបន្តផ្តោតលើការកាត់បន្ថយចំណាយ ដើម្បីគាំទ្រនិងជំរុញការសិក្សារបស់សិស្សានុសិស្សនៅតាមសាលារៀន។

**៣.៣.៤- កម្រងសំណួរសម្ភាសសម្រាប់គ្រូបង្រៀន**

**ផ្នែកទី១៖** ព័ត៌មានប្រជាសាស្រ្ត

មាន៧សំណួរ ដែលទាក់ទងនឹង ភេទ អាយុ ទីកន្លែងបម្រើការងារ បង្រៀនថ្នាក់ទី មុខវិជ្ជាបង្រៀន កម្រិតវប្បធម៌ និងបទពិសោធន៍ការងារ។

**ផ្នែកទី២៖ ការឆ្លើយតបរបស់លោកគ្រូអ្នកគ្រូលើការចំណាយរបស់សិស្ស**

មាន៣សំណួរ ដែលទាក់ទងនឹងអ្វីដែលលោកគ្រូអ្នកគ្រូបានដឹងពីការចំណាយរបស់សិស្ស ការដឹងពីបញ្ហាប្រឈមរបស់សិស្ស និងការចូលរួមចំណែករបស់លោកគ្រូអ្នកគ្រូលើការកាត់បន្ថយចំណាយរបស់សិស្ស ជាពិសេសសិស្សក្រីក្រ។

**ផ្នែកទី៣៖ សារៈសំខាន់នៃការចូលរួមរបស់លោកគ្រូអ្នកគ្រូលើចំណាយការសិក្សារបស់សិស្ស**

មាន១សំណួរ ដែលទាក់ទងនឹងការឆ្លើយតបរបស់លោកគ្រូអ្នកគ្រូថាតើការចូលរួមកាត់បន្ថយចំណាយរបស់លោកគ្រូអ្នកគ្រូនឹងផ្តល់ប្រយោជន៍អ្វីខ្លះដល់ការសិក្សានិងលទ្ធផលរបស់សិស្ស។

**៣.៣.៥- ការសង្កេត**

ផ្នែកនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រក្នុងការសង្កេតដើម្បីប្រមូលទិន្នន័យ ដោយការចុះដោយផ្ទាល់តាមសាលាគោលដៅ ដើម្បីដកស្រង់យកនូវព័ត៌មានសំខាន់តាមគោលបំណងបស្រ័ជានបទផងដែរ។

## ៣.៤ ការជ្រើសរើសភាគសំណាក

ការប្រមូលទិន្នន័យ ធ្វើឡើងតាមរយៈកម្រងសំណួរចំនួន៣មធ្យមសិក្សាក្នុងខេត្តកំពង់ស្ពឺ រួមមានអនុវិទ្យាល័យឆាយធុបស្ថិតក្នុងក្រុងច្បារមន អនុវិទ្យាល័យត្រពាំងឈូកស្ថិតក្នុងស្រុកសំរោងទង និងវិទ្យាល័យសម្តេចជាស៊ីមឱរ៉ាល់ស្ថិតក្នុងស្រុកឱរ៉ាល់។ ភាគសំណាកនេះបានកំណត់សាលារៀននៅទីរួមខេត្ត សាលារៀននៅទីប្រជុំជន សាលារៀននៅតំបន់ជួបការលំបាក មានសំណាកចំនួន ១៧៣នាក់ គណៈគ្រប់ គ្រងសាលាចំនួន៨នាក់ គ្រូបង្រៀនចំនួន១៥នាក់ សិស្សចំនួន១៣៥នាក់ និងមាតាបិតាសិស្សចំនួន១៥នាក់។

អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់សំណាក៣ប្រភេទ ដោយប្រើវិធី Purposive Sampling(ជ្រើសរើសសំណាកតាមគោលបំណងរបស់អ្នកស្រាវជ្រាវ) រួមមាន៖ សំណាកទី១គឺ សិស្សមកពីអនុវិទ្យាល័យឆាយធុប ថ្នាក់ទី៧ ថ្នាក់ទី៨ ថ្នាក់ទី៩ ក្នុងមួយកម្រិតថ្នាក់១៥នាក់ សិស្សមកពីអនុវិទ្យាល័យត្រពាំងឈូកថ្នាក់ទី៧ ថ្នាក់ទី៨ ថ្នាក់ទី៩ ក្នុងមួយកម្រិតថ្នាក់ ១៥នាក់ និងសិស្សមកពីវិទ្យាល័យសម្តេចជាស៊ីមឱរ៉ាល់ថ្នាក់ទី៧ ថ្នាក់ទី៨ ថ្នាក់ទី៩ ក្នុងមួយកម្រិតថ្នាក់ ១៥នាក់។ សំណាកទី២គឺ មាតាបិតារបស់សិស្ស នៅតំបន់

ទីរួមខេត្តចំនួន៥នាក់ តំបន់ប្រជុំជនចំនួន ៥នាក់ និងតំបន់ជួបការលំបាកចំនួន ៥នាក់។ សំណាកទី៣គឺ គណៈគ្រប់គ្រងសាលារៀនអនុវិទ្យាល័យឆាយធុបចំនួន ៣នាក់ គណៈគ្រប់គ្រងសាលារៀនអនុវិទ្យាល័យត្រពាំងឈូកចំនួន ២នាក់ និងវិទ្យាល័យសម្តេចជាស៊ីមឱរ៉ាល់ចំនួន ៣នាក់។ សំណាកទី៤គឺ គ្រូបង្រៀនអនុវិទ្យាល័យឆាយធុបចំនួន ៥នាក់ គ្រូបង្រៀនសាលាអនុវិទ្យាល័យត្រពាំងឈូកចំនួន ៥នាក់ និងវិទ្យាល័យសម្តេចជាស៊ីមឱរ៉ាល់ចំនួន ៥នាក់។

**តារាង ៣.១៖ ចំនួនភាគសំណាកនៃការស្រាវជ្រាវ**

| ភាគសំណាក | ថ្នាក់ទី | អនុ.ឆាយធុប (ទីរួមខេត្ត) | អនុ.ត្រពាំងឈូក (ប្រជុំជន) | វិ.សម្តេចជាស៊ីមឱរ៉ាល់ (ដាច់ស្រយាល) | ចំនួនសំណាក |
|---|---|---|---|---|---|
| សិស្ស | ៧ | ១៥នាក់ | ១៥នាក់ | ១៥នាក់ | ៤៥នាក់ |
| | ៨ | ១៥នាក់ | ១៥នាក់ | ១៥នាក់ | ៤៥នាក់ |
| | ៩ | ១៥នាក់ | ១៥នាក់ | ១៥នាក់ | ៤៥នាក់ |
| មាតាបិតាសិស្ស | ៧-៩ | ៥នាក់ | ៥នាក់ | ៥នាក់ | ១៥នាក់ |
| គណៈគ្រប់គ្រងសាលា | ៧-៩ | ៣នាក់ | ២នាក់ | ៣នាក់ | ៨នាក់ |
| គ្រូបង្រៀន | ៧-៩ | ៥នាក់ | ៥នាក់ | ៥នាក់ | ១៥នាក់ |
| សរុបភាគសំណាក | ម.ប.ភ | **៥៣នាក់** | **៥២នាក់** | **៥៣នាក់** | **១៧៣នាក់** |

## ៣.៥ ការវិភាគទិន្នន័យ

ការសិក្សាស្រាជ្រាវនេះ អ្នកសិក្សាបានប្រើប្រាស់វិធីសាស្ត្រវិភាគទិន្នន័យតាមបែបបរិមាណវិស័យនិងគុណវិស័យ។

ការវិភាគបែបបរិមាណវិស័យទិន្នន័យដែលប្រមូលបាន អ្នកសិក្សាស្រាវជ្រាវប្រើប្រាស់វិធីសាស្ត្រដូចជា៖ ប្រើប្រាស់កម្មវិធី SPSS សម្រាប់គណនាស្ថិតិ តម្លៃមធ្យម គំលាតស្តង់ដា និងភាគរយ និងប្រើប្រាស់កម្មវិធី Microsoft Excel សម្រាប់សង់ក្រាប តារាង និងបកស្រាយព័ត៌មានរបស់ភាគសំណាកនីមួយៗ។

ការវិភាគបែបគុណវិស័យ ជាការប្រមូលផ្តុំគំនិត ទស្សនៈ ការយល់ឃើញ និងសំណូមពរនានារបស់អ្នកផ្តល់បទសម្ភាសន៍ដោយចាប់ក្រុមពាក្យ ចំណុចដូចឬប្រហាក់ប្រហែលគ្នា ដើម្បីបន្ថែមព័ត៌មាននិងបង្ហាញការគាំទ្រចំពោះទិន្នន័យនៃការវិភាគតាមបែបបរិមាណវិស័យ។

# ជំពូកទី៤

# លទ្ធផលនិងការពិភាក្សា

# ជំពូកទី៤

# លទ្ធផលនិងការពិភាក្សា

ក្នុងជំពូកទី៤នេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យធ្វើការបកស្រាយលទ្ធផល និងការពិភាក្សានូវអ្វីដែលបានរកឃើញតាមរយៈការបំពេញកម្រងសំណួររបស់សិស្សានុសិស្ស ព្រមទាំងលទ្ធផលដែលទទួលបានពីការសម្ភាសលើក្រុមគោលដៅ ដែលពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវរួមមាន៖ សិស្សានុសិស្ស មាតាបិតា គណៈគ្រប់គ្រង និងលោកគ្រូអ្នកគ្រូ នៅសាលារៀនទាំងបីក្នុងខេត្តកំពង់ស្ពឺគឺ៖ អនុវិទ្យាល័យឆាយធុប អនុវិទ្យាល័យត្រពាំងឈូក និងវិទ្យាល័យសម្តេចជាស៊ីមឱរ៉ាល់។ ជំពូកទី៤នេះ នឹងបង្ហាញនូវចំណុចសំខាន់ៗដែលបានចោទសួរក្នុងសំណួរស្រាវជ្រាវទាក់ទងនឹង មុខសញ្ញាចំណាយលើការសិក្សារបស់សិស្សានុសិស្សកម្រិតមធ្យមសិក្សាបឋមភូមិ បញ្ហាប្រឈមលើចំណាយការសិក្សារបស់សិស្សានុសិស្សកម្រិតមធ្យមសិក្សាបឋមភូមិ និងការចូលរួមរបស់សាលារៀនក្នុងការកាត់បន្ថយលើចំណាយការសិក្សារបស់សិស្សានុសិស្សកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ សម្រាប់លើកយកមកបកស្រាយតាមលទ្ធផលជាក់ស្តែង និងធ្វើការពិភាក្សាវែកញែករវាងលទ្ធផលដែលបានរកឃើញទៅនឹងទ្រឹស្តីដែលបានលើកឡើងដោយអ្នកសិក្សាស្រាវជ្រាវកន្លងមកឱ្យកាន់តែទូលំទូលាយ។

## ៤.១-ការវិភាគទិន្នន័យលើកម្រងសំណួរស្តីពីព័ត៌មានប្រជាសាស្ត្ររបស់សិស្សានុ សិស្ស មាតាបិតា គណៈគ្រប់គ្រងសាលា និងគ្រូបង្រៀន

ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានកំណត់យកវិទ្យាល័យចំនួនបីដែលស្ថិតក្នុងខេត្តកំពង់ស្ពឺ រួមមាន៖ អនុវិទ្យាល័យឆាយធុប អនុវិទ្យាល័យត្រពាំងឈូក និងវិទ្យាល័យសម្តេចជាស៊ីមឱរ៉ាល់។ ក្នុងផ្នែកនេះដែរ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញព័ត៌មានទូទៅរបស់សិស្សានុសិស្ស មាតាបិតា គណៈគ្រប់គ្រងសាលា និងលោកគ្រូអ្នកគ្រូ ដែលជាភាគសំណាគក្នុងសិក្សាស្រាវជ្រាវហើយបានផ្តោតលើព័ត៌មានសំខាន់ៗដូចតទៅ៖ អំពីព័ត៌មានសិស្សលើ ភេទ អាយុ រៀនថ្នាក់ទី និងរៀននៅអនុវិទ្យាល័យ។ អំពីមាតាបិតាលើ អាយុ មុខរបរ ទីកន្លែងរស់នៅ និងកម្រិតវប្បធម៌។អំពីគណៈគ្រប់គ្រងសាលាលើ តួនាទី ភេទ

អាយុ ទីកន្លែងបម្រើការងារ កម្រិតវប្បធម៌ បទពិសោធការងារ។ អំពីគ្រូបង្រៀនលើ ភេទ អាយុ ទីកន្លែងបម្រើការងារ កម្រិតថ្នាក់បង្រៀន មុខវិជ្ជាបង្រៀន កម្រិតវប្បធម៌ និងបទពិសោធការងារ។

### ៤.១.១- ព័ត៌មានប្រជាសាស្ត្ររបស់សិស្សានុសិស្ស

**តារាង ៤.១ ៖ តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់សិស្សានុសិស្ស**

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| ១ | ភេទ | ស្រី | ៨៣ | ៦១.៥០ |
| | | ប្រុស | ៥២ | ៣៨.៥០ |
| | | **សរុប** | **១៣៥** | **១០០** |
| ២ | អាយុ | ១៣ | ៣៣ | ២៤.៤០ |
| | | ១៤ | ៤១ | ៣០.៤០ |
| | | ១៥ | ៤៦ | ៣៤.១០ |
| | | ១៦ | ១៥ | ១១.១០ |
| | | **សរុប** | **១៣៥** | **១០០** |
| ៣ | កម្រិតរៀនថ្នាក់ | ថ្នាក់ទី៧ | ៤៥ | ៣៣.៣០ |
| | | ថ្នាក់ទី៨ | ៤៥ | ៣៣.៣០ |
| | | ថ្នាក់ទី៩ | ៤៥ | ៣៣.៣០ |
| | | **សរុប** | **១៣៥** | **១០០** |
| ៤ | សាលារៀន | អនុ.ឆាយធុប | ៤៥ | ៣៣.៣០ |
| | | អនុ.ត្រពាំងឈូក | ៤៥ | ៣៣.៣០ |
| | | វិ.សម្ដេចជាស៊ីមឱរ៉ាល់ | ៤៥ | ៣៣.៣០ |
| | | **សរុប** | **១៣៥** | **១០០** |

តាមតារាងទិន្នន័យ (៤.១) បង្ហាញថាសិស្សានុសិស្ស ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ មានចំនួនសរុប១៣៥នាក់ ស្រី៨៣នាក់ ស្មើនឹង៦១.៥០% មកពីសាលាអនុវិទ្យាល័យចំនួនបីរួមមានអនុវិទ្យាល័យឆាយធុប អនុវិទ្យាល័យត្រពាំងឈូក និងវិទ្យាល័យសម្ដេចជាស៊ីមឱរ៉ាល់ ដែលសាលានីមួយៗ មានចំនួន៤៥នាក់ ស្មើនឹង៣៣.៣០%។ ក្នុងនោះ សិស្សថ្នាក់ទី៧ ទី៨ និងទី៩ មានចំនួនសរុប៤៥នាក់ ស្មើនឹង៣៣.៣០%។ សម្រាប់អាយុរបស់សិស្សទាំងអស់វិញគឺ អាយុ១៣ឆ្នាំ ចំនួន៣៣នាក់ ស្មើនឹង

២៤.៤០% អាយុ១៤ឆ្នាំ ចំនួន៤១នាក់ ស្មើនឹង៣០.៤០% អាយុ១៥ឆ្នាំ ចំនួន៤៦នាក់ ស្មើនឹង ៣៤.១០% និងអាយុ១៦ឆ្នាំ ចំនួន១៥នាក់ ស្មើនឹង១១.១០%។

### ៤.១.១- ព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតា អាណាព្យាបាលសិស្ស

**តារាង ៤.២ ៖ តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតា អាណាព្យាបាលសិស្ស តាមតួនាទី**

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| ១ | តួនាទី | ឪពុក | ៣ | ២០.០០ |
| | | ម្ដាយ | ៩ | ៦០.០០ |
| | | អាណាព្យាបាលក្រៅពីឪពុកម្ដាយ | ៣ | ២០.០០ |
| | | **សរុប** | **១៥** | **១០០** |

តាមតារាងទិន្នន័យ (៤.២) បង្ហាញថាមាតាបិតាដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ មានចំនួនសរុប១៥នាក់ ដែលមានតួនាទីជាឪពុកចំនួន៣នាក់ ស្មើនឹង២០% ម្ដាយចំនួន៩នាក់ ស្មើនឹង៦០% និងអាណាព្យាបាលក្រៅពីឪពុកម្ដាយ ចំនួន៣នាក់ ស្មើនឹង២០%។

**តារាង ៤.៣ ៖ តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតា អាណាព្យាបាលសិស្ស តាមអាយុ**

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| ២ | អាយុ | ៣០-៣៥ឆ្នាំ | ០ | ០ |
| | | ៣៦-៤០ឆ្នាំ | ៦ | ៤០.០០ |
| | | ៤១-៤៥ឆ្នាំ | ៤ | ២៦.៦៧ |
| | | ៤៦-៥០ឆ្នាំ | ៤ | ២៦.៦៧ |
| | | លើសពី៥០ឆ្នាំ | ១ | ៦.៦៦ |
| | | **សរុប** | **១៥** | **១០០** |

តាមតារាងទិន្នន័យ (៤.៣) បង្ហាញថាមាតាបិតាដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះភាគច្រើនមានអាយុចន្លោះ ៣៦-៤០ឆ្នាំ មានចំនួន៦នាក់ ស្មើនឹង៤០% និងមានអាយុចន្លោះ៤១-៤៥ឆ្នាំ និងអាយុចន្លោះ៤៦-៥០ឆ្នាំមានចំនួន៤នាក់ ស្មើនឹង២៦.៦៧%។

**តារាង ៤.៤ ៖ តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតា អាណាព្យាបាលសិស្ស តាមមុខរបរ**

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| ៣ | មុខរបរ | មេផ្ទះ/នៅផ្ទះ | ៤ | ២៦.៦៧ |
| | | កសិករ | ២ | ១៣.៣៣ |
| | | អាជីករ | ៣ | ២០.០០ |
| | | មន្ត្រីរាជការ | ១ | ៦.៦៧ |
| | | បុគ្គលិកក្រុមហ៊ុន | ០ | ០ |
| | | កម្មករ | ៥ | ៣៣.៣៣ |
| | | ផ្សេងៗ | ០ | ០ |
| | | **សរុប** | **១៥** | **១០០** |

តាមតារាងទិន្នន័យ (៤.៤) បង្ហាញថាមាតាបិតា អាណាព្យាបាលដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះគឺភាគច្រើនជាកម្មកររោងចក្រនិងសំណង់ ដែលមានចំនួន៥នាក់ ស្មើនឹង៣៣.៣៣% និងជាមេផ្ទះឬនៅផ្ទះ មានចំនួន៤នាក់ ស្មើនឹង២៦.៦៧%។ ដោយសារ ខេត្តកំពង់ស្ពឺ ជាទីតាំងភូមិសាស្ត្រអំណោយផល ស្ថិតនៅក្បែររាជធានីភ្នំពេញ និងជិតកំពង់ផែដែនសមុទ្រ មានស្ថានដីធំទូលាយទំនេរច្រើន និងសម្បូរកម្លាំងពលកម្ម ទើបធ្វើឱ្យនយោជក អ្នកវិនិយោគជ្រើសរើសជាគោលដៅ ដោយបង្កើតរោងចក្រជាច្រើន ហើយក៏ជាឱកាសប្រជាជនក្នុងតំបន់ខេត្តកំពង់ស្ពឺបានសម្រេចចិត្តជ្រើសរើសមុខរបរជាកម្មករកាត់ដេរសម្រាប់ជាចំណូលប្រចាំខែ។

**តារាង ៤.៥៖ តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតា អាណាព្យាបាលរបស់សិស្ស តាមទីកន្លែងរស់នៅ**

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| ៤ | ទីកន្លែងរស់នៅ | ក្រុងច្បារមន (តំបន់ទីរួមខេត្ត) | ៥ | ៣៣.៣៣ |
| | | ស្រុកសំរោងទង (តំបន់ប្រជុំជន) | ៥ | ៣៣.៣៣ |
| | | ស្រុកឱរ៉ាល់ (តំបន់ដាច់ស្រយាល) | ៥ | ៣៣.៣៣ |
| | | **សរុប** | **១៥** | **១០០** |

តាមតារាងទិន្នន័យ (៤.៥) បង្ហាញថាមាតាបិតា អាណាព្យាបាលដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះគឺមានទីលំនៅស្ថិតក្នុងក្រុងច្បារមន(តំបន់ទីរួមខេត្ត) ស្រុកសំរោងទង (តំបន់ប្រជុំជន) ស្រុកឱរ៉ាល់ (តំបន់ដាច់ស្រយាល) ដែលមួយតំបន់គឺមានចំនួនសរុប៥នាក់ ស្មើនឹង៣៣.៣៣%។

**តារាង ៤.៦៖ តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតា អាណាព្យាបាល តាមកម្រិតវប្បធម៌**

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| ៥ | កម្រិតវប្បធម៌ | កម្រិតបឋមសិក្សា | ៨ | ៥៣.៣៣ |
| | | កម្រិតបឋមភូមិ | ៣ | ២០.០០ |
| | | កម្រិតទុតិយភូមិ | ៣ | ២០.០០ |
| | | កម្រិតបរិញ្ញាបត្ររង | ០ | ០ |
| | | កម្រិតបរិញ្ញាបត្រ | ១ | ៦.៦៧ |
| | | កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ | ០ | ០ |
| | | **សរុប** | **១៥** | **១០០** |

តាមតារាងទិន្នន័យ(៤.៦) បង្ហាញថាមាតាបិតាដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះគឺភាគច្រើនមានកម្រិតវប្បធម៌ត្រឹមកម្រិតបឋមសិក្សាដែលមានចំនួន៨នាក់ ស្មើនឹង៥៣.៣៣% និងមានចំនួនតិចបំផុតដែលបានបញ្ចប់កម្រិតបរិញ្ញាបត្រ ពោលគឺមានចំនួនត្រឹមតែ១នាក់ ស្មើនឹង៦.៦៧%ប៉ុណ្ណោះ។ ដោយសារស្ថានភាពគ្រួសារលំបាក ពុំមានលទ្ធភាពគ្រប់គ្រាន់ និងចង់សម្រាលបន្ទុកគ្រួសារ ទើបធ្វើឱ្យពួកគាត់សម្រេចចិត្តបោះបង់ការសិក្សាទាំងវ័យក្មេងក្នុងកម្រិតថ្នាក់ទាបបែបនេះ។

**ករណីសិក្សា៖** មាតារបស់សិស្សម្នាក់ មានទីលំនៅស្ថិតក្នុងឃុំញាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មានមុខរបរជាកម្មកររោងចក្របានលើកឡើងថា កាលនោះ (ពេលដែលគាត់នៅសិក្សា) ជីវភាពគ្រួសាររបស់ខ្ញុំមានការលំបាកខ្លាំងដោយសារតែក្នុងគ្រួសារមានសមាជិកច្រើន ប៉ុន្តែពុំមានអ្នកចេញធ្វើការរកចំណូលទេ។ ឪពុកខ្ញុំជាជនពិការ ម្តាយត្រូវនៅផ្ទះមើលថែទាំងកូនតូចៗ ហេតុនេះហើយទើបខ្ញុំសម្រេចចិត្តបោះបង់ការសិក្សាទាំងវ័យក្មេង ដើម្បីរកការងារយកប្រាក់មកផ្គត់ផ្គង់ជីវភាពគ្រួសារ។

**តារាង ៤.៧៖ តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតា តាមសមាជិកគ្រួសាររស់នៅជាមួយ**

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| ៦ | សមាជិកគ្រួសាររស់នៅជាមួយ | ២នាក់ | ១ | ៦.៦៧ |
| | | ៣នាក់ | 0 | 0.00 |
| | | ៤នាក់ | ២ | ១៣.៣៣ |
| | | ៥នាក់ | ៥ | ៣៣.៣៣ |
| | | ៦នាក់ | ៦ | ៤០.០០ |
| | | លើសពី៦នាក់ | ១ | ៦.៦៧ |
| | | **សរុប** | **១៥** | **១០០** |
| | | **មធ្យម** | **៤.២០** | |

តាមតារាងទិន្នន័យ (៤.៧) បង្ហាញថាសមាជិកគ្រួសាររស់នៅជាមួយគឺមានចាប់ពី២នាក់ឡើងទៅ។ ក្នុងនោះមាន៣៣.៣៣% ដែលមានសមាជិកចំនួន៥នាក់ និង១៣.៣៣% ដែលមានសមាជិកចំនួន៤នាក់។ ក្នុងនោះ ជាមធ្យមនៃគ្រួសារដែលបានចូលរួមលើការស្រាវជ្រាវនេះគឺមានចំនួន៤នាក់ផងដែរ។

**តារាង ៤.៨៖ តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតាសិស្ស តាមចំនួនកូនកំពុងសិក្សា**

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| ៧ | ចំនួនកូនកំពុងសិក្សា | ១នាក់ | ២ | ១៣.៣៣ |
| | | ២នាក់ | ៥ | ៣៣.៣៣ |
| | | ៣នាក់ | ៧ | ៤៦.៦៧ |
| | | ៤នាក់ | ១ | ៦.៦៧ |
| | | លើសពី៤នាក់ | 0 | 0 |
| | | **សរុប** | **១៥** | **១០០** |
| | | **មធ្យម** | **២.៤៧** | |

តាមតារាងទិន្នន័យ (៤.៨) បង្ហាញថាមាតាបិតាដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ គឺមានកូនកំពុងសិក្សានៅសាលាចំនួនចាប់ពី១នាក់ដល់៤នាក់។ ក្នុងចំណោមនោះ ៤៦.៦៧%នៃគ្រួសារគឺមានចំនួន៣នាក់ និង ៣៣.៣៣%នៃគ្រួសារគឺមានចំនួន២នាក់ដែលមានកូនកំពុងសិក្សានៅសាលា។ សម្រាប់ការគណនាជាមធ្យមនៃចំនួនកូនកំពុងសិក្សានៅក្នុងសាលារៀនគឺមានចំនួន២នាក់។

**តារាង ៤.៩៖ តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតា អាណាព្យាបាលសិស្ស តាមសមាជិកដែលអាចរកចំណូលបាន**

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| ៨ | សមាជិកដែលអាចរកចំណូលបាន | ១នាក់ | ៦ | ៤០.០០ |
| | | ២នាក់ | ៨ | ៥៣.៣៣ |
| | | ៣នាក់ | ១ | ៦.៦៧ |
| | | ៤នាក់ | ០ | ០ |
| | | លើសពី៤នាក់ | ០ | ០ |
| | | **សរុប** | **១៥** | **១០០** |
| | | **មធ្យម** | **១.៦៧** | |

តាមតារាងទិន្នន័យ (៤.៩) បង្ហាញពីសមាជិកដែលអាចរកចំណូលនៅក្នុងគ្រួសារ។ តាមរយៈការចូលរួមរបស់មាតាបិតា អាណាព្យាបាលលើការសិក្សាស្រាវជ្រាវនេះបង្ហាញថា ៥៣.៣៣% ដែលមានសមាជិក២នាក់គឺអាចរកចំណូលសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។ ក្នុងចំណោមសមាជិកទាំងអស់នៃគ្រួសារ គឺឪពុក និងម្ដាយ ជាអ្នកចេញធ្វើការរកប្រាក់ ឬម្នាក់ក្នុងចំណោមឪពុកម្ដាយ និងកូនច្បងនៃគ្រួសារត្រូវបានចេញធ្វើការងារសម្រាប់រកប្រាក់ដើម្បីផ្គត់ផ្គង់គ្រួសារ។

**ករណីសិក្សា៖** គ្រួសារមួយដែលមានសមាជិក៤នាក់ កំពុងរស់នៅតំបន់ដាច់ស្រយាលនៃស្រុកឱ៉ាល់។ ក្នុងចំណោមសមាជិកគ្រួសារទាំងអស់ មាន២នាក់ដែលអាចរកចំណូលបានគឺឪពុកជាកម្មករសំណង់ និងកូនស្រីទី១ជាកម្មកររោងចក្រ។ ស្របពេលដែលម្ដាយនៅចាំផ្ទះនិងធ្វើការងារដាំស្ល ឯកូនស្រីទី២ កំពុងបន្តការសិក្សាថ្នាក់ទី៨។ គាត់បានបន្ថែមថា ស្ថិតក្នុងស្ថានភាពប្រទេសកំពុងជួបបញ្ហាជំងឺកូវីដ សេដ្ឋកិច្ចមានការប្រែប្រួល ទំនិញឡើងថ្លៃ ហើយការងារដែលប្ដីនិងកូនស្រីច្បងកំពុងធ្វើសព្វថ្ងៃនេះ ក៏មិនបិតថេរ។ មានពេលខ្លះប្ដីរបស់គាត់ឈឺ មិនអាចទៅធ្វើការសំណង់បាន ត្រូវឈប់សម្រាក៣ទៅ៤ថ្ងៃក៏មានដែរ ដូចនេះវាពិតជាពិបាកដោយសារគ្រួសាររបស់ខ្ញុំ។

**តារាង ៤.១០៖ តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់មាតាបិតា អាណាព្យាបាលសិស្ស តាមចំណូលសរុបប្រចាំខែ**

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| ៩ | ចំណូលសរុបប្រចាំខែ | ២០០-៣០០ ដុល្លារ | ៣ | ២០.០០ |
| | | ៣០១-៤០០ ដុល្លារ | ៣ | ២០.០០ |
| | | ៤០១-៥០០ ដុល្លារ | ៦ | ៤០.០០ |
| | | ៥០១-៦០០ ដុល្លារ | ២ | ១៣.៣៣ |
| | | លើសពី៦០០ ដុល្លារ | ១ | ៦.៦៧ |
| | | **សរុប** | **១៥** | **១០០** |

តាមតារាងទិន្នន័យ (៤.១០) បង្ហាញថាគ្រួសារដែលបានចូលរួមលើការសិក្សាស្រាវជ្រាវនេះ មានចំណូលសរុបប្រចាំខែ ៤០% ដែលទទួលបានចន្លោះពី៤០១ទៅ៥០០ ដុល្លារអាមេរិច និង៦.៦៧% ដែលទទួលបានលើសពី៦០០ដុល្លារអាមេរិច។

**៤.១.៣- ព័ត៌មានប្រជាសាស្ត្ររបស់គណៈគ្រប់គ្រងសាលា**

**តារាង ៤.១១ ៖ តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់គណៈគ្រប់គ្រងសាលារៀន**

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| ១ | តួនាទី | នាយក | ៣ | ៣៧.៥០ |
| | | នាយករង/នាយិការង | ៥ | ៦២.៥០ |
| | | **សរុប** | **៨** | **១០០** |
| ២ | ភេទ | ស្រី | ២ | ២៥.០០ |
| | | ប្រុស | ៦ | ៧៥.០០ |
| | | **សរុប** | **៨** | **១០០** |
| ៣ | អាយុ | ២៥-៣០ ឆ្នាំ | ០ | ០ |
| | | ៣១-៣៥ ឆ្នាំ | ២ | ២៥.០០ |
| | | ៣៦-៤០ ឆ្នាំ | ០ | ០ |
| | | ៤១-៥០ ឆ្នាំ | ២ | ២៥.០០ |
| | | លើសពី៥០ ឆ្នាំ | ៤ | ៥០.០០ |
| | | **សរុប** | **៨** | **១០០** |

| | | | | |
|---|---|---|---|---|
| ៤ | ទីកន្លែងបម្រើការងារ | អនុ.ឆាយធុប | ៣ | ៣៧.៥០ |
| | | អនុ.ត្រពាំងឈូក | ២ | ២៥.០០ |
| | | វិ.សម្តេចជាស៊ីមឱ៉ាល់ | ៣ | ៣៧.៥០ |
| | | **សរុប** | **៨** | **១០០** |
| ៥ | កម្រិតវប្បធម៌ | ចប់ថ្នាក់ទី១២ | ៣ | ៣៧.៥០ |
| | | បរិញ្ញាបត្ររង | ០ | ០ |
| | | បរិញ្ញាបត្រ | ៤ | ៥០.០០ |
| | | បរិញ្ញាបត្រជាន់ខ្ពស់ | ១ | ១២.៥០ |
| | | **សរុប** | **៨** | **១០០** |
| ៦ | បទពិសោធការងារ | ១-៥ ឆ្នាំ | ០ | ០ |
| | | ៦-១០ ឆ្នាំ | ១ | ១២.៥០ |
| | | ១១-១៥ឆ្នាំ | ២ | ២៥.០០ |
| | | លើសពី១៥ឆ្នាំ | ៥ | ៦២.៥០ |
| | | **សរុប** | **៨** | **១០០** |

តាមតារាងទិន្នន័យ (៤.១១) បង្ហាញថាគណៈគ្រប់គ្រងសាលាបានចូលរួមលើការស្រាវជ្រាវនេះ មានចំនួនសរុប៨នាក់ រួមមាន នាយកសាលាចំនួន៣៧.៥០% និងនាយករង/នាយិការងមានចំនួន ៦២.៥០% ដែលមានស្រីចូលរួមចំនួន២៥% មកពីសាលាអនុវិទ្យាល័យចំនួនបី រួមមានអនុវិទ្យាល័យ ឆាយធុប និងវិទ្យាល័យសម្តេចជាស៊ីមឱ៉ាល់មានចំនួន៣៧.៥០% និងអនុវិទ្យាល័យត្រពាំងឈូកមាន ចំនួន២៥%។ សម្រាប់ក្រុមអាយុរបស់គណៈគ្រប់គ្រងសាលារៀនវិញគឺ ៥០% ដែលមានអាយុលើសពី ៥០ឆ្នាំ មានតួនាទីជានាយកសាលា។ ចំពោះកម្រិតវប្បធម៌មានចំនួន ៥០% ដែលបានបញ្ចប់កម្រិត បរិញ្ញាបត្រ ៣៧.៥០% បានបញ្ចប់ថ្នាក់ទី១២ និងអ្នកដែលបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួនតិច បំផុតគឺត្រឹមតែ១២.៥០% តែប៉ុណ្ណោះ។ ដោយឡែក ចំពោះបទពិសោធការងារវិញគឺ ៦២.៥០% ដែល បានបម្រើការងារក្នុងវិស័យអប់រំ ដែលមានតួនាទីជាគណៈគ្រប់គ្រងសាលា លើសពី១៥ឆ្នាំ ២៥% មាន បទពិសោធចន្លោះពី១១ ដល់១៥ឆ្នាំ និងយ៉ាងតិចបំផុត ១២.៥០% ក៏មានបទពិសោធលើការងារអប់រំ ចន្លោះចាប់ពី៦ដល់១០ឆ្នាំដែរ។

## ៤.១.៤- ព័ត៌មានប្រជាសាស្ត្ររបស់គ្រូបង្រៀន

**តារាង ៤.១២ ៖ តារាងទិន្នន័យព័ត៌មានប្រជាសាស្ត្ររបស់គ្រូបង្រៀន**

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| ១ | ភេទ | ស្រី | ៩ | ៦០.០០ |
| | | ប្រុស | ៦ | ៤០.០០ |
| | | **សរុប** | **១៥** | **១០០** |
| ២ | អាយុ | ២៥-៣០ ឆ្នាំ | ១ | ៦.៦៧ |
| | | ៣១-៣៥ ឆ្នាំ | ៣ | ២០.០០ |
| | | ៣៦-៤០ ឆ្នាំ | ៤ | ២៦.៦៦ |
| | | ៤១-៥០ ឆ្នាំ | ៧ | ៤៦.៦៧ |
| | | លើសពី៥០ ឆ្នាំ | ០ | ០ |
| | | **សរុប** | **១៥** | **១០០** |
| ៣ | ទីកន្លែងបម្រើការងារ | អនុ.ឆាយឆុប | ៥ | ៣៣.៣៣ |
| | | អនុ.ត្រពាំងឈូក | ៥ | ៣៣.៣៣ |
| | | វិ.សម្តេចជាស៊ីមឱរ៉ាល់ | ៥ | ៣៣.៣៣ |
| | | **សរុប** | **១៥** | **១០០** |
| ៤ | បង្រៀនថ្នាក់ទី | ទី៧ | ៦ | ៤០.០០ |
| | | ទី៨ | ៣ | ២០.០០ |
| | | ទី៩ | ៦ | ៤០.០០ |
| | | **សរុប** | **១៥** | **១០០** |
| ៥ | មុខវិជ្ជាបង្រៀន | គណិតវិទ្យា | ៥ | ៣៣.៣៣ |
| | | រូបវិទ្យា | ៣ | ២០.០០ |
| | | គីមីវិទ្យា | ២ | ១៣.៣៣ |
| | | ជីវៈវិទ្យា | ២ | ១៣.៣៣ |
| | | ភាសាខ្មែរ | ២ | ១៣.៣៣ |
| | | ភាសាអង់គ្លេស | ១ | ៦.៦៧ |
| | | **សរុប** | **១៥** | **១០០** |
| ៦ | កម្រិតវប្បធម៌ | ចប់ថ្នាក់ទី១២ | ៦ | ៤០.០០ |
| | | បរិញ្ញាបត្ររង | ០ | ០ |
| | | បរិញ្ញាបត្រ | ៩ | ៦០.០០ |
| | | បរិញ្ញាបត្រជាន់ខ្ពស់ | ០ | ០ |

| | | | | |
|---|---|---|---|---|
| | | **សរុប** | **១៥** | **១០០** |
| ៧ | បទពិសោធការងារ | ១-៥ ឆ្នាំ | ០ | ០ |
| | | ៦-១០ ឆ្នាំ | ២ | ១៣.១៣ |
| | | ១១-១៥ឆ្នាំ | ៦ | ៤០.០០ |
| | | លើសពី១៥ឆ្នាំ | ៧ | ៤៦.៦៧ |
| | | **សរុប** | **១៥** | **១០០** |

តាមតារាងទិន្នន័យ (៤.១២) បង្ហាញថាគ្រូបង្រៀនបានចូលរួមលើការស្រាវជ្រាវនេះ មានចំនួនសរុប១៥នាក់ ដែលមានស្រីចំនួន ៩នាក់ ស្មើនឹង៦០% មកពីសាលាអនុវិទ្យាល័យចំនួនបីរួមមានអនុវិទ្យាល័យធាយធុប អនុវិទ្យាល័យត្រពាំងឈូក និងវិទ្យាល័យសម្តេចជាស៊ីមឱរ៉ាល់ ដែលសាលានីមួយៗមានចំនួន៥នាក់ ស្មើនឹង៣៣.៣៣%។ សម្រាប់ក្រុមអាយុរបស់គ្រូបង្រៀនវិញគឺ ៤៦.៦៧% ដែលមានអាយុចន្លោះពី៤១ដល់៥០ឆ្នាំ ២៦.៦៦% មានអាយុចន្លោះពី៣៦ដល់៤០ឆ្នាំ និងយ៉ាងតិចបំផុត៦.៦៧%គឺមានអាយុចន្លោះពី២៥ដល់៣០ឆ្នាំ។ ចំពោះកម្រិតថ្នាក់បង្រៀន គឺថ្នាក់ទី៧ មានចំនួន៤០% ថ្នាក់ទី៨ មានចំនួន២០% និងថ្នាក់ទី៩ មានចំនួន៤០%។ ក្នុងចំណោមនោះ មាន៦មុខវិជ្ជាបង្រៀនដែលភាគច្រើន គឺមុខវិជ្ជាគណិតវិទ្យា ស្មើនឹង៣៣.៣៣% បន្ទាប់មករូបវិទ្យាដែលមានចំនួន២០% និងតិចជាងគេស្មើនឹង ៦.៦៧% គឺជាមុខវិជ្ជាភាសាអង់គ្លេស។ ចំពោះកម្រិតវប្បធម៌មានចំនួន ៦០% ដែលបានបញ្ចប់កម្រិតបរិញ្ញាបត្រ និងកម្រិតទាបបំផុតគឺ ៤០% បានបញ្ចប់ថ្នាក់ទី១២។ ដោយឡែក ចំពោះបទពិសោធការងារវិញ គឺ៤៦.៦៧% មានបទពិសោធការងារលើសពី១៥ឆ្នាំ ៤០% មានបទពិសោធចន្លោះពី១១ ដល់១៥ ឆ្នាំ និងយ៉ាងតិចបំផុត ១៣.៣៣% ក៏មានបទពិសោធចន្លោះពី៦ដល់១០ឆ្នាំដែរ។

## ៤.២-ការវិភាគទិន្នន័យលើកម្រងសំណួរស្តីពី មុខសញ្ញាចំណាយលើការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ ខេត្តកំពង់ស្ពឺ

ក្នុងផ្នែកនេះ អ្នកសិក្សាស្រាវជ្រាវបានចងកូដ និងបញ្ចូលទិន្នន័យក្នុងកម្មវិធី SPSS និងបានវិភាគរកភាគរយ តម្លៃមធ្យម គម្លាតស្តង់ដា នៃសូចនាករផ្សេងៗរបស់សិស្សានុសិស្សលើមុខសញ្ញាចំណាយការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ ដែលមាននៅក្នុងកម្រងសំណួរ។

៤.២.១- មុខសញ្ញាចំណាយលើការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ តាមការឆ្លើយតបរបស់សិស្ស

**តារាង ៤.១៣៖ មធ្យោបាយធ្វើដំណើររបស់សិស្សានុសិស្ស**




តាមតារាងទិន្នន័យ(៤.១៣)ខាងលើបានបង្ហាញថា សិស្សានុសិស្សប្រើប្រាស់មធ្យោបាយធ្វើដំណើរដោយម៉ូតូមានចំនួនច្រើនជាងគេរហូតដល់ ៨២.២០ភាគរយ ការជិះកង់ មាន១០.៤០ភាគរយ ការដើរទៅសាលា និងគ្រួសារជូនដំណើរទៅមក មានចំនួន២.២០ភាយរយ។ ដោយឡែក សិស្សដែលសុំអ្នករួមដំណើរឬមិត្តភក្តិជិះជាមួយគឺមានចំនួន៣ភាគរយ។ ការសុំគេជិះឬថ្មើរជើងដើម្បីសាលានេះ មិនមែនមានន័យថា ពួកគេមិនមានលទ្ធភាពទិញកង់ឬម៉ូតូតែមួយនោះទេ គឺអាចមកពីសាលានៅជិតផ្ទះ ឬមូលហេតុផ្សេងៗ។

**តារាង ៤.១៤៖ ការចំណាយលើការសិក្សាជាប្រចាំថ្ងៃ(គិតជារៀល/ដុល្លារ)**

អត្រាប្តូរប្រាក់ ១$ = ៤១០១៛ (អគ្គនាយកដ្ឋានពន្ធដារ, ២០២២)

| ការចំណាយជាប្រចាំថ្ងៃ | អនុ.ឆាយធុប (តំបន់ទីរួមខេត្ត) | អនុ.ត្រពាំងឈូក (តំបន់ប្រជុំជន) | វិ.ឱរ៉ាល់ (តំបន់ដាច់ស្រយាល) | ចំនួនសរុប |
|---|---|---|---|---|
| ចំនួនអ្នកចូលរួម (៧-៩) | ៤៥ | ៤៥ | ៤៥ | **១៣៥** |
| ចំ.មធ្យម (គិតជារៀល) | ៨,៨៥៦ | ៨,៨៤៥ | ៨,៨២៣ | **៨,៨៤០** |
| ចំ.មធ្យម (គិតជាដុល្លារ) | ២.១៦ | ២.១៥ | ២.១៥ | **២.១៥** |
| ចំណាយទាបបំផុត | ៣,០០០ | ២,៥០០ | ៣,០០០ | **២,៥០០** |
| ចំណាយខ្ពស់បំផុត | **១,៥០០០** | **១,៥០០០** | **១,៣០០០** | **១,៥០០០** |

តាមតារាងទិន្នន័យ (៤.១៤) ខាងលើបានបង្ហាញថា ការចំណាយលើការសិក្សារបស់សិស្សជាប្រចាំថ្ងៃគិតជាមធ្យមគឺមានចំនួន៨,៨០០រៀល ស្មើនឹង ២.១៥ ដុល្លារ ដែលរាប់បញ្ចូលលើការចំណាយថ្លៃអាហារបរិភោគ នំចំណី សាំងម៉ូតូ ចំណតកង់ ម៉ូតូ និងការរៀនគួរក្រៅម៉ោងបន្ថែម។ ក្នុងនោះ ការចំណាយដែលទាបជាងគេគឺមានចំនួន២៥០០រៀល ក្នុងមួយថ្ងៃ និងការចំណាយខ្ពស់បំផុតគឺមានចំនួន១៥,០០០រៀលក្នុងមួយថ្ងៃ។

**តារាង ៤.១៥៖ ការចំណាយលើការសិក្សាជាប្រចាំសប្តាហ៍(គិតជារៀល/ដុល្លារ)**

| ការចំណាយជាសប្តាហ៍ | អនុ.ឆាយធុប (តំបន់ទីរួមខេត្ត) | អនុ.ត្រពាំងឈូក (តំបន់ប្រជុំជន) | វិ.ឱរ៉ាល់ (តំបន់ដាច់ស្រយាល) | ចំនួនសរុប |
|---|---|---|---|---|
| **ចំនួនអ្នកចូលរួម (៧-៩)** | ៤៥ | ៤៥ | ៤៥ | **១៣៥** |
| **ចំ.មធ្យម (គិតជារៀល)** | ៥៣,១៣៣ | ៥៣,០៦៦ | ៥២,៩៣៣ | **៥៣,០៤៤** |
| **ចំ.មធ្យម (គិតជាដុល្លារ)** | ១២.៩៦ | ១២.៩៤ | ១២.១៩ | **១២.៩៣** |
| **ចំណាយទាបបំផុត** | ១៨,០០០ | ១៥,០០០ | ១៨,០០០ | **១៥,០០០** |
| **ចំណាយខ្ពស់បំផុត** | **៩០,០០០** | **៩០,០០០** | **៧៨,០០០** | **៩០,០០០** |

តាមតារាងទិន្នន័យ (៤.១៥) ខាងលើបានបង្ហាញថា ការចំណាយលើការសិក្សារបស់សិស្សជាប្រចាំសប្តាហ៍គិតជាមធ្យមគឺមានចំនួន៥,៣០០រៀល ស្មើនឹង ១២.៩៣ ដុល្លារ។ សម្រាប់ការចំណាយដែលទាបបំផុតគឺមានចំនួន ១៥,០០០ រៀល និងការចំណាយដែលខ្ពស់បំផុតគឺមានចំនួន៩០,០០០ រៀល។

**តារាង ៤.១៦៖ ការចំណាយលើការសិក្សាជាប្រចាំខែ(គិតជារៀល/ដុល្លារ)**

| ការចំណាយជាប្រចាំខែ | អនុ.ឆាយធុប (តំបន់ទីរួមខេត្ត) | អនុ.ត្រពាំងឈូក (តំបន់ប្រជុំជន) | វិ.ឱរ៉ាល់ (តំបន់ដាច់ស្រយាល) | ចំនួនសរុប |
|---|---|---|---|---|
| ចំនួនអ្នកចូលរួម (ទី៧-៩) | ៤៥ | ៤៥ | ៤៥ | **១៣៥** |
| ចំ.មធ្យម (គិតជារៀល) | ២១២,៥៣៣ | ២១២,២៦៦ | ២១១,៧៣៣ | **២១២,១៧៧** |
| ចំ.មធ្យម (គិតជាដុល្លារ) | ៥១.៨៣ | ៥១.៧៧ | ៥១.៦៤ | **៥១.៧៥** |
| ចំណាយទាបបំផុត | ៧២,០០០ | ៦០,០០០ | ៧២,០០០ | ៦០,០០០ |
| ចំណាយខ្ពស់បំផុត | ៣៦០,០០០ | ៣៦០,០០០ | ៣១២,០០០ | ៣៦០,០០០ |

យោងតាមតារាងទិន្នន័យ (៤.១៦) ខាងលើបានបង្ហាញថា សិស្សានុសិស្សដែលកំពុងសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិចាប់ពីថ្នាក់ទី៧ដល់ទី៩ ដែលបានចូលរួមលើការសិក្សាស្រាវជ្រាវនេះ មានការចំណាយលើការសិក្សាជាប្រចាំខែគិតជាមធ្យមគឺមានចំនួន២១២,១៧៧ រៀល ស្មើនឹង៥១.៧៥ ដុល្លារអាមេរិក។ ក្នុងចំណោមនោះ ការចំណាយលើការសិក្សាដែលទាបបំផុតគឺមានចំនួន៦០,០០០ រៀល ស្មើនឹង ១៤.៦៣ ដុល្លារអាមេរិក និងការចំណាយលើការសិក្សាដែលខ្ពស់បំផុតគឺមានចំនួន ៣៦០, ០០០ រៀល ស្មើនឹង ៨៧.៨០ ដុល្លារអាមេរិក។

**តារាង ៤.១៧៖ ការសិក្សាគួរក្រៅម៉ោងបន្ថែម (គិតជាម៉ោង)**

| ចំនួនម៉ោង | អនុ.ឆាយធុប (តំបន់ទីរួមខេត្ត) | | អនុ.ត្រពាំងឈូក (តំបន់ប្រជុំជន) | | វិ.ឱរ៉ាល់ (តំបន់ដាច់ស្រយាល) | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ០ | ៥ | ១១,១១ | ២៧ | ៦០,០០ | ៩ | ២០,០០ | ៤១ | **៣០,៣៧** |
| ១ | ២៩ | ៦៤,៤៤ | ១១ | ២៤,៤៤ | ៩ | ២០,០០ | ៤៩ | **៣៦,២៩** |
| ២ | ១១ | ២៤,៤៤ | ៥ | ១១,១១ | ៩ | ២០,០០ | ២៥ | **១៨,៥១** |
| ៣ | ០ | ០ | ២ | ៤,៤៤ | ៥ | ១១,១១ | ៧ | **៥,១៨** |
| ៤ | ០ | ០ | ០ | ០ | ៨ | ១៧,៧៧ | ៨ | **៥,៩២** |
| ៥ | ០ | ០ | ០ | ០ | ៥ | ១១,១១ | ៥ | **៣,៧០** |
| សរុប | **៤៥** | **១០០%** | **៤៥** | **១០០%** | **៤៥** | **១០០%** | **១៣៥** | **១០០%** |

យោងតាមតារាងទិន្នន័យ (៤.១៧) ខាងលើបានបង្ហាញថា សិស្សានុសិស្សដែលកំពុងសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ ចាប់ពីថ្នាក់ទី៧ដល់ទី៩ ដែលបានចូលរួមលើការសិក្សាស្រាវជ្រាវនេះ បានរៀនគួរក្រៅម៉ោងបន្ថែមភាគច្រើនគឺ១ម៉ោងក្នុងមួយថ្ងៃ ដែលមានចំនួនសរុប ៤៩នាក់ ស្មើនឹង៣៦,២៩ ភាគរយ និងសិស្សដែលមានរៀនគួរ ២ម៉ោងក្នុងមួយថ្ងៃ មានចំនួនសរុប ២៥នាក់ ស្មើនឹង១៨,៥១ ភាគរយ និងអ្នកដែលមានរៀនគួរច្រើនម៉ោងបំផុត មានត្រឹមតែ៥នាក់ប៉ុណ្ណោះ ស្មើនឹង៣,៧០ ភាគរយ។ ដោយឡែកសម្រាប់សិស្សនុសិស្សដែលមិនបានរៀនគួរក្រៅម៉ោងបន្ថែមទាល់តែសោះ មានចំនួនសរុប៤១នាក់ ស្មើនឹង ៣០,៣៧ភាគរយ។

**តារាង ៤.១៨៖ ការចំណាយពេលរៀនគួរក្រៅម៉ោង (គិតជាថ្ងៃ)**

| ចំនួនថ្ងៃ | អនុ.ឆាយធុប (តំបន់ទីរួមខេត្ត) | | អនុ.ត្រពាំងឈូក (តំបន់ប្រជុំជន) | | វិ.ឱរ៉ាល់ (តំបន់ដាច់ស្រយាល) | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ០ | ៥ | ១១,១១ | ២៧ | ៦០,០០ | ៩ | ២០,០០ | ៤១ | **៣០,៣៧** |
| ១ | ១៣ | ២៨,៨៨ | ០ | ០ | ០ | ០ | ១៣ | **៩,៦៣** |
| ២ | ១៩ | ៤២,២២ | ៤ | ៨,៨៨ | ០ | ០ | ២៣ | **១៧,០៤** |
| ៣ | ០ | ០ | ០ | ០ | ០ | ០ | ០ | **០** |
| ៤ | ០ | ០ | ០ | ០ | ០ | ០ | ០ | **០** |
| ៥ | ៨ | ១៧,៧៧ | ១៤ | ៣១,១១ | ៣៦ | ៨០,០០ | ៥៨ | **៤២,៩៦** |
| សរុប | **៤៥** | **១០០%** | **៤៥** | **១០០%** | **៤៥** | **១០០%** | **១៣៥** | **១០០%** |

យោងតាមតារាងទិន្នន័យ (៤.១៨) ខាងលើបានបង្ហាញថា សិស្សានុសិស្សដែលបានចូលរួមលើការសិក្សាស្រាវជ្រាវនេះ រៀនគួរក្រៅម៉ោងបន្ថែមភាគច្រើនគឺ៥ថ្ងៃក្នុងមួយសប្តាហ៍ មានចំនួន៥៨នាក់ ស្មើនឹង ៤២,៩៦ ភាគរយ និងសិស្សដែលមានរៀនគួរក្រៅម៉ោង ២ ថ្ងៃក្នុងមួយសប្តាហ៍ មានចំនួន២៣នាក់ ស្មើនឹង ១៧,០៤ ភាគរយ ។ ដោយឡែក សម្រាប់សិស្សដែលមិនបានរៀនគួរក្រៅម៉ោង មានចំនួន៤១ នាក់ ស្មើនឹង ៣០,៣៧ភាគរយ។

**តារាង ៤.១៩៖ ការចំណាយប្រាក់រៀនគួរក្រៅម៉ោងក្នុងមួយមុខវិជ្ជា (គិតជារៀល)**

| រៀល/មុខវិជ្ជា | អនុ.ឆាយធុប (តំបន់ទីរួមខេត្ត) | | អនុ.ត្រពាំងឈូក (តំបន់ប្រជុំជន) | | វិ.ឱរ៉ាល់ (តំបន់ដាច់ស្រយាល) | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ០ | ៥ | ១១,១១ | ២៧ | ៦០ | ៩ | ២០ | ៤១ | **៣០,៣៧** |
| ១០០០ | ៤០ | ៨៨,៨៨ | ១៨ | ៤០ | ៣៦ | ៨០ | ៩៤ | **៦៩,៦៣** |
| សរុប | **៤៥** | **១០០%** | **៤៥** | **១០០%** | **៤៥** | **១០០%** | **១៣៥** | **១០០%** |

យោងតាមតារាងទិន្នន័យ (៤.១៩) ខាងលើបានបង្ហាញថា សិស្សានុសិស្សដែលបានចូលរួមលើការសិក្សាស្រាវជ្រាវនេះ បានចំណាយលើការរៀនគួរក្រៅម៉ោងបន្ថែម ចំនួន១០០០ រៀល ក្នុងមួយមុខវិជ្ជា។

តារាង ៤.២០៖ ការចំណាយប្រចាំថ្ងៃ (គិតក្នុងមួយឆ្នាំសិក្សា)

| ចំណាយប្រចាំថ្ងៃ | អនុ.ឆាយធុប (តំបន់ទីរួមខេត្ត) | អនុ.ត្រពាំងឈូក (តំបន់ប្រជុំជន) | វិ.ឱរ៉ាល់ (តំបន់ដាច់ស្រយាល) | សរុប | ដុល្លារ |
|---|---|---|---|---|---|
| អាហារបរិភោគ/ចំណី | ១,០២៧,២០០ | ១,០០៨,០០០ | ៨៣៥,២០០ | ៩៥៦,៨០០ | ២៣៣.៣៦ |
| គួរក្រៅម៉ោង | ១១៨,៨០០ | ១៣១,២០០ | ៤២៤,៨០០ | ២២៤,៩៣៣ | ៥៤.៨៦ |
| ចំណតកង់ | ១០,៥៦០ | ៤,៣២០ | ១,៩២០ | ៥,៦០០ | ១.៣៦ |
| ចំណតម៉ូតូ | ១៣៤,៤០០ | ១៥៦,០០០ | ៩៦,០០០ | ១២៨,៨០០ | ៣១.៤១ |
| មធ្យោបាយធ្វើដំណើរ | ៥៤៨,៨០០ | ៥៦១,៦០០ | ៤៨២,០០០ | ៥៣០,៨០០ | ១២៩.៤៦ |
| សរុប | ១,៨៣៩,៧៦០ | ១,៨៦១,១២០ | ១,៨៣៩,៩២០ | ១,៨៤៦,៩៣៣ | **៤៥០.៤៧** |




យោងតាមតារាងទិន្នន័យ (៤.២០) ខាងលើបានបង្ហាញថា សិស្សានុសិស្សដែលបានចូលរួមលើការសិក្សាស្រាវជ្រាវនេះបានចំណាយប្រចាំថ្ងៃ មានដូចជា អាហារបរិភោគ/នំចំណី គួរក្រៅម៉ោងបន្ថែម ចំណតកង់ ម៉ូតូ និងមធ្យោបាយធ្វើដំណើរ។ ក្នុងចំណោមនោះ ការទិញអាហារបរិភោគនិងនំចំណីនៅសាលារៀន

គឺមានចំណាយខ្ពស់រហូតដល់ចំនួន ៩៥៦,៨០០រៀល ស្មើនឹង២៣៣.៣៦ ដុល្លារ (៥១.៨១ ភាគរយ)។ ទន្ទឹមនឹងនេះ ការចំណាយលើការប្រើប្រាស់មធ្យោបាយធ្វើដំណើរដោយការចាក់សាំងម៉ូតូ មានចំនួនសរុប ៥៣០,៨០០ រៀល ស្មើនឹង ១២៩.៤៦ ដុល្លារអាមេរិក (២៨.៧៤ ភាគរយ)។ សម្រាប់ទិន្នន័យជារួម សិស្សានុសិស្សដែលបានចូលរួមលើការសិក្សាស្រាវជ្រាវនេះ បានចំណាយលើការសិក្សាប្រចាំថ្ងៃ(គិតក្នុងមួយឆ្នាំសិក្សា) ជាមធ្យមគឺមានចំនួនសរុប១,៨៤៦,៩៣៣ រៀល ស្មើនឹង ៤៥០.៤៧ ដុល្លារអាមេរិក (៨៣.៩៧ ភាគរយ)។

**តារាង ៤.២១៖ ការចំណាយថ្លៃសាលារៀនក្នុងមួយឆ្នាំសិក្សា**

| ចំណាយថ្លៃសាលា | អនុ.ឆាយធុប (តំបន់ទីរួមខេត្ត) | អនុ.ត្រពាំងឈូក (តំបន់ប្រជុំជន) | វិ.ឌិរ៉ាល់ (តំបន់ដាច់ស្រយាល) | សរុប | ដុល្លារ |
|---|---|---|---|---|---|
| **ចំណាយលើគ្រូ** | ០០ | ៧,៩០០ | ០០ | ២,៦៣៣ | ០.៦៤ |
| **ឯកសារបង្រៀន/ទិញមេរៀនគ្រូ** | ៣៩,១១១ | ៦,៥០០ | ០០ | ១៥,២០៤ | ៣.៧១ |
| **ក្រដាសប្រឡង/ឯកសារប្រឡង** | ៣១,៦៣៣ | ៧,៦៣៣ | ១០,៨១១ | ១៦,៦៩៣ | ៤.០៧ |
| **សៀវភៅតាមដាន** | ២០,១៥៦ | ៩,១៧៨ | ០០ | ៩,៧៧៨ | ២.៣៨ |
| **បង់ថ្លៃមធ្យមភាគ** | ០០ | ០០ | ០០ | ០០ | ០០ |
| **ការរៃអង្គាសមូលនិធិ** | ១៨,០០០ | ៦,៥៥៦ | ៨,២០០ | ១០,៩១៩ | ២.៦៦ |
| **អគ្គីសនី** | ៤,៥០០ | ៨,៩០០ | ៤,៥០០ | ៥,៩៦៧ | ១.៤៦ |
| **ផាកពិន័យអវត្តមាន** | ១១១ | ៨០០ | ២០៥ | ៣៧៣ | ០.០៩ |
| **ផាកពិន័យមករៀនយឺត** | ៤០០ | ៨០០ | ១០,២០០ | ៣,៨០០ | ០.៩៣ |
| **សរុប** | ១១៣,៩១១ | ៤៨,២៦៧ | ៣៣,៩១៦ | ៦៥,៣៦៧ | **១៥.៩៤** |




យោងតាមតារាងទិន្នន័យ (៤.២១) ខាងលើបានបង្ហាញថា សិស្សានុសិស្សបានចំណាយលើថ្លៃសាលារៀនគិតជាមធ្យម មានចំនួន៦៥,៣៦៧ រៀល ស្មើនឹង១៥.៩៤ ក្នុងមួយឆ្នាំសិក្សា (២.៩៧ ភាគរយ)។ ការចំណាយដែលខ្ពស់ជាងគេគឺលើក្រដាសប្រឡងឬឯកសារប្រឡងនានា មានចំនួន ១៦,៦៩៣ រៀល ស្មើនឹង៤.០៧ ដុល្លារ (២៥.៥៣ភាគរយ) និងការចំណាយលើឯកសារបង្រៀន/ទិញមេរៀនរបស់គ្រូ ចំនួន១៥,២០៤រៀល ស្មើនឹង ៣.៧១ ដុល្លារ (២៣.២៧ភាគរយ)។ ទន្ទឹមនឹងនេះ ការរៃអង្គាសមូលនិធិក្នុងសាលាក៏ត្រូវបាន ចំណាយក្នុងចំនួន១០,៩១៩រៀល ស្មើនឹង២.៦៦ ដុល្លារ (១៦.៦៩ភាគរយ)។

**តារាង ៤.២២៖ ការចំណាយដើមឆ្នាំសិក្សាក្នុងមួយឆ្នាំសិក្សា (ឯកសណ្ឋានសាលា)**

| ចំណាយថ្លៃ ឯកសណ្ឋានសាលា | អនុ.ឆាយធុប (តំបន់ទីរួមខេត្ត) | អនុ.ត្រពាំងឈូក (តំបន់ប្រជុំជន) | វិ.ឱ៉ាល់ (តំបន់ដាច់ស្រយាល) | សរុប | ដុល្លារ |
|---|---|---|---|---|---|
| ឯកសណ្ឋានប្រចាំថ្ងៃ | ៦៨,៤៨៩ | ៧៥,១៥៦ | ៥១,៥៣៣ | ៦៥,០៥៩ | ១៥.៨៧ |
| ឯកសណ្ឋានកីឡា | ១១,០០០ | ១៩,២២២ | ៨,០០០ | ១២,៧៤១ | ៣.១១ |
| ស្បែកជើងប៉ាត់តាទៅសាលារៀន | ៤៦,៦៦៧ | ២៨,០០០ | ៣៨,៥១១ | ៣៧,៧២៦ | ៩.២០ |
| ស្បែកជើងកីឡា | ១១,៦៨៩ | ០០ | ៤,៣៣៣ | ៥,៣៤១ | ១.៣០ |
| កាតសិស្ស | ៣,៣៣៣ | ៣,៥០០ | ៣,០០០ | ៣,២៧៨ | ០.៨០ |
| សរុប | ១៤១,១៧៨ | ១២៥,៨៧៨ | ១០៥,៣៧៧ | ១២៤,១៤៥ | **៣០.២៨** |




តាមតារាងទិន្នន័យ (៤.២២) ខាងលើបានបង្ហាញថា សិស្សានុសិស្សបានចំណាយដើមឆ្នាំសិក្សាលើឯកសណ្ឋានសាលា ជាមធ្យមចំនួន ១២៤,១៤៥ រៀល ស្មើនឹង ៣០.២៨ ដុល្លារ (៥.៦៤ភាគរយ)។ ក្នុងនោះ ការចំណាយច្រើនជាងគេគឺលើឯកសណ្ឋានប្រចាំថ្ងៃ មានចំនួន៦៥,០៥៩ រៀល ស្មើនឹង១៥.៨៧ ដុល្លារ (៥២.៤១ភាគរយ) និងការចំណាយលើស្បែកជើងប៉ាត់តា មានចំនួន៣៧,៧២៦ ស្មើនឹង៩.២០ ដុល្លារអាមេរិក (៣០.៣៨ភាគរយ)។

**តារាង ៤.២៣៖ ការចំណាយដើមឆ្នាំសិក្សាក្នុងមួយឆ្នាំសិក្សា (ចំណាយលើសម្ភារៈសិក្សា)**

| ចំណាយថ្លៃ សម្ភារៈសិក្សា | អនុ.ឆាយធុប (តំបន់ទីរួមខេត្ត) | អនុ.ត្រពាំងឈូក (តំបន់ប្រជុំជន) | វិ.ឱរ៉ាល់ (តំបន់ដាច់ស្រយាល) | សរុប | ដុល្លារ |
|---|---|---|---|---|---|
| កាបូបស្ពាយ | ៤១,៦៦៧ | ៣៧,៨៤៤ | ៣២,៧៥៦ | ៣៧,៤២២ | ៩.១៣ |
| សៀវភៅសរសេរ | ២៧,១៣៣ | ២៣,០៤៤ | ១៨,៣១១ | ២២,៨៣០ | ៥.៥៧ |
| សៀវភៅអាន | ៥,៥៤៤ | ១,៣០០ | ៤,៦២២ | ៣,៨២២ | ០.៩៣ |
| សៀវភៅលំហាត់ | ១,៣៧៨ | ១,៨៨៦ | ១,០៤៤ | ១,៤៣៣ | ០.៣៥ |
| ប៊ិក ខ្មៅដៃ បន្ទាត់... | ១២,៨៨៩ | ១០,៣៨៨ | ១១,៥១១ | ១១,៥៩៦ | ២.៨៣ |
| គម្របសៀវភៅ | ៣,៨០០ | ២,៤៣៦ | ២,២៦៧ | ២,៨៣៤ | ០.៦៩ |
| សរុប | ៩២,៤១១ | ៧៦,៨៩៨ | ៧០,៥១១ | ៧៩,៩៣៧ | **១៩.៥០** |




តាមតារាងទិន្នន័យ (៤.២៣) ខាងលើបានបង្ហាញថា សិស្សានុសិស្សបានចំណាយដើមឆ្នាំសិក្សាលើសម្ភារៈសិក្សា ជាមធ្យមមានចំនួន ៧៩,៩៣៧ រៀល ស្មើនឹង ១៩.៥០ ដុល្លារអាមេរិក (៣.៦៣ ភាគរយ)។ ក្នុងចំណោមការចំណាយទាំងអស់ សិស្សបានចំណាយថវិកាសម្រាប់ទិញកាបូបស្ពាយគឺច្រើនជាងគេដែលមានចំនួន ៣៧,៤២២ រៀល ស្មើនឹង ៩.១៣ ដុល្លារអាមេរិក (៤៦.៨២ ភាគរយ)។

**តារាង ៤.២៤ ការចំណាយដើមឆ្នាំសិក្សាក្នុងមួយឆ្នាំសិក្សា (ចំណាយលើការចុះឈ្មោះចូលរៀន)**

| ចំណាយថ្លៃចុះឈ្មោះចូលរៀន | អនុ.ឆាយធុប | អនុ.ត្រពាំងឈូក | វិ.ឱរ៉ាល់ | សរុប | ដុល្លារ | ភាគរយ |
|---|---|---|---|---|---|---|
| ពាក្យសុំចូលរៀន | ៥០០ | ៣,៣៣៣ | ០០ | ១,២៧៨ | ០.៣១ | ២០.២៦ |
| សេវាបំពេញទម្រង់ពាក្យចូលរៀន | ០០ | ០០ | ០០ | ០០ | ០០ | ០០ |
| រូបថត | ៤,៧២២ | ៤,៣២២ | ៦,០២២ | ៥,០២២ | ១.២២ | ៧៩.៧៤ |
| បង់កីឡាប្រចាំឆ្នាំ | ០០ | ០០ | ០០ | ០០ | ០០ | ០០ |
| សរុប | ៥,២២២ | ៧,៦៥៥ | ៦,០២២ | ៦,៣០០ | **១.៥៣** | **១០០** |

តាមតារាងទិន្នន័យ (៤.២៤) ខាងលើបានបង្ហាញថា សិស្សានុសិស្សបានចំណាយដើមឆ្នាំសិក្សាលើការចុះឈ្មោះចូលរៀន ជាមធ្យមគឺមានចំនួន ៦,៣០០ រៀល ស្មើនឹង ១.៥៣ ដុល្លារអាមេរិក (០.២៨ ភាគរយ)។ ក្នុងចំណោមនោះសិស្សមានការចំណាយលើរូបថត ចំនួន៥,០២២ រៀល ស្មើនឹង ១.២២ ដុល្លារ (៧៩.៧៤ភាគរយ)និង ពាក្យសុំចូលរៀន ចំនួន១,២៧៨ រៀល ស្មើនឹង ០.៣១ ដុល្លារអាមេរិក (២០.២៦ ភាគរយ)។

**តារាង ៤.២៥ ការចំណាយបន្ថែមក្នុងមួយឆ្នាំសិក្សា**

| ការចំណាយបន្ថែម | អនុ.ឆាយធុប (តំបន់ទីរួមខេត្ត) | អនុ.ត្រពាំងឈូក (តំបន់ប្រជុំជន) | វិ.ឌីរ៉ាល់ (តំបន់ដាច់ស្រយាល) | សរុប | ដុល្លារ |
|---|---|---|---|---|---|
| **ការផ្គត់ផ្គង់សម្ភារៈសិក្សា** | ៥០,៤១១ | ៤១,៥៨៩ | ២៣,៥៤៤ | ៣៨,៥១៥ | ៩.៣៩ |
| **ការផ្គត់ផ្គង់ថ្នាក់រៀន** | ៦,៥០០ | ១១,៩០០ | ៧,៦១១ | ៨,៦៧០ | ២.១១ |
| **ការជួសជុលកង់/ម៉ូតូ** | ២៩,១៥៦ | ១៩,២១១ | ៣២,៣៣៣ | ២៦,៩០០ | ៦.៥៦ |
| **ការជូនអំណោយគ្រូ** | ០០ | ០០ | ០០ | ០០ | ០០ |
| **ការរៀបចំកម្មវិធី** | ០០ | ៣៧១១ | ៤,៦០០ | ២,៧៧០ | ០.៦៨ |
| **សរុប** | ៨៦,០៦៧ | ៧៦,៤១១ | ៦៨,០៨៨ | ៧៦,៨៥៥ | **១៨.៧៤** |



តាមតារាងទិន្នន័យ (៤.២៥) ខាងលើបានបង្ហាញថា សិស្សានុសិស្សបានចំណាយបន្ថែមលើការសិក្សារបស់ពួកគេ គិតជាមធ្យមសរុបមានចំនួន ៧៦,៨៥៥ រៀល ស្មើនឹង ១៨.៧៤ ដុល្លារ (៣.៥០ភាគរយ)។ ការចំណាយទាំងនោះ មានការផ្គត់ផ្គង់សម្ភារៈសិក្សា ចំនួន៣៨,៥១៥ រៀល ស្មើនឹង ៩.៣៩ ដុល្លារ (៥០.១១ភាគរយ)និងការជួសជុលកង់ ម៉ូតូ ចំនួន២៦,៩០០ រៀល ស្មើនឹង ៦.៥៦ ដុល្លារអាមេរិក (៣៥.០១ភាគរយ)។

### ៤.២.២- លទ្ធផលនៃការសិក្សាស្រាវជ្រាវលើមុខសញ្ញាចំណាយលើការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ តាមការឆ្លើយតបរបស់សិស្ស

នៅត្រង់ចំណុចនេះ អ្នកសិក្សាស្រាវជ្រាវនឹងលើកបង្ហាញពីលទ្ធផលសរុបរួមលើការឆ្លើយតបរបស់សិស្ស ដែលទាក់ទងនឹងមុខសញ្ញាចំណាយលើការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ ដោយផ្តោតលើសូចនាករចំនួនបួនរួមមាន៖ ទី១-ការចំណាយប្រចាំថ្ងៃ ទី២-ការចំណាយថ្លៃសាលា ទី៣-ការចំណាយដើមឆ្នាំសិក្សា និងទី៤-ការចំណាយបន្ថែម។

**តារាង ៤.២៦ លទ្ធផលសរុបលើមុខសញ្ញាចំណាយលើការសិក្សា**

| មុខសញ្ញាចំណាយ | អនុ.ឆាយធុប (តំបន់ទីរួមខេត្ត) | អនុ.ត្រពាំងឈូក (តំបន់ប្រជុំជន) | វិ.ឱ៉ាល់ (តំបន់ដាច់ស្រយាល) | សរុប | ដុល្លារ |
|---|---|---|---|---|---|
| **ចំណាយប្រចាំថ្ងៃ** | ១,៨៣៩,៧៦០ | ១,៨៦១,១២០ | ១,៨៣៩,៩២០ | ១,៨៤៦,៩៣៣ | ៤៥០.៤៧ |
| **ចំណាយថ្លៃសាលា** | ១១៣,៩១១ | ៤៨,២៦៧ | ៣៣,៩១៦ | ៦៥,៣៦៧ | ១៥.៩៤ |
| **ចំណាយដើមឆ្នាំ** | ២៣៨,៨១១ | ២១០,៤៣១ | ១៨១,៩១០ | ២១០,៣៨២ | ៥១.៣២ |
| **ចំណាយបន្ថែម** | ៨៦,០៦៧ | ៧៦,៤១១ | ៦៨,០៨៨ | ៧៦,៨៥៥ | ១៨.៧៥ |
| **សរុប** | ២,២៧៨,៥៤៩ | ២,១៩៦,២២៩ | ២,១២៣,៨៣៤ | ២,១៩៩,៥៣៧ | **៥៣៦.៤៨** |
| * ផ.ស.ស សម្រាប់មនុស្សម្នាក់ (២០២២) = ១,៨៤២ ដុល្លារអាមរិក (អគ្គនាយកដ្ឋានពន្ធដារ, ២០២២)<br>* ចំណូលសុទ្ធក្នុងមួយគ្រួសារគិតជាមធ្យមក្នុងមួយខែ = ៥៥១.៧០ ដុល្លារអាមេរិក (ក្រសួងផែនការ,២០២០) | | | | | |




តាមតារាងទិន្នន័យ (៤.២៦) ខាងលើបានបង្ហាញពីមុខសញ្ញាចំណាយលើការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ ជាមធ្យមសរុបចំនួន ២,១៩៩,៥៣៧ រៀល ស្មើនឹង ៥៣៦,៤៨ ដុល្លារក្នុងមួយឆ្នាំសិក្សា។ ក្នុងនោះទៀតសោត សូចនាករដែលបង្ហាញពីការចំណាយច្រើនជាងគេ គឺការចំណាយប្រចាំថ្ងៃដែលមានចំនួន ១,៨៤៦,៩៣៣ រៀល ស្មើនឹង ៤៥០.៤៧ ដុល្លារ(៨៣.៩៧ភាគរយ)។ ការចំណាយប្រចាំថ្ងៃនោះរួមមាន អាហារបរិភោគ/នំចំណី មធ្យោបាយធ្វើដំណើរ ការរៀនគួរក្រៅម៉ោង ចំណតកង់ និងម៉ូតូ។

**៤.២.៣- មុខសញ្ញាចំណាយលើការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ តាមការឆ្លើយតបរបស់មាតាបិតា/ អាណាព្យាបាលសិស្ស**

**តារាង៤.២៧ ការចំណាយជាប្រចាំថ្ងៃ**

| ការចំណាយជាប្រចាំថ្ងៃ | មាតាបិតា (តំបន់ទីរួមខេត្ត) | មាតាបិតា (តំបន់ប្រជុំជន) | មាតាបិតា (តំបន់ដាច់ស្រយាល) | សរុប |
|---|---|---|---|---|
| ចំនួនអ្នកចូលរួម (៧-៩) | ៥ | ៥ | ៥ | ១៥ |
| ចំ.មធ្យម (គិតជារៀល) | ៩,៤០០ | ៨,៨០០ | ៨,៦០០ | ៨,៩៣៣ |
| ចំ.មធ្យម (គិតជាដុល្លារ) | ២.២៩ | ២.១៥ | ២.១០ | ២.១៨ |

តាមតារាងទិន្នន័យ (៤.២៧) ខាងលើបានបង្ហាញថា អ្នកចូលរួមលើការស្រាវជ្រាវដែលជាមាតាបិតាអាណាព្យាបាលសិស្សមានចំនួនសរុប ១៥នាក់ ដោយបានឆ្លើយតបលើការចំណាយប្រចាំថ្ងៃរបស់កូនៗគឺជាមធ្យមចំនួន ៨,៩៣៣ រៀល ស្មើនឹង ២.១៨ ដុល្លារអាមេរិក។

**ករណីសិក្សា៖** ស្ត្រីជាម្តាយរបស់សិស្សម្នាក់ដែលរស់នៅទីរួមខេត្តកំពង់ស្ពឺបានលើកឡើងថា បច្ចុប្បន្ននេះ គាត់មានកូន កំពុងសិក្សាថ្នាក់ទី៩។ ជារៀងរាល់ថ្ងៃ គាត់បានចំណាយលើការសិក្សាកូនចន្លោះពី ៨,០០០រៀល ទៅ១០,០០០ រៀល។ ចំណាយទាំងនេះ ត្រូវបានដឹងថាសម្រាប់សាំងម៉ូតូ ការរៀនគួរ អាហារ និងការទិញសម្ភារៈសិក្សានានា។ មានតិចតួចដែលកូនប្រាប់ថាសុំលុយដើម្បីចំណាយលើការ បង់ថ្លៃសាលា ការរៃអង្គាស ឬការបង្ខិតបង្ខំនានា។ ទន្ទឹមនឹងនេះ អាណាព្យាបាលរបស់សិស្ស ឈ្មោះ រចនា កំពុងសិក្សានៅអនុវិទ្យាល័យមួយក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ផ្តល់កិច្ចសម្ភាសន៍បានឱ្យដឹងថា គាត់ត្រូវចំណាយលើការសិក្សា ចន្លោះពី ៨,០០០ រៀល ទៅ៩,០០០រៀល ក្នុងមួយថ្ងៃ ដោយរាប់បញ្ចូល ទាំងការចំណាយលើសាំងម៉ូតូ ការទិញនំចំណីខ្លះៗ ជាពិសេស គឺការរៀនគួរក្រៅម៉ោងពី៣ទៅ៤មុខ វិជ្ជា។ នៅមានពេលខ្លះ អាចនឹងមានការចំណាយលើសនេះ ប្រសិនបើស្ថិតក្នុងអំឡុងពេល ប្រឡង ឬការ រៃអង្គាស ការចូលបុណ្យក្នុងសាលារៀន។

### ៤.២.៤- មុខសញ្ញាចំណាយលើការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ តាមការឆ្លើយតបរបស់ គណៈគ្រប់គ្រងសាលារៀន

តាមរយៈការឆ្លើយតបរបស់គណៈគ្រប់គ្រងសាលារៀនបានបង្ហាញថា សិស្សានុសិស្សបានចំណាយ ដោយផ្ទាល់និងប្រយោលដូចជា មធ្យោបាយធ្វើដំណើរ ការធ្វើម៉ូតូ កង់ ឯកសណ្ឋាន សម្ភារៈសិក្សា ស្បែកជើង ការស្នាក់នៅ អាហារ មូលនិធិ ការរៀនគួរក្រៅម៉ោង កាតទូរសព្ទ ការផាកពិន័យចំពោះសិស្សមិនបានអនុវត្ត បទបញ្ជាផ្ទៃក្នុងសាលារៀន និងចំណាយខុសគោលដៅមួយចំនួន។ ក្នុងចំណោមការចំណាយទាំងអស់នេះ គណៈគ្រប់គ្រងសាលារៀនបានយកចិត្តទុកដាក់និងសង្កេតពីការចំណាយរបស់សិស្សបានឱ្យដឹងថា ពួកគេ បានចំណាយលើការមុខសញ្ញាសំខាន់ៗដូចជា ឯកសណ្ឋានសាលា មធ្យោបាយធ្វើដំណើរ ការរៀនគួរក្រៅ ម៉ោង ការហូបចំណីអាហារ សុទ្ធតែជាការចំណាយដែលចាំបាច់ និងអាទិភាពសម្រាប់សិស្សគ្រប់គ្នាៗ ដែល ចាត់ទុកថាជាការចំណាយស្ថិតក្នុងកម្រិតខ្ពស់ផងដែរ។

**ករណីសិក្សា៖** លោកនាយកសាលាអនុវិទ្យាល័យស្ថិតក្នុងខេត្តកំពង់ស្ពឺ បានបង្ហើបឱ្យដឹងថា សិស្សកំពុងសិក្សាក្នុងសាលារៀនដែលលោកគ្រប់គ្រងនេះគឺជាសាលារៀនតំបន់ទីរួមខេត្ត ភាគច្រើនជាសិស្សដែលមានឪពុកម្តាយស្ថិតក្នុងជីវភាពកម្រិតមធ្យមឡើងទៅ។ ការចំណាយលើការសិក្សាជាមធ្យមចន្លោះពី ៩,០០០រៀល ទៅ១០,០០០រៀល ដោយបានចំណាយលើមុខសញ្ញាសំខាន់ៗដូចជា ឯកសណ្ឋានដើមឆ្នាំសិក្សារួមមាន ខោសំពត់ អាវ កាតសិស្ស ស្បែកជើង និងការចំណាយប្រចាំថ្ងៃ រួមមាន ចំណតកង់ម៉ូតូ សាំងម៉ូតូ ការរៀនគួរក្រៅម៉ោង នំចំណី អាហារ និងការចូលរួមមូលនិធិបន្តិចបន្តួចតាមសទ្ធារបស់សិស្ស និងការផាកពិន័យដល់សិស្សមិនបានគោរពបទបញ្ជាផ្ទៃក្នុង។ ដោយឡែក ការប្រមូលលុយថ្លៃក្រដាសប្រឡង ការលក់មេរៀន ឬ ការបង់សេវាផ្សេងៗដល់គ្រូបង្រៀន និងសាលារៀន មិនបានសង្កេតឃើញថាសិស្សបានចំណាយជាប្រចាំនោះឡើយ។

### ៤.២.៥- មុខសញ្ញាចំណាយលើការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ តាមការឆ្លើយតបរបស់គ្រូបង្រៀន

តាមរយៈការឆ្លើយតបរបស់គ្រូបង្រៀនដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ បានបង្ហាញថា សិស្សានុសិស្សបានចំណាយលើការញ៉ាំនំចំណីអាហារនៅសាលារៀនច្រើនជាងគេ បន្ទាប់ពីនោះ គឺការរៀនគួរក្រៅម៉ោងបន្ថែម ការចំណាយលើមធ្យោបាយធ្វើដំណើរដោយការចាក់សាំង ការផ្ញើម៉ូតូ កង់ និងការរៃអង្គាសក្នុងសាលារៀនដូចជាថ្ងៃសីលឬតាមភាពចាំបាច់របស់សាលារៀន។

**ករណីសិក្សា៖** លោកស្រី រតនា ជាគ្រូបង្រៀនដែលមានបទពិសោធរយៈពេល១៥ឆ្នាំ តែងតែសង្កេតលើការចំណាយរបស់សិស្សពីមួយឆ្នាំទៅមួយឆ្នាំមានការកើនឡើងជាបន្តបន្ទាប់។ ការចំណាយនៅដើមឆ្នាំសិក្សាមានដូចជា ឯកសណ្ឋានសាលារៀនជាចំណាយចាំបាច់សម្រាប់សិស្សគ្រប់រូបត្រូវទទួលយកជាប្រចាំឆ្នាំ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍គឺការចំណាយប្រចាំថ្ងៃលើការរៀនគួរក្រៅម៉ោង និងការញ៉ាំចំណីអាហារច្រើនលើសចំណាយសម្រាប់មធ្យោបាយធ្វើដំណើរ រួមទាំងការចំណាយផ្សេងៗទៀតផងដែរ។

### ៤.២.៦- មុខសញ្ញាចំណាយលើការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ តាមការសង្កេត

តាមលទ្ធផលនៃការសង្កេតរបស់អ្នកសិក្សាស្រាវជ្រាវបានបង្ហាញថា សិស្សកម្រិតមធ្យមសិក្សាបឋមភូមិទាំងបីសាលានេះគឺ នៅឯកន្លែងចំណតគឺមានបរិមាណម៉ូតូច្រើនជាងកង់លើសពី ៥០ ភាគរយ នៃចំនួនសិស្សសរុប។ ត្រង់នេះមិនមានន័យថាសិស្សទាំងនោះសុទ្ធតែមានជីវភាពធូរធារទាំងអស់នោះទេ ប៉ុន្តែអាចបញ្ជាក់បានទៅលើការចំណាយថ្លៃសាំងច្រើន។ វេលាព្រឹកមុនពេលចូលតម្រង់ជួរសិស្សខ្លះ ញ៉ាំអាហារពេលព្រឹកនៅតូបអ្នកលក់កកកុញ។ ជាពិសេសរាល់ពេលដល់ម៉ោងចេញលើកទី១ សិស្សសម្រុក ប្រជែងគ្នាទៅទិញអាហារ នំចំណី និងភេសជ្ជៈ។ នៅតាមតូបលក់ដូរក្នុងសាលារៀននីមួយៗមានអាហារ នំចំណីជាច្រើនប្រភេទ មានទាំងបាយ មីឆៅ មីធុង នំកញ្ចប់ នំបំពងខ្លាញ់ ទឹកសុទ្ធ និងគ្រឿងភេសជ្ជៈផ្អែម ដែលមានប្រភពផ្សេងៗ ដូចជាផលិតផលប្រទេសចិន ថៃ វៀតណាម ខ្មែរ និងខ្លះទៀតមិនបានស្គាល់ព្រោះមិនមានលេខកូដឬផ្លាកសញ្ញាសម្គាល់។ ដោយឡែក បើនិយាយពីបរិយាកាស ទីធ្លាសាលារៀនវិញ នៅផ្នែកខាងក្រោយពេញដោយគំនរដបទឹកសុទ្ធនិងសំរាមថង់ប្លាស្ទិកដែលសិស្សរើសប្រមូលគរដូចភ្នំ ខ្លះមាននៅថតតុអង្គុយក្នុងថ្នាក់រៀនក៏មាន ដែលសំរាមនេះទើបតែរយៈពេលបីថ្ងៃប៉ុណ្ណោះ។ មានន័យថា សិស្សបានចំណាយលើការញ៉ាំអាហារនំចំណី ទឹកភេសជ្ជៈច្រើនបំផុត។ អ្នកយកចំណតកង់ម៉ូតូ មួយថ្ងៃបីទៅប្រាំរយរៀល និងមានការលើកលែងសម្រាប់អ្នកមានកាតលើកលែងដែលផ្តល់ជូនពីសាលា។

## ៤.៣-ការពិភាក្សាលើមុខសញ្ញាចំណាយលើការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ ខេត្តកំពង់ស្ពឺ

ការចំណាយ គឺមានភាពចាំបាច់បំផុតសម្រាប់សិស្សានុសិស្សគ្រប់រូប ដើម្បីបំពេញលក្ខខណ្ឌនៃដំណើរការសិក្សារៀនសូត្រប្រកបដោយរលូន។ ប្រភពចំណាយសំខាន់ៗទាំងនោះត្រូវបានកើតឡើងពីរដ្ឋាភិបាល អ្នកនយោបាយ អង្គការក្រៅរដ្ឋាភិបាល និងភ្នាក់ងារជំនួយខាងក្រៅ គ្រួសារ សហគមន៍ និងសាលារៀន។ ការអប់រំមានការចំណាយច្រើន ដូចនេះការកំណត់មុខសញ្ញាចំណាយពិតជាសំខាន់ដែលអាចផ្តល់ឱកាសសម្រាប់អ្នកទទួលការអប់រំ និងអ្នកផ្តល់សេវាអប់រំបានប្រមើលមើលឃើញពីការចំណាយចំគោលដៅ និងច្បាស់លាស់ផងដែរ (Bray, 1999)។ ត្រង់ចំណុចនេះ អ្នកសិក្សាស្រាវជ្រាវបានផ្តោតលើការឆ្លើយតបរបស់សិស្សទៅលើសូចនាករបួនសំខាន់គឺ ការចំណាយប្រចាំថ្ងៃ ការចំណាយថ្លៃសាលា ការចំណាយដើមឆ្នាំសិក្សា

និងការចំណាយបន្ថែម។ ផ្អែកលើលទ្ធផលបង្ហាញថា សិស្សានុសិស្សបានចំណាយលើការសិក្សាសរុបជាមធ្យមចំនួន៥៣៦.៤៨ដុល្លារអាមេរិកក្នុងមួយឆ្នាំសិក្សា ខណៈGDPសរុបសម្រាប់មនុស្សម្នាក់ចំនួន ១,៨៤២ ដុល្លារអាមេរិក (អគ្គនាយកដ្ឋានពន្ធដារ, ២០២២)។ បើគិតចំណាយការសិក្សាប្រចាំខែសម្រាប់កូនម្នាក់ចំនួន ៥៩.៦០ ដុល្លារអាមេរិក ខណៈដែលចំណូលសុទ្ធក្នុងមួយគ្រួសារគិតជាមធ្យមក្នុងមួយខែចំនួន ៥៥១.៧០ ដុល្លារអាមេរិក ស្មើនឹង១០.៨០ភាគរយ និងស្មើនឹង ១០.៧២ ភាគរយនៃចំណាយការប្រើប្រាស់ប្រចាំខែគិតជាមធ្យមក្នុងមួយគ្រួសារ(ក្រសួងផែនការ, ២០២០)។ ក្នុងចំណោមសូចនាករទាំងបួនខាងលើនេះ សូចនាករទីមួយដែលមានភាគរយខ្ពស់ជាងគេគឺការចំណាយប្រចាំថ្ងៃ ស្មើនឹង ៨៣.៩៧ ភាគរយ។ ការចំណាយប្រចាំថ្ងៃទៀតសោត មុខសញ្ញាចំណាយដែលមានភាគរយខ្ពស់ជាងគេគឺ អាហារបរិភោគ/នំចំណីស្មើនឹង៥១.៨១ភាគរយ រីឯមធ្យោបាយធ្វើដំណើរ ស្មើនឹង ២៨.៧៤ ភាគរយ គួរក្រៅម៉ោង ស្មើនឹង ១២.១៨ ភាគរយ ចំណតម៉ូតូ ស្មើនឹង៦.៩៧ ភាគរយ ដោយឡែកចំណាយដែលតិចជាងគេគឺចំណតកង់ស្មើនឹង ០.៣០ ភាគរយ។ សូចនាករទីពីរ ការចំណាយដើមឆ្នាំសិក្សា ស្មើនឹង ៩.៥៧ ភាគរយ ក្នុងនោះ ការចំណាយលើឯកសណ្ឋាន ស្មើនឹង ៥៩ ភាគរយ (ឯកសណ្ឋានប្រចាំថ្ងៃ ស្មើនឹង៥២.៤១ភាគរយ ស្បែកជើងប៉ាត់តាស្មើនឹង៣០.៣៨ ភាគរយ ឯកសណ្ឋានកីឡា ស្មើនឹង ១០.២៧ ភាគរយ ស្បែកជើងកីឡា ស្មើនឹង ៤.២៩ភាគរយ កាតសិស្ស ស្មើនឹង២.៦៤ភាគរយ)។ ការចំណាយលើសម្ភារៈសិក្សា ស្មើនឹង ៣៨ ភាគរយ (ការចំណាយលើការបូបស្ពាយ ស្មើនឹង៤៦.៨២ភាគរយ សៀវភៅសរសេរ ស្មើនឹង២៨.៥៦ភាគរយ ប៊ិក ខ្មៅដៃ បន្ទាត់...ស្មើនឹង១៤.៥១ភាគរយ សៀវភៅអាន ស្មើនឹង ៤.៧៧ ភាគរយ ក្រប/គម្របសៀវភៅ ស្មើនឹង ៣.៥៤ ភាគរយ និងសៀវភៅលំហាត់ ស្មើនឹង១.៧៩ ភាគរយ)។ ការចំណាយលើការចុះឈ្មោះចូលរៀន ស្មើនឹង ៣ភាគរយ (ពាក្យសុំចូលរៀន ស្មើនឹង ២០.២៦ភាគរយ និងរូបថត ស្មើនឹង ៧៩.៧៤ភាគរយ)។ សូចនាករទីបី ការចំណាយបន្ថែម ស្មើនឹង៣.៥០ ភាគរយ ក្នុងនោះ ការចំណាយលើការផ្គត់ផ្គត់សម្ភារៈសិក្សា ស្មើនឹង ៥០.១១ ភាគរយ ការជួសជុលកង់/ម៉ូតូ ស្មើនឹង ៣៥.០១ ភាគរយ ការផ្គត់ផ្គង់ថ្នាក់រៀន ស្មើនឹង១១.២៦ ភាគរយ និងការរៀនចំកម្មវិធី ស្មើនឹង ៣.៦៣ ភាគរយ។ សូចនាករទីបួន ការចំណាយថ្លៃសាលារៀន ស្មើនឹង ២.៩៧ ភាគរយ ក្នុងនោះ ក្រដាសប្រឡង/ឯកសារប្រឡង ស្មើនឹង២៥.៥៣ភាគរយ ឯកសារបង្រៀន/ទិញមេរៀនគ្រូ ស្មើ

នឹង ២៣.២៧ភាគរយ ការរៃអង្គាសមូលនិធិ ស្មើនឹង១៦.៦៩ភាគរយ សៀវភៅតាមដាន ស្មើនឹង១៤.៩៣ ភាគរយ អគ្គីសនី ស្មើនឹង៩.១៦ភាគរយ ផាកពិន័យមកយឺត ស្មើនឹង៥.៨៣ភាគរយ ចំណាយលើគ្រូ ស្មើនឹង ៤.០២ ភាគរយ និងការផាកពិន័យអវត្តមាន០.៥៦ភាគរយ។

លទ្ធផលខាងលើនេះ បានសេចក្តីថា មានការសិក្សាគឺត្រូវមានការចំណាយដើម្បីគាំទ្រដល់ការអប់រំ សម្រេចបានការបញ្ចប់នៅគ្រប់កម្រិតថ្នាក់ ស្របនឹងការលើកឡើងរបស់ស្ថាប័នភាពជាដៃគូរអប់រំនៃអង្គការ ក្រៅរដ្ឋាភិបាល (NEP, 2007)។ ការចំណាយប្រចាំថ្ងៃដែលមានភាគរយខ្ពស់ មានន័យថាសិស្សានុសិស្ស បានចំណាយច្រើនជាប្រចាំថ្ងៃ ពិសេសការទិញនំចំណីអាហារបរិភោគ ដោយហេតុថា ផ្ទះសិស្សនៅឆ្ងាយ ពីសាលារៀន ទើបពួកគេត្រូវសម្រាកពេញមួយថ្ងៃនៅទីនោះ ដូចនេះក៏ត្រូវចំណាយប្រាក់សម្រាប់ទិញអាហារ ពេលព្រឹកនិងថ្ងៃត្រង់ផងដែរ។ ម្យ៉ាងវិញទៀត ក្នុងសាលារៀនមានលក់នំចំណីច្រើនសម្បូរបែប ប្លែកៗ ឈ្ងុយ ឆ្ងាញ់ និងសុទ្ធតែជាអាហារពេញនិយមរបស់សិស្ស ដូចជាអាហារបំពង នំកញ្ចប់ និងគ្រឿងភេសជ្ជៈផ្អែមៗ ត្រជាក់ៗ ដែលជាការទាក់ទាញចិត្តរបស់សិស្ស។ ក្រៅពីនោះ ការចំណាយមធ្យោបាយធ្វើដំណើរ ដោយសារតែ ចម្ងាយពីផ្ទះទៅសាលារៀនឆ្ងាយ ទើបមាតាបិតាសិស្សភាគច្រើនបានសម្រេចចិត្តផ្តល់ម៉ូតូសម្រាប់កូនៗជាម ធ្យោបាយ។ ការជិះម៉ូតូត្រូវការចំណាយលើសាំង ស្របពេលស្ថានភាពសង្គមជួបវិបត្តិជំងឺកូវីដ និងមានបញ្ហា វិវាទសង្គ្រាមពិភពលោក ទើបធ្វើឱ្យតម្លៃសាំងឡើងថ្លៃនាំឱ្យការចំណាយរបស់សិស្សកាន់តែកើនច្រើនឡើង។ ដោយឡែក ការរៀនគួរក្រៅម៉ោង ជាការពេញនិយមសម្រាប់សិស្សានុសិស្សស្ទើរគ្រប់កម្រិត។ ការរៀនគួរ ជា ការបំពេញបន្ថែមពីលើម៉ោងសិក្សានៅសាលារដ្ឋ មុខវិជ្ជាដែលពេញនិយមមាន គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងភាសាខ្មែរ ហើយសិស្សខ្លះក៏បានសិក្សាបន្ថែមលើមុខវិជ្ជាភាសាអង់គ្លេស ដោយសិស្សជឿជាក់ថា ការ សិក្សានេះធ្វើឱ្យពួកគេទទួលបានចំណេះដឹងកាន់តែល្អប្រសើរ។ ការលើកឡើងខាងលើនេះ ស្របជាមួយគ្នា ជាមួយនឹង លោក Bray and Seng (2005)។

តាមរយៈការឆ្លើយតបរបស់មាតាបិតា អាណាព្យាបាលសិស្ស គណៈគ្រប់គ្រងសាលារៀន និងគ្រូ បង្រៀន បានបង្ហាញថាការចំណាយសំខាន់ៗ រួមមានការចំណាយប្រចាំថ្ងៃ ការចំណាយដើមឆ្នាំសិក្សា និង ផ្នែកខ្លះនៃថ្លៃសាលារៀន។ ដូចគ្នាទៅនឹងការសិក្សារបស់អង្គការ NEP (2007) និងលោក Bray and Seng

(2005) ការចំណាយដើមឆ្នាំសិក្សាដែលសិស្សត្រូវទិញសម្លៀកបំពាក់ ឯកសណ្ឋានថ្មីសម្រាប់ត្រៀមបើកបវេសនកាល។ សម្លៀកបំពាក់ ឯកសណ្ឋានសាលារៀន គឺជាបទបញ្ជាផ្ទៃក្នុងរបស់សាលានីមួយៗ ដូចជាអាវសខោ សំពត់ពណ៌ខ្មៅ ឬខៀវ សម្ភារៈសិក្សានានា កាតសិស្ស ឬប័ណ្ណសម្គាល់ខ្លួន។ វាជារឿងចាំបាច់ដែលសិស្សត្រូវសម្រេចចិត្តទិញ ដើម្បីគោរពតាមគោលការណ៍របស់សាលា បើពុំដូច្នេះទេនឹងត្រូវទទួលការផាកពិន័យ។ ការចំណាយប្រចាំថ្ងៃ លើការញ៉ាំអាហារ មធ្យោបាយធ្វើដំណើរ និងការរៀនគួរ ផ្ញើកង់ ម៉ូតូ ជាចំណាយចាំបាច់សម្រាប់កុមារគ្រប់រូប។ ជារៀងរាល់ថ្ងៃ សិស្សត្រូវបានបានមាតាបិតា អាណាព្យាបាលឱ្យលុយទៅសាលារៀនជាប្រចាំ សម្រាប់ផ្គត់ផ្គង់ដល់ការសិក្សា ដ្បិតថាសិស្សខ្លះ មិនបានទទួលប្រាក់ទៀងទាត់ ឬគ្រប់គ្រាន់យ៉ាងក៏ដោយ ប៉ុន្តែទាំងអស់នេះសំខាន់ណាស់។ តួយ៉ាង សិស្សដែលមានផ្ទះឆ្ងាយពីសាលាត្រូវជិះម៉ូតូចាក់សាំងប្រសិនបើរួមដំណើរជាមួយមិត្តភក្តិក៏ត្រូវចំណាយថ្លៃសាំងតិចឬច្រើនតាមលទ្ធភាពដែរ។ សម្រាប់សិស្សដែលមិនអាចវិលត្រឡប់ទៅផ្ទះវិញបាន ត្រូវញ៉ាំអាហារនៅក្នុងសាលារៀន ជួនខ្លះពេលចេញលេងមានការញ៉ាំចំណីឬផឹកភេសជ្ជៈនានា។ កុមារក៏ត្រូវបានជ្រើសរើសការរៀនគួរក្រៅម៉ោងបន្ថែម លើមុខវិជ្ជាសំខាន់ៗ ដែលបានក្លាយជាទម្លាប់ទៅហើយ (Bray, 1999)។

## ៤.៤-ការវិភាគទិន្នន័យលើកម្រងសំណួរស្តីពី បញ្ហាប្រឈមលើចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ ខេត្តកំពង់ស្ពឺ

### ៤.៤.១- បញ្ហាប្រឈមលើការចំណាយការសិក្សា តាមការឆ្លើយតបរបស់សិស្ស

**តារាង ៤.២៨៖ បញ្ហាប្រឈមលើផ្នែកសតិអារម្មណ៍និងភាពជឿជាក់**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | ខ្ញុំខ្មាសអៀន/មិនហ៊ានជួបមុខគ្រូ ព្រោះមិនបានរៀនគួរក្រៅម៉ោងជាមួយគាត់ | ២.៦៤ | ០.៤៨ | មធ្យម |
| ២ | ខ្ញុំអវត្តមានច្រើន ព្រោះមិនហ៊ានចូលរៀនមុខវិជ្ជាដែលមិនបានរៀនគួរ | ២.១៦ | ០.៤២ | តិច |
| ៣ | ខ្ញុំមករៀនយឺត ព្រោះសាលាឆ្ងាយពីផ្ទះ | ៣.២៣ | ០.៦៦ | មធ្យម |
| ៤ | ខ្ញុំមានបងប្អូនរៀនច្រើន ចំណាយច្រើន | ៣.៤៤ | ០.៥៥ | ខ្លាំង |

| | | | | |
|---|---|---|---|---|
| ៥ | ខ្ញុំអវត្តមានពេលប្រឡង ព្រោះមិនមានប្រាក់បង់ថ្លៃក្រដាស | ២.១២ | ០.៣២ | តិច |
| ៦ | ខ្ញុំមានអារម្មណ៍តានតឹងនៅពេលដែលសាលាផាកពិន័យសិស្សជាទឹកប្រាក់ | ៣.១៩ | ០.៥១ | មធ្យម |
| ៧ | គ្រូតែងហៅសិស្សដែលមិនបានរៀនគួរជាមួយគាត់ឡើងឈរមុខក្ដារខៀន | ២.១៦ | ០.៣៦ | តិច |
| ៨ | គ្រូបង្រៀនមិនអស់ចំណុច/ខ្លឹមសារ ពន្យល់មិនបានក្បោះក្បាយក្នុងម៉ោងរដ្ឋ | ២.៣៦ | ០.៤៨ | តិច |
| ៩ | គ្រូលម្អៀងរវាងសិស្សរៀនគួរ និងសិស្សមិនបានរៀនគួរជាមួយគាត់ | ២.៣១ | ០.៥៥ | តិច |
| **សរុប** | | **២.៦២** | **០.៥២** | **មធ្យម** |

តាមតារាងទិន្នន័យ (៤.២៨) បង្ហាញពីការឆ្លើយតបរបស់សិស្ស លើបញ្ហាប្រឈមលើផ្នែកសតិអារម្មណ៍និងភាពជឿជាក់ គឺមានបញ្ហាប្រឈមកម្រិតមធ្យម (មធ្យមភាគ ស្មើនឹង២.៦២ និងគម្លាតស្តង់ដាស្មើនឹង ០.៥២)។ ចំពោះសូចនាករ ដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺ សិស្សមានបងប្អូនច្រើន ត្រូវចំណាយថវិកាច្រើន ស្ថិតក្នុងបញ្ហាប្រឈមកម្រិតខ្លាំង(មធ្យមភាគ ស្មើនឹង ៣.៤៤) ហើយសូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ ការអវត្តមានពេលប្រឡង ដោយសារមិនប្រាក់បង់ថ្លៃក្រដាស ស្ថិតក្នុងបញ្ហាប្រឈមកម្រិតតិចបំផុត(មធ្យមភាគ ស្មើនឹង ២.១២)។

**តារាង ៤.២៩៖ បញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើការចំណាយប្រចាំថ្ងៃ**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | អាហារបរិភោគ/នំចំណី | ៤.២៥ | ០.៤៣ | ខ្លាំងបំផុត |
| ២ | គួរក្រៅម៉ោង | ៣.៦៩ | ០.៩១ | ខ្លាំង |
| ៣ | ចំណតកង់ | ២.១៧ | ០.៣៧ | តិច |
| ៤ | ចំណតម៉ូតូ | ៣.១១ | ០.៥៩ | មធ្យម |
| ៥ | មធ្យោបាយធ្វើដំណើរ/កន្លែងស្នាក់នៅ | ៣.៩៣ | ០.៧១ | ខ្លាំង |
| **សរុប** | | **៣.៤៣** | **០.៨១** | **ខ្លាំង** |

តាមតារាងទិន្នន័យ (៤.២៩) បង្ហាញពីការឆ្លើយតបរបស់សិស្ស លើបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើការចំណាយប្រចាំថ្ងៃ គឺមានបញ្ហាប្រឈមកម្រិតខ្លាំង (មធ្យមភាគ ស្មើនឹង៣.៤៣ និងគម្លាតស្តង់ដា ស្មើនឹង ០.៨១)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺការចំណាយលើការបរិភោគអាហារ/នំចំណី ស្ថិតក្នុងបញ្ហាប្រឈមកម្រិតខ្លាំងបំផុត (មធ្យមភាគ ស្មើនឹង ៤.២៥) និងការចំណាយលើមធ្យោបាយធ្វើដំណើរ/ការស្នាក់នៅ ស្ថិតក្នុងបញ្ហាប្រឈមកម្រិតខ្លាំង (មធ្យមភាគ ស្មើនឹង ៣.៩៣)។ ដោយឡែក ការចំណាយលើការរៀនគួរក្រៅម៉ោងបន្ថែម ស្ថិតក្នុងបញ្ហាប្រឈមកម្រិតខ្លាំង (មធ្យមភាគ ស្មើនឹង ៣.៦៩) ហើយសូចនាករដែលទទួលបានពិន្ទុទាបជាងគឺ ការចំណាយលើចំណតកង់ ដែលស្ថិតក្នុងបញ្ហាប្រឈមកម្រិតតិច(មធ្យមភាគ ស្មើនឹង ២.១៧)។

**តារាង ៤.៣០៖ បញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើការចំណាយថ្លៃសារៀន**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | ចំណាយលើគ្រូបង្រៀន | ២.៣៩ | ០.៤៩ | តិច |
| ២ | ឯកសារបង្រៀន/ទិញមេរៀនគ្រូ | ២.៤៧ | ០.៩៦ | តិច |
| ៣ | ក្រដាសប្រឡង/ឯកសារប្រឡង | ២.៨៥ | ០.៦២ | មធ្យម |
| ៤ | សៀវភៅតាមដាន | ២.០៨ | ០.៨២ | តិច |
| ៥ | ការរៃអង្គាសមូលនិធិ | ៣.២៤ | ០.៤២ | មធ្យម |
| ៦ | អគ្គិសនី | ២.៥៤ | ០.៥១ | តិច |
| ៧ | ផាកពិន័យវត្តមានជាទឹកប្រាក់ | ២.២១ | ០.៤៣ | តិច |
| ៨ | ផាកពិន័យមករៀនយឺត | ២.២៤ | ០.៧៤ | តិច |
| **សរុប** | | **២.៥០** | **០.៣៨** | **តិច** |

តាមតារាងទិន្នន័យ (៤.៣០) បង្ហាញពីការឆ្លើយតបរបស់សិស្ស លើបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើការចំណាយថ្លៃសាលារៀនគឺមានបញ្ហាប្រឈមកម្រិតតិច (មធ្យមភាគ ស្មើនឹង ២.៥០ និងមានគម្លាតស្តង់ដា ០.៣៨)។ ក្នុងចំណោមនោះ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺការចំណាយលើការអែអង្គាសមូលនិធិនៅក្នុងសាលារៀន ដែលស្ថិតក្នុងបញ្ហាប្រឈមកម្រិតមធ្យម (មធ្យមភាគ ស្មើនឹង ៣.២៤) ហើយសូចនាករដែលទទួលបានពិន្ទុទាបជាងគេនោះគឺ ការចំណាយលើសៀវភៅតាមដាន ដែលស្ថិតក្នុងបញ្ហាប្រឈមកម្រិតតិច(មធ្យមភាគ ស្មើនឹង ២.០៨)។

**តារាង៤.៣១៖ បញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើការចំណាយដើមឆ្នាំសិក្សា (ឯកសណ្ឋានសាលា)**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | ឯកសណ្ឋានប្រចាំថ្ងៃ | ៣.១២ | ០.៣៤ | មធ្យម |
| ២ | ឯកសណ្ឋានកីឡា | ២.៤៧ | ០.៥០ | តិច |
| ៣ | ស្បែកជើងប៉ាត់តាទៅសាលា | ២.៨៤ | ០.៣៦ | មធ្យម |
| ៤ | ស្បែកជើងកីឡា | ២.២៩ | ០.៥៩ | តិច |
| ៥ | កាតសិស្ស | ២.៣៦ | ០.៤៨ | តិច |
| **សរុប** | | **២.៦២** | **០.៣៥** | **មធ្យម** |

យោងតាមតារាងទិន្នន័យ (៤.៣១) បានបង្ហាញពីការឆ្លើយតបរបស់សិស្ស លើបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើការចំណាយដើមឆ្នាំសិក្សា (ឯកសណ្ឋានសាលា)គឺមានបញ្ហាប្រឈមកម្រិតមធ្យម (មានមធ្យមភាគ ស្មើនឹង២.៦២ និងមានគម្លាតស្តង់ដា ស្មើនឹង ០.៣៥)។ ក្នុងចំណោមនោះ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺការចំណាយលើឯកសណ្ឋានប្រចាំថ្ងៃ ដែលស្ថិតក្នុងបញ្ហាប្រឈមកម្រិតមធ្យម (មានមធ្យមភាគស្មើនឹង ៣.១២ និងគម្លាតស្តង់ដា ស្មើនឹង០.៣៤) ហើយសូចនាករដែលទទួលបានពិន្ទុទាបជាងគេនោះគឺ ការចំណាយលើស្បែកជើងកីឡា ដែលស្ថិតក្នុងបញ្ហាប្រឈមកម្រិតតិច(មានមធ្យមភាគ ស្មើនឹង ២.២៩ និងគម្លាតស្តង់ដា ស្មើនឹង០.៥៩)។

តារាង ៤.៣២៖ បញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើការចំណាយដើមឆ្នាំសិក្សា (សម្ភារៈសិក្សា)

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | កាបូបស្ពាយ | ២.៨១ | ០.៥៧ | មធ្យម |
| ២ | សៀវភៅសរសេរ | ២.៦៤ | ០.៤៨ | មធ្យម |
| ៣ | សៀវភៅអាន | ២.២៧ | ០.៤៦ | តិច |
| ៤ | សៀវភៅលំហាត់ | ២.១៩ | ០.៣៩ | តិច |
| ៥ | ប៊ិក ខ្មៅដៃ បន្ទាត់ | ២.៨៥ | ០.៣៧ | មធ្យម |
| ៦ | គម្របសៀវភៅ/អ៊ុតសៀវភៅ | ២.០៤ | ០.៣៧ | តិច |
| **សរុប** | | **២.៤៧** | **០.៣៤** | **តិច** |

យោងតាមតារាងទិន្នន័យ (៤.៣២)បានបង្ហាញពីការឆ្លើយតបរបស់សិស្ស លើបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើការចំណាយដើមឆ្នាំសិក្សា (ផ្នែកសម្ភារៈសិក្សា)គឺស្ថិតក្នុងបញ្ហាប្រឈមកម្រិតតិច (មធ្យមភាគ ស្មើនឹង ២.៤៧ និងគម្លាតស្តង់ដា ស្មើនឹង០.៣៤)។ ក្នុងចំណោមនោះ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺការចំណាយលើសម្ភារៈសិក្សាដូចជា ប៊ិក ខ្មៅដៃ បន្ទាត់ ជ័រលុប ទឹកលុប ដៃកឈាន... ស្ថិតក្នុងបញ្ហាប្រឈមកម្រិតមធ្យម (មធ្យមភាគ ស្មើនឹង២.៨៥ និងគម្លាតស្តង់ដា ស្មើនឹង០.៣៧)។ ទន្ទឹមនឹងនេះផងដែរ ការចំណាយលើកាបូបស្ពាយសម្រាប់ដាក់សម្ភារៈសិក្សាគឺស្ថិតក្នុងបញ្ហាប្រឈមកម្រិតមធ្យម (មធ្យមភាគ ស្មើនឹង២.៨១ និងគម្លាតស្តង់ដា ស្មើនឹង០.៥៧)។ ដោយឡែក សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ ការចំណាយលើក្រុបសៀវភៅ ស្ថិតក្នុងបញ្ហាប្រឈមកម្រិតតិច(មធ្យមភាគ ស្មើនឹង ២.០៤ និងគម្លាតស្តង់ដា ស្មើនឹង ០.៣៧)។

តារាង៤.៣៣ បញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើការចំណាយដើមឆ្នាំសិក្សា (ការចុះឈ្មោះចូលរៀន)

| ល.រ | បរិយាយ | មធ្យម | គម្លាត ស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | ពាក្យសុំចូលរៀន | ១.៩៥ | ០.៧៩ | តិច |
| ២ | រូបថត | ២.៥៣ | ០.៥៣ | តិច |
| **សរុប** | | **២.២៤** | **០.៤១** | **តិច** |

តាមតារាងទិន្នន័យ (៤.៣៣) បង្ហាញពីការឆ្លើយតបរបស់សិស្ស លើបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើការចំណាយដើមឆ្នាំសិក្សា (ការចុះឈ្មោះចូលរៀន) គឺមានបញ្ហាប្រឈមកម្រិតតិច(មធ្យមភាគ ស្មើនឹង ២.២៤ និងគម្លាតស្តង់ដា ស្មើនឹង០.៤១)។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ ពាក្យសុំចូលរៀន ស្ថិតក្នុងបញ្ហាប្រឈមកម្រិតតិច(មធ្យមភាគ ស្មើនឹង ១.៩៥)។

**តារាង៤.៣៤៖ បញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើការចំណាយបន្ថែម**

| ល.រ | បរិយាយ | មធ្យម | គម្លាត ស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | ការផ្គត់ផ្គង់សម្ភារៈសិក្សា | ២.៨៤ | ០.៥០ | មធ្យម |
| ២ | ការផ្គត់ផ្គង់ថ្នាក់រៀន | ២.៣៩ | ០.៥៣ | តិច |
| ៣ | ការជួសជុលកង់/ម៉ូតូ | ២.៩៩ | ០.៧១ | មធ្យម |
| ៤ | ការរៀបចំកម្មវិធី | ២.៣០ | ០.៤៦ | តិច |
| **សរុប** | | **២.៦៣** | **០.៣៣** | **មធ្យម** |

តាមតារាងទិន្នន័យ (៤.៣៤) បង្ហាញពីការឆ្លើយតបរបស់សិស្ស លើបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើ ការចំណាយបន្ថែមគឺមានបញ្ហាប្រឈមកម្រិតមធ្យម(មធ្យមភាគ ស្មើនឹង២.៦៣ និងគម្លាតស្តង់ដា ស្មើនឹង ០.៣៣)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺការចំណាយលើការជួសជុលម៉ូតូ ស្ថិតក្នុងបញ្ហាប្រឈមកម្រិតមធ្យម (មធ្យមភាគ ស្មើនឹង២.៩៩)។ ហើយសូចនាករដែលទទួលបានពិន្ទុទាបជាងគេនោះគឺ ការរៀបចំកម្មវិធី ស្ថិតក្នុងបញ្ហាប្រឈមកម្រិតតិច (មធ្យមភាគ ស្មើនឹង ២.៣០)។

តារាង ៤.៣៥៖ បញ្ហាប្រឈមលើការសម្រេចចិត្ត

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | ខ្ញុំចង់ឈប់រៀនដើម្បីធ្វើការរកប្រាក់ជួយគ្រួសារ | ២.៨១ | ០.៥៧ | មធ្យម |
| ២ | ខ្ញុំចង់ឈប់រៀនដើម្បីជួយធ្វើការងារផ្ទះ | ២.៤៧ | ០.៥០ | តិច |
| ៣ | ខ្ញុំចង់ផ្អាកការសិក្សាមួយរយៈដើម្បីរកប្រាក់ផ្គត់ផ្គង់ការរៀនសូត្រ | ២.៦៣ | ០.៤៨ | មធ្យម |
| ៤ | ដោយសារភាពខ្មាសអៀនគ្រូ/មិត្តភក្តិ ទើបខ្ញុំមិនចង់ទៅសាលា | ២.៥៨ | ០.៤៩ | តិច |
| ៥ | ឪពុកម្តាយខ្ញុំបង្ខំឱ្យឈប់រៀនដោយសារមានការចំណាយច្រើន | ២.៨៨ | ០.៦១ | មធ្យម |
| **សរុប** | | **២.៦៧** | **០.១៦** | **មធ្យម** |

តាមតារាងទិន្នន័យ(៤.៣៥) បង្ហាញពីការឆ្លើយតបរបស់សិស្សលើបញ្ហាប្រឈមលើការសម្រេចចិត្ត គឺមានបញ្ហាប្រឈមកម្រិតមធ្យម (មធ្យមភាគ ស្មើនឹង២.៦៧ និងគម្លាតស្តង់ដា ស្មើនឹង០.១៦)។ ក្នុងចំណោមសូចនាករទាំងអស់ដែលទទួលបានពិន្ទុខ្ពស់ជាងគេ គឺសិស្សត្រូវបានឪពុកម្តាយបង្ខំឱ្យឈប់រៀនដោយសារមានការចំណាយច្រើន ស្ថិតក្នុងបញ្ហាប្រឈមកម្រិតមធ្យម (មធ្យមភាគ ស្មើនឹង២.៨៨)។ ចំណែកឯសូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ សិស្សចង់ឈប់រៀនដើម្បីជួយការងារផ្ទះឪពុកម្តាយ ស្ថិតក្នុងបញ្ហាប្រឈមកម្រិតតិច (មធ្យមភាគ ស្មើនឹង២.៤៧)។

### ៤.៤.២- លទ្ធផលសរុបនៃការសិក្សាស្រាវជ្រាវលើបញ្ហាប្រឈមក្នុងការចំណាយការសិក្សា តាមការឆ្លើយតបរបស់សិស្ស

ត្រង់ចំណុចនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញពីទិន្នន័យមធ្យមភាគសរុបរួម លើបញ្ហាប្រឈមនៃការចំណាយការសិក្សាតាមការឆ្លើយតបរបស់សិស្ស ពាក់ព័ន្ធនឹងសូចនាករសំខាន់ដូចជា៖ សតិអារម្មណ៍ និងភាពជឿជាក់ សេដ្ឋកិច្ច (ការចំណាយប្រចាំថ្ងៃ ការចំណាយថ្លៃសាលារៀន ការចំណាយដើមឆ្នាំ និងការចំណាយបន្ថែម) និងការសម្រេចចិត្ត។

តារាង៤.៣៦៖ ទិន្នន័យសរុបលើបញ្ហាប្រឈមក្នុងការចំណាយការសិក្សា តាមការឆ្លើយតបរបស់សិស្ស

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | បញ្ហាប្រឈមលើសតិអារម្មណ៍និងភាពជឿជាក់ | **២.៦២** | **០.៥២** | **មធ្យម** |
| ២ | បញ្ហាប្រឈមលើផ្នែកសេដ្ឋកិច្ច | | | |
| | ការចំណាយប្រចាំថ្ងៃ | ៣.៤៣ | ០.៨១ | ខ្លាំង |
| | ការចំណាយថ្លៃសាលារៀន | ២.៥០ | ០.៣៨ | តិច |
| | ការចំណាយដើមឆ្នាំសិក្សា | ២.៤៤ | ០.១៩ | តិច |
| | ការចំណាយបន្ថែម | ២.៦៣ | ០.៣៣ | មធ្យម |
| | សរុបបញ្ហាប្រឈមលើផ្នែកសេដ្ឋកិច្ច | **២.៧៥** | **០.៤៦** | **មធ្យម** |
| ៣ | បញ្ហាប្រឈមលើការសម្រេចចិត្ត | **២.៦៧** | **០.១៦** | **មធ្យម** |
| **សរុប** | | **២.៦៨** | **០.០៦** | **មធ្យម** |

ផ្អែកតាមតារាងទិន្នន័យ (៤.៣៦) បង្ហាញពីការឆ្លើយតបជារួមរបស់សិស្សានុសិស្សកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ លើបញ្ហាប្រឈមក្នុងការចំណាយការសិក្សា គឺមានបញ្ហាប្រឈមស្ថិតក្នុងកម្រិតមធ្យម (មធ្យមភាគ ស្មើនឹង២.៦៨ និងគម្លាតស្តង់ដា ស្មើនឹង ០.០៦)។ ក្នុងចំណោមនោះ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេ គឺបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ច ដែលស្ថិតក្នុងបញ្ហាប្រឈមកម្រិតមធ្យម (មធ្យមភាគ ស្មើនឹង ២.៧៥ និងគម្លាតស្តង់ដា ស្មើនឹង០.៤៦)។ ក្នុងនោះទៀតសោតសិស្សានុសិស្សកំពុងជួបប្រឈមខ្លាំងលើការចំណាយប្រចាំថ្ងៃ(មធ្យមភាគ ស្មើនឹង ៣.៤៣ និងគម្លាតស្តង់ដាស្មើនឹង០.៨១) ។ ចំពោះសូចនាករដែលទទួលបានពិន្ទុទាបជាងគេ គឺបញ្ហាប្រឈមលើសតិអារម្មណ៍និងភាពជឿជាក់ ដែលស្ថិតក្នុងបញ្ហាប្រឈមកម្រិតមធ្យម (មធ្យមភាគ ស្មើនឹង២.៦២ និងគម្លាតស្តង់ដាស្មើនឹង០.៥២) ។

### ៤.៤.៣-ទិន្នន័យបែបគុណវិស័យស្តីពីបញ្ហាប្រឈមក្នុងការចំណាយការសិក្សារបស់សិស្ស

តារាង៤.៣៧៖ ទិន្នន័យបែបគុណវិស័យស្តីពីបញ្ហាប្រឈមក្នុងការចំណាយការសិក្សារបស់សិស្ស ដែលទទួលបានពីសិស្ស មាតាបិតា/អាណាព្យាបាលសិស្ស គណៈគ្រប់គ្រងសាលារៀន និង គ្រូបង្រៀន

| បញ្ហាប្រឈមក្នុងការចំណាយការសិក្សារបស់សិស្ស | |
|---|---|
| **សិស្សានុសិស្ស** | – សិស្សមានបញ្ហាប្រឈមលើការចំណាយប្រចាំថ្ងៃ ដូចជាអាហារបរិភោគ/នំចំណី មធ្យោបាយធ្វើដំណើរ ក្រៅពីនេះ ការចំណាយលើគួរក្រៅម៉ោង ដែលសិស្សត្រូវសម្រេចចិត្តជ្រើសរើសរៀនដើម្បីបំពេញបន្ថែមចំណេះដឹងបន្ទាប់ពីម៉ោងរដ្ឋ។<br>– ការចំណាយប្រចាំថ្ងៃ បានប៉ះពាល់ដល់សតិអារម្មណ៍ និងភាពជឿជាក់របស់សិស្ស ស្របពេលដែលកុមារភាគច្រើនមានសមាជិកគ្រួសារកំពុងសិក្សានៅសាលារៀន ច្រើន ដោយតម្រូវឱ្យមានការចំណាយទ្វេដង។<br>– ការចំណាយប្រចាំថ្ងៃនេះ ធ្វើឱ្យពួកគេរារែកចិត្តថាតើពួកគេនឹងសង្ឃឹមថាបានបន្តការសិក្សាចប់ថ្នាក់ឬអត់ ស្របពេលដែលឪពុកម្តាយតែងតែបង្ហាញអារម្មណ៍ចង់ឱ្យកូនជួយរកប្រាក់។ |
| **មាតាបិតាសិស្ស** | – ការចំណាយលើការសិក្សារបស់កូនៗ គឺជាកាតព្វកិច្ចរបស់ពួកគាត់ដែលមិនអាចប្រកែកបាន ខណៈបច្ចុប្បន្ននេះ កូនដែលកំពុងសិក្សានៅសាលាមានចន្លោះពី២-៣ នាក់ធ្វើឱ្យការចំណាយត្រូវកើនទ្វេដង។<br>– គ្រួសារដែលទទួលបានចំណូលទាប ឬមធ្យម មានកូនច្រើន ត្រូវចំណាយលើម្ហូប និងចំណាយលើតម្រូវការផ្សេងៗ ហើយត្រូវដកចំណែកខ្លះសម្រាប់កូនសិក្សា ដូចនេះវាពិតជាឧបសគ្គសម្រាប់ពួកគាត់។<br>– បញ្ហាប្រឈមនោះគឺចំណាយប្រចាំថ្ងៃ ចំណាយលើការញ៉ាំអាហារពេលព្រឹកឬថ្ងៃត្រង់ ចំណីនៅឯសាលារៀន ការចំណាយលើសាំងម៉ូតូសម្រាប់ធ្វើដំណើរទៅមក |

| | |
|---|---|
| | និងរៀនគួរ ២-៣មុខវិជ្ជាសំខាន់ៗ គឺជាបន្ទុកខ្លាំងសម្រាប់ឪពុកម្តាយ ជាពិសេសគ្រួសារដែលមានជីវភាពទន់ខ្សោយ។ ការចំណាយនៅដើមឆ្នាំសិក្សាលើសម្លៀកបំពាក់ ឯកសណ្ឋាន និងសម្ភារៈសិក្សាក៏ជាបញ្ហាផងដែរ ដោយហេតុថាពួកគាត់ត្រូវចំណាយសរុបច្រើនក្នុងពេលនោះ ដ្បិតមួយឆ្នាំសិក្សាចំណាយម្តងយ៉ាងណាក្តី។ បញ្ហានេះ ត្រូវបានសម្រួលខ្លះសម្រាប់សម្លៀកបំពាក់ឯកសណ្ឋានដែលសល់ពីឆ្នាំចាស់ៗ ដែលតម្រូវទិញថ្មីបន្ថែមមួយទៅពីរឈុតជាការស្រេច ឯសៀវភៅឬសម្ភារៈសិក្សាក៏នៅមានតម្លៃធូរថ្លៃនៅឡើយ។<br>– ក្នុងចំណោមមាតាបិតា អាណាព្យាបាលទាំងអស់ដែលបានចូលរួមផ្តល់កិច្ចសម្ភាសន៍ គឺមាន២៧ភាគរយ ដែលលើកឡើងពីផលលំបាកនាំឱ្យពួកគេគាត់មានភាពស្ទាក់ស្ទើរក្នុងការសម្រេចចិត្តឱ្យកូនបោះការសិក្សា ឬគួរបន្តទៅទៀត ខណៈដែលខ្លួនកំពុងជួបបំណុលធនាគារធ្វើលំនៅដ្ឋាន និងទិញម៉ូតូដើម្បីឱ្យកូនទៅរៀនសាលាអនុវិទ្យាល័យដែលមានចម្ងាយឆ្ងាយ។ |
| **គណៈគ្រប់គ្រងសាលារៀន** | – ស្ថានភាពគ្រួសារជួបបញ្ហា ជីវភាពខ្វះខាត ឪពុកម្តាយភាគច្រើនជាកសិករ និងកម្មករ ចំណូលគ្រួសារតិច ស្របពេលស្ថានភាពបច្ចុប្បន្នកំពុងប្រឈមនឹងជំងឺរាតត្បាត ត្រូវកាត់បន្ថយបុគ្គលិកធ្វើឱ្យឪពុកម្តាយសិស្សខ្លះពិបាករកប្រាក់ចំណូល។<br>– ការចំណាយលើការសិក្សាជាប្រចាំថ្ងៃ ដូចជា ចំណាយលើការចាក់សាំងម៉ូតូ ការចំណាយលើការទិញអាហារ នំចំណីក្នុងសាលា និងការរៀនគួរក្រៅម៉ោងបន្ថែមសុទ្ធសឹងជាបញ្ហាប្រឈមដែលមាតាបិតាអាណាព្យាបាលកំពុងជួប។ ក្រៅពីនេះ ក៏មានចំណាយផ្សេងៗ ដូចជា ឯកសណ្ឋានសាលា ផ្ញើកង់ ម៉ូតូ ការរៃអង្គាសប្រាក់ថ្ងៃសីល ក្រដាសប្រឡង និងចំណាយបន្ទាប់បន្សំនានា។<br>– សិស្សក្រីក្រ មានភាពខ្មាស់អៀនច្រើន មិនហ៊ានស្នើសុំអាហារូបករណ៍ ជំនួយពីសាលារៀន អាណាព្យាបាលពុំសូវបានចូលរួម ការយល់ដឹងរបស់ឪពុកម្តាយនៅមាន |

| | |
|---|---|
| | កម្រិត រួមទាំងក្លាយទម្លាប់ទៅជាគ្រួសារសម្ភារនិយមផង និងជាតម្រូវការផង (ធ្វើផ្ទះថ្មី ទិញម៉ូតូ...) ទើបធ្វើឱ្យគ្រួសារជំពាក់ធនាគារ ខ្លះត្រូវបង្ខំឱ្យកូនច្បងក្នុងគ្រួសារបញ្ឈប់ការសិក្សាដើម្បីជួយរកប្រាក់។<br>– បញ្ហាទាំងនេះពិតបានជះឥទ្ធិពលដល់ការសិក្សារបស់សិស្សពិតប្រាកដ។ |
| **គ្រូបង្រៀន** | – បច្ចុប្បន្នមានសិស្សក្រីក្រលំបាក ឪពុកម្ដាយខ្វះខាតដោយសារបាត់បង់ចំណូល ជាឧបសគ្គរាំងលើការសិក្សារបស់កុមារ។<br>– ការចំណាយលើអាហារនៅសាលារៀនច្រើន ការចំណាយលើសាំងម៉ូតូមានតម្លៃថ្លៃ សិស្សខ្លះមិនបានគោរពវិន័យសាលា (លើឯកសណ្ឋាន) ព្រោះមិនមានលទ្ធភាពច្រើនសម្រាប់ទិញសម្ភារៈដូចជាស្បែកជើងមានតែមួយគូរ នៅពេលខែវស្សាភ្លៀងទទឹក គ្មានអ្វីផ្លាស់ប្ដូរ។<br>– សិស្សមួយចំនួនមិនមានលទ្ធភាពរៀនគួរក្រៅម៉ោងបន្ថែម សិស្សមានភាពខ្មាសអៀនច្រើន មិនហ៊ានស្នើសុំឬលើកឡើងអំពីបញ្ហាប្រឈមជាមួយគ្រូបង្រៀន មករៀនមិនបានទៀងទាត់ឬយឺតយ៉ាវ ដោយសារសភាពផ្លូវស្ងាត់ផ្ទះឆ្ងាយ មុនមកសាលាត្រូវជួយធ្វើការងារឪពុកម្ដាយ។<br>– ការលំបាកមានច្រើន ឯសង្គមការងារកាន់តែខិតជិតក្បែរផ្ទះ ទើបធ្វើឱ្យសិស្សតិចតួចសម្រេចចិត្តឈប់រៀនចូលរោងចក្រ។ |

សរុបជារួមមក តាមរយៈការឆ្លើយតបរបស់សិស្ស មាតាបិតាអាណាព្យាបាល គណៈគ្រប់គ្រងសាលា និងគ្រូបង្រៀន បានបញ្ជាក់ថាបញ្ហាប្រឈមដែលសិស្សានុសិស្សកំពុងជួបប្រទះខ្លាំងជាងគេ គឺផ្នែកសេដ្ឋកិច្ចលើការចំណាយប្រចាំថ្ងៃ ដូចជាការចំណាយអាហារបរិភោគ នំចំណី មធ្យោបាយធ្វើដំណើរ និងការរៀនគួរ ហើយបញ្ហាប្រឈមទាំងនេះ ត្រូវបានលើកយកមកពិភាក្សាជាអាទិភាព។

## ៤.៥- ការពិភាក្សាពីបញ្ហាប្រឈមលើចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ ខេត្តកំពង់ស្ពឺ

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវ ពីបញ្ហាប្រឈមលើការចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ បានបង្ហាញថាស្ថិតក្នុងកម្រិតមធ្យម ដែលមានតម្លៃមធ្យមភាគស្មើនឹង២.៦៨ គម្លាតស្តង់ដា ស្មើនឹង ០.០៦។ សូចនាករដែលទទួលបានមធ្យមភាគពិន្ទុខ្ពស់ជាងគេ តាមរយៈការឆ្លើយរបស់សិស្សទាំងបីសាលា ដែលមានសមាសភាពចូលរួមចំនួន១៣៥នាក់គឺ បញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើការចំណាយប្រចាំថ្ងៃ ពោលគឺសិស្សានុសិស្សបានប្រឈមលើអាហារបរិភោគ/នំចំណី មធ្យោបាយធ្វើដំណើរ គួរក្រៅម៉ោងសិក្សា និងចំណតកង់/ម៉ូតូ។ ជាការពិត សិស្សានុសិស្សតែងចំណាយលើការសិក្សាពិសេសការយកលុយសម្រាប់ចាយវាយប្រចាំថ្ងៃនៅសាលារៀន។ ផ្អែកតាមលទ្ធផលនិងបទពិសោធ និងការសង្កេត សិស្សភាគច្រើនឬស្ទើរទាំងអស់តែងតែបានត្រៀមទុកប្រាក់មួយចំណែកសម្រាប់ទិញចំណីឬអាហារនៅសាលារៀន។ ការញ៉ាំចំណីអាហារ ជាការចំណាយច្រើនជាទូទៅនៅពេលដែលសិស្សចេញលេងដូចជាទឹកសុទ្ធ គេសជ្ជៈផ្អែម នំកញ្ចប់...និងការញាំអាហារពេលព្រឹកឬថ្ងៃត្រង់ ចន្លោះពី២៥០០រៀលទៅ៣០០០រៀល ក្នុងមួយចាន។ ស្របតាមការលើកឡើងរបស់លោក (Bray, 1999) បង្ហាញថាការចំណាយលើអាហារបរិភោគជារឿងមួយដែលឪពុកម្តាយត្រូវចំណាយ ហើយជាទូទៅអាហារទាំងនេះមានតម្លៃថ្លៃជាងអាហារនៅផ្ទះ។ ឯការចំណាយលើមធ្យោបាយធ្វើដំណើរវិញ ជារឿងដែលសិស្សភាគច្រើនកំពុងជួបដោយហេតុថាសាលារៀននៅឆ្ងាយពីផ្ទះ ឪពុកម្តាយបានសម្រេចចិត្តប្រគល់ម៉ូតូដែលប្រើរួមគ្នាក្នុងគ្រួសារឬទិញម៉ូតូថ្មីដើម្បីឱ្យកូនទៅសាលារៀន។ មិនមែនតែប៉ុណ្ណោះទេ វាក៏ជាប់ទាក់ទងនឹងបរិបទនៃសង្គមកំពុងរីកចម្រើន ការគិតពីសុវត្ថិភាព ការយល់ពីផលលំបាករបស់កូនផងដែរ។ ម្យ៉ាងវិញទៀត ស្របពេលដែលបញ្ហាពិភពលោកផ្ទុះឡើង ការចំណាយថ្លៃសាំងនេះកាន់តែច្រើន។ ការរៀនគួរក្រៅម៉ោងគឺជាការពេញនិយមបំផុតស្ទើរគ្រប់សាលាក្នុងប្រទេសកម្ពុជា។ ការបង្រៀនគួរនេះ ជាប់ពាក់ព័ន្ធនឹងការចំណាយរបស់គ្រួសារសិស្សនិងការដាក់សម្ពាធផ្លូវចិត្តផងដែរ។ ស្របនឹងការសិក្សារបស់ (Bray and Seng 2005) បានលើកឡើងថា ការរៀនគួរធ្វើឱ្យមានការចាប់អារម្មណ៍ខ្លាំងពីសំណាក់ពិភពលោក សូម្បីប្រទេសរីកចម្រើន

ដូចជានៅហុងកុង សិង្ហបុរី កូរ៉េខាងត្បូង និងតៃវ៉ាន់ក៏មានការបង្រៀនគួរដែរ។ ម្យ៉ាងវិញទៀត ការមានសមាជិកបងប្អូនកំពុងសិក្សាក្នុងសាលាច្រើន ការចំណាយកើនឡើងទ្វេគុណ ហើយវាបានជះឥទ្ធិពលដល់ការសម្រេចចិត្តរបស់សិស្ស និងអាណាព្យាបាលផងដែរ។ ដូចនេះ សម្រាប់ដំណោះស្រាយគឺសិស្សអាចកាត់បន្ថយការញ៉ាំនំចំណីអាហារ នំកញ្ចប់ វាមិនត្រឹមតែជាបន្ទុកចំណាយទេថែមទាំងប៉ះពាល់សុខភាពថែមទៀត ជាពិសេសអាហារឬភេសជ្ជៈដែលមានជាតិផ្អែមក្រសួងអប់រំបានហាមឃាត់។ ការប្រើទម្លាប់ដាក់បាយនិងទឹកយកទុកញ៉ាំនៅសាលារៀន ជាវិធីល្អបំផុត ទាំងធានាអនាម័យ សុខភាព និងសន្សំសំចៃ។ ការប្រើទម្លាប់ជិះកង់ឬកង់អគ្គិសនី ក៏ជាដំណោះស្រាយល្អក្នុងបញ្ចៀសបានការចំណាយច្រើនក្នុងបរិបទសាំងឡើងថ្លៃ ផ្ដល់បាននូវសុខភាពផងដែរ។ ចំពោះសូចនាករដែលទទួលបានមធ្យមភាគពិន្ទុទាបជាងគេ តាមរយៈការឆ្លើយរបស់សិស្ស គឺបញ្ហាប្រឈមផ្នែកសតិអារម្មណ៍និងភាពជឿជាក់។ ត្រង់នេះមានន័យថា សិស្សមិនមានសម្ពាធអវត្តមានពេលប្រឡងព្រោះគ្មានលុយបង់ថ្លៃក្រដាសប្រឡង សិស្សមិនបានឈប់សម្រាកឬអវត្តមានច្រើនដោយសារមិនបានរៀនគួរមុខវិជ្ជាណាមួយ មិនមានសម្ពាធគ្រូធ្វើបាបដោយឱ្យឡើងឈរឬធ្វើលំហាត់លើក្ដារខៀនចំពោះសិស្សដែលមិនបានរៀនគួរ គ្រូមិនមានភាពលម្អៀងនិងរៀនមិនអស់ខ្លឹមសារក្នុងម៉ោងរដ្ឋទុកសម្រាប់ម៉ោងគួរឡើយ។ នេះសបញ្ជាក់ថា សាលារៀនបានខំខិតប្រឹងគិតពីលទ្ធផលសិក្សាសិស្សតាមរយៈការយកចិត្តទុកដាក់លើបរិយាកាសសិក្សារបស់សិស្ស ជាពិសេសលោកគ្រូអ្នកគ្រូបានអនុវត្តទៅតាមនិយាម គរុកោសល្យ បង្ហាញពីឱ្យសិស្សបានដឹងថាថ្នាក់រៀនពោរពេញដោយតម្លាភាព ការស្រលាញ់ លើកទឹកចិត្ត និងយល់ពីសេចក្ដីត្រូវការរបស់សិស្ស។

តាមរយៈការឆ្លើយតបរបស់មាតាបិតាសិស្សបានបង្ហាញថា ឪពុកម្ដាយមានបញ្ហាលើការចំណាយជាប្រចាំថ្ងៃសម្រាប់កូនៗទៅសាលារៀន ខណៈដែលត្រូវរ៉ាប់រងការចំណាយផ្សេងៗរួមទាំង បំណុលផងដែរ។ តាមការសិក្សារបស់ក្រសួងផែនការឆ្នាំ២០២០បង្ហាញថា ការចំណាយប្រើប្រាស់ប្រចាំខែគិតជាមធ្យមគឺមានចំនួន ២.២៧៨ ពាន់រៀលក្នុងមួយគ្រួសារ ខណៈក្នុងឆ្នាំ២០១៤មានចំនួន១.៥២៩ ពាន់រៀលសម្រាប់មួយគ្រួសារ ឯបំណុលនៃគ្រួសារកម្ពុជាក្នុងឆ្នាំ២០១៩-២០២០ គឺមាន៣៤% ធៀបនឹងឆ្នាំ២០១៤ កើន២១,៥%។ ជាការពិត សេដ្ឋកិច្ចគ្រួសារជាប្រភពសំខាន់ក្នុងការជំរុញឱ្យការសិក្សារបស់កុមារបាន

ប្រសើរ ពោលស្ថានភាពគ្រួសារមានជីវភាពធូរធារ ឪពុកម្តាយមានលទ្ធភាពក្នុងការចូលរួមការសិក្សាកូនៗបានល្អ ផ្ទុយពីនេះប្រសិនជាស្ថានភាពគ្រួសារមានជីវភាពខ្វះខាត នោះពួកគេនឹងពិបាកក្នុងការផ្គត់ផ្គង់ដល់ការសិក្សាកុមារដូចគ្នា។ ស្របតាមអ្នកសិក្សាស្រាវជ្រាវ (Lin,T., & Lv, H.,2017) ការអប់រំរបស់កុមារគឺត្រូវបានពឹងផ្អែកលើស្ថានភាពសេដ្ឋកិច្ចគ្រួសារនីមួយៗ ពោលគ្រួសារដែលមានចំណូលទាបគឺពិបាកក្នុងជំរុញកូនៗឱ្យទទួលបានការអប់រំនៅសាលាល្អៗ ឬបន្តការសិក្សាខ្ពស់នោះឡើយ។ ដូចនេះ ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចរបស់គ្រួសារ ជះឥទ្ធិពលអវិជ្ជមានដល់ការសម្រេចចិត្តរបស់ឪពុកម្តាយ ហើយកុមារក៏ទទួលរងផលអវិជ្ជមាននោះផងដែរ។ ផ្អែកលើលទ្ធផលនេះបង្ហាញថា ការចំណាយប្រចាំថ្ងៃលើការសិក្សារបស់សិស្សម្នាក់គិតជាមធ្យមមានចំនួន៤៥០.៤៧ ដុល្លារអាមេរិក ស្មើនឹង៨៣.៩៦ភាគរយ នៃចំណាយសរុបក្នុងមួយឆ្នាំសិក្សា។ ខណៈដែលGDPសរុបសម្រាប់មនុស្សម្នាក់ចំនួន ១,៨៤២ ដុល្លារអាមេរិក (អគ្គនាយកដ្ឋានពន្ធដារ, ២០២២)។ ទន្ទឹមនឹងនេះ សិស្សចំណាយប្រចាំថ្ងៃលើការសិក្សាក្នុងមួយខែ ស្មើនឹង៩ភាគរយបើធៀបនឹងចំណាយការប្រើប្រាស់ប្រចាំខែគិតជាមធ្យមក្នុងមួយគ្រួសារចំនួន ៥៥៥.៦០ ដុល្លារអាមេរិក (ក្រសួងផែនការ,២០២០)។ តាមការសិក្សាខាងលើ ក្នុងមួយគ្រួសារជាមធ្យមមានកូន៣នាក់កំពុងសិក្សា ដូចនេះមាតាបិតាក៏ត្រូវចំណាយកើនទ្វេគុណ។ ការចំណាយទាំងនេះ ត្រូវបានគណនាក្រោយការជួយជ្រោមជ្រែងពីរដ្ឋាភិបាល ប្រសិនពុំដូច្នោះទេ បន្ទុកទាំងស្រុងនឹងធ្លាក់លើគ្រួសារកាន់តែពិបាក។ ទោះបីជារាជរដ្ឋាភិបាលជាតិបានគាំទ្រគោលការណ៍អប់រំដោយឥតបង់ថ្លៃយ៉ាងណាក្តី រដ្ឋាភិបាលក៏មិនអាចធានាលើការផ្តល់ហិរញ្ញវត្ថុ សម្រាប់សេវាអប់រំសាធារណៈបានគ្រប់គ្រាន់ប្រកបដោយនិរន្តរភាពនោះដែរ។ ដើម្បីធានាបាននូវនិរន្តរភាពផ្នែកហិរញ្ញវត្ថុនៃប្រព័ន្ធសាលារៀននេះ ត្រូវការចូលរួមរបស់មាតាបិតាដែលជាយន្តការផ្តល់មូលនិធិស្ម័គ្រចិត្ត ឬការទទួលខុសត្រូវតាមការរៀបចំឱ្យមានភាពច្បាស់លាស់ស្របតាមក្របខណ្ឌច្បាប់មួយ (UNDP, 2014)។ ជារួម ឪពុកម្តាយឬអាណាព្យាបាល បានដើរតួនាទីសំខាន់ក្នុងការកំណត់វាសនាការសិក្សារបស់បុត្រធីតា ដោយហេតុថាការអប់រំត្រូវមានធនធានហិរញ្ញវត្ថុ ជំនួយពីសង្គម អារម្មណ៍ការលើកទឹកចិត្ត ដែលទាំងនេះត្រូវពឹងផ្អែកភាគច្រើនលើមាតាបិតា អាណាព្យាបាល (Chhaing, 2021)។

សម្រាប់ការឆ្លើយតបរបស់គណៈគ្រប់គ្រងសាលារៀនបានបង្ហាញដូចគ្នាទៅនឹងសិស្ស និងមាតាបិតាអាណាព្យាបាលផងដែរ។ គណៈគ្រប់គ្រងសាលារៀនបានយកចិត្តទុកដាក់គ្រប់សកម្មភាពរបស់សិស្ស ព្រមទាំងបានប្រមើលមើលឃើញថា កុមារកំពុងជួបឧបសគ្គនោះគឺមានប្រឈមលើផ្នែកសេដ្ឋកិច្ចជាពិសេសការចំណាយប្រចាំថ្ងៃ ដូចជាការចំណាយលើមធ្យោបាយធ្វើដំណើរ ការចំណាយលើការញ៉ាំអាហារ និងការរៀនគួរ។ យោងតាមការសិក្សារបស់លោក (Bray, 1999)បានលើកឡើងថា សិស្សមានផលលំបាកច្រើនលើការធ្វើដំណើរខណៈពេលដែលសាលារៀននៅឆ្ងាយពីផ្ទះសិស្ស ឯការចំណាយលើការញ៉ាំអាហារច្រើនជាងនៅផ្ទះ ហើយការរៀនគួរមានផលវិបាកយ៉ាងខ្លាំង ពិសេសចំពោះកុមារដែលមិនមានលទ្ធភាពរៀនបន្ថែម។ ការចំណាយទាំងនេះ មិនបានបញ្ចប់ត្រឹមថាឪពុកម្តាយក្រីក្រ និងមានកូនសិក្សាច្រើនគ្មានលទ្ធភាព ធ្វើឱ្យប៉ះពាល់អារម្មណ៍សិស្ស និងការសម្រេចចិត្តរបស់មាតាបិតាប៉ុណ្ណោះទេ វាថែមទាំងបានជះឥទ្ធិពលដល់ដំណើរការការងាររបស់គណៈគ្រប់គ្រងសាលារៀនផងដែរ។ ក្នុងដំណាក់កាលនេះ វត្តមានរបស់សាលារៀនពិតជាសំខាន់ក្នុងការចូលរួមដោះស្រាយ។ បញ្ហាចោទសំខាន់ស្ថិតនៅត្រង់សិស្សក្រីក្រលំបាក សម្រាប់សិស្សដែលមានជីវភាពប្រសើរ មិនមែនជាឧបសគ្គធ្ងន់ធ្ងរនោះឡើយ។ សាលារៀនគួរសម្រួចផ្តោតយកចិត្តទុកដាក់លើក្រុមសិស្សជួបការលំបាកទាំងនោះឱ្យបានច្រើន តាមរយៈការកាត់បន្ថយតម្រូវការចំណាយណាដែលមិនសូវចាំបាច់ក្នុងសាលារៀន ហើយព្យាយាមបង្កើតឱ្យមានតម្លាភាព បង្ហាញសមិទ្ធផលដើម្បីទាក់ទាញសហគមន៍ឱ្យពេញចិត្តក្នុងការចូលរួម ជាពិសេសសប្បុរសជនដែលមានជីវភាពល្អប្រសើរ។ ផ្តោតយកចិត្តទុកដាក់លើសិស្សដែលក្រីក្រពិតប្រាកដ គាំទ្រ ជំរុញលើកទឹកចិត្ត ឧបត្ថម្ភថវិកាសម្ភារៈ តាមលទ្ធភាពរបស់សាលារៀន ទប់ស្កាត់ការលក់នំចំណីអាហារសម្បូរបែបដែលប៉ះពាល់សុខភាព ឬ កាត់បន្ថយការលក់នំចំណីណាដែលពុំសូវចាំបាច់ ប្រើយុទ្ធវិធីដោយបំផុសគំនិតសិស្សចេញយកទឹក និងអាហារចំអិនខ្លួនឯងពីផ្ទះ លើកទឹកចិត្តការជិះកង់ជាមធ្យោបាយ ស្នើសុំការអនុគ្រោះគ្រូបង្រៀនគួរក្រៅម៉ោងចំពោះសិស្សក្រីក្រលំបាក ស្វែងរកយុទ្ធសាស្ត្រដើម្បីអំពាវនាវសម្បុរសជនចូលរួមឱ្យបានច្រើន។

តាមរយៈការឆ្លើយតបរបស់គ្រូបង្រៀនបង្ហាញថា បញ្ហាចំពោះសិស្សានុសិស្សគឺស្ថិតនៅលើស្ថានភាពរបស់គ្រួសារក្នុងការចំណាយជាប្រចាំថ្ងៃ។ សិស្សដែលស្ថិតក្នុងគ្រួសារមានជីវភាពល្អប្រសើរ មិនសូវមាន

បញ្ហាអ្វីប៉ះពាល់ដល់ការសិក្សារបស់សិស្សឡើយ ផ្ទុយពីនេះសិស្សក្រីក្រពិតជាលំបាក បាត់បង់ទំនុកចិត្ត សម្ពាធទាំងផ្នែកហិរញ្ញវត្ថុ និងផ្លូវអារម្មណ៍។ ការចំណាយលើចំណីអាហារនៅសាលា មធ្យោបាយធ្វើដំណើរ ការបង្រៀនគួរក្រៅម៉ោង ការផ្ញើកង់ម៉ូតូ ការរៃអង្គាស និងការចំណាយផ្សេងៗ វាមិនត្រឹមតែប៉ះពាល់ដល់សិស្សនិងក្រុមគ្រួសារនោះទេ ថែមទាំងបានផ្តល់ផលអវិជ្ជមានដល់ការបង្រៀននិងរៀន ដោយហេតុថា សេដ្ឋកិច្ចនិងផ្លូវអារម្មណ៍នេះជាប់ទាក់ទងយ៉ាងស្អិតរមួតជាការធ្វើឱ្យសម្រេចនូវវត្ថុបំណងមេរៀន និងលទ្ធផលសិក្សារបស់សិស្ស។ ប្រសិនបើគ្មានអន្តរាគមន៍ណាមួយទេ នោះគ្រួសារសិស្សអាចសម្រេចចិត្តដោយមានទំនោរទៅលើការចំណាយអាទិភាពផ្សេងៗ ជាជាងការមានទំនោរចិត្តទៅលើចំណាយការសិក្សារបស់សិស្សមិនខាន(Bray and Seng, 2005)។ ដូច្នេះគ្រូបង្រៀន ជាតួអង្គសំខាន់ចំពោះបញ្ហាប្រឈមមួយនេះ ដែលនឹងត្រូវលើកយកមកពិភាក្សានូវសំណួរស្រាវជ្រាវខាងក្រោម។

## ៤.៦- ការវិភាគទិន្នន័យបែបគុណវិស័យលើកម្រងសំណួរស្តីពីការចូលរួមរបស់សាលារៀនក្នុងការកាត់បន្ថយលើចំណាយការសិក្សារបស់សិស្សានុសិស្ស

**តារាង៤.៣៨៖ ទិន្នន័យបែបគុណវិស័យស្តីពីការចូលរួមរបស់សាលារៀនក្នុងការកាត់បន្ថយលើចំណាយការសិក្សារបស់សិស្សានុសិស្សដែលទទួលបានពីសិស្ស មាតាបិតា/អាណាព្យាបាលសិស្ស គណៈគ្រប់គ្រងសាលារៀន និង គ្រូបង្រៀន**

| ការចូលរួមរបស់សាលារៀនក្នុងការកាត់បន្ថយលើចំណាយការសិក្សារបស់សិស្សានុសិស្ស | |
|---|---|
| **សិស្សានុសិស្ស** | – សាលារៀនបានកាត់បន្ថយការបង្រៀនគួរក្រៅម៉ោងជំនួសដោយការពង្រឹងក្នុងម៉ោងរដ្ឋ និងកាត់បន្ថយការបង់ថ្លៃសេវានានាក្នុងសាលារៀន ការផាកពិន័យនានា ការរៃអង្គាសមូលនិធិឬក្នុងពេលប្រឡង លើកទឹកចិត្តក្នុងការបង្កើតកម្មវិធីអ្នកមានជាក់ អ្នកក្រដក ការលើកលែងថ្លៃចំណតកង់ឬម៉ូតូចំពោះសិស្សជួបការលំបាក កំណត់តម្លៃលក់ចំណីអាហារ ជួយឧបត្ថម្ភនិងអាហារូបករណ៍ដល់សិស្សក្រីក្រ។ |

| | |
|---|---|
| **មាតាបិតាសិស្ស** | – សាលារៀនបានចូលរួមកាត់បន្ថយការរំអៀងគ្លាសមិនសូវសំខាន់ និងកាត់បន្ថយការផាកពិន័យជាទឹកប្រាក់ចំពោះសិស្សធ្វើខុសបទបញ្ជាផ្ទៃក្នុងសាលា។<br>– ផ្តល់ប្រាក់អាហារូបករណ៍ដល់សិស្សក្រីក្រចំគោលដៅ<br>– លោកគ្រូ អ្នកគ្រូ បានជួយសិស្សដែលមានជីវភាពខ្វះខាតដោយផ្តល់ឱកាសពួកគេចូលរៀនគួរក្រៅម៉ោងឥតគិតថ្លៃ<br>– កាត់បន្ថយយកលុយពេលប្រឡង ឬការលក់មេរៀន លើកលែងការយកចំណតកង់ម៉ូតូចំពោះសិស្សក្រីក្រ។ |
| **គណៈគ្រប់គ្រងសាលារៀន** | សកម្មភាពដែលគណៈគ្រប់គ្រងសាលារៀនបានអនុវត្តកន្លងមកនេះមានដូចជាៈ<br>– កៀរគរ និងរៃអង្គាសមូលនិធិដោយស្ម័គ្រចិត្តពីមាតាបិតាមានជីវភាពមធ្យមឬធូរជារ និងស្នើសុំការចូលរួមពីអតីតសិស្ស<br>– ផ្តល់ទំនុកចិត្តដល់សហគមន៍ មាតាបិតា អាណាព្យាបាល តាមរយៈការបង្ហាញលទ្ធផល ស្នាដៃក្នុងអង្គប្រជុំជាប្រចាំ<br>– ជ្រើសរើសសិស្សក្រីក្រខ្វះខាតផ្នែកជីវភាពពិតប្រាកដ ក្នុងការផ្តល់អាហារូបករណ៍ចំគោលដៅ<br>– ផ្តល់កង់ចំពោះសិស្សខ្វះខាតគ្មានមធ្យោបាយធ្វើដំណើរ ការផ្តល់ថវិកាផ្ទាល់ខ្លួនសម្រាប់ទិញសម្ភារៈសិក្សា ឯកសណ្ឋានសាលា ស្បែកជើង សម្លៀកបំពាក់ ស្លាកឈ្មោះ ការលើកលែងចំពោះសិស្សក្រីក្រក្នុងការផ្ញើកង់ឬម៉ូតូ ការស្នើសុំគ្រូបង្រៀនតាមមុខវិជ្ជាដើម្បីឱ្យសិស្សក្រីក្ររៀនគួរក្រៅម៉ោងមិនបង់ថ្លៃសិក្សា<br>– បន្តការគាំទ្រសាលារៀនដែលមានមជ្ឈមណ្ឌលសហគមន៍បង្រៀនភាសាអង់គ្លេស និងកុំព្យូទ័រឥតគិតថ្លៃ<br>– ក្រៅពីនេះ គណៈគ្រប់គ្រងតែងតែអប់រំណែនាំជាប្រចាំ(ក្រោយពេលគោរពទង់ជាតិឬការប្រជុំប្រចាំខែ)ឱ្យសិស្សចេះសន្សំសំចៃ មិនមែនត្រឹមតែជាការសន្សំ |

| | |
|---|---|
| | សម្រាប់រយៈពេលខ្លីទេ ប៉ុន្តែជាការបំផុសគំនិតឱ្យមានការសន្សំក្នុងរយៈពេលវែងសម្រាប់ការសិក្សាបន្តទៅមុខទៀត។ |
| **គ្រូបង្រៀន** | – ការរៀនគួរត្រូវបានលើកលែងចំពោះសិស្សក្រីក្រ និងមិនមានការបង្ខិតបង្ខំ<br>– ការប្រឡងមិនយកប្រាក់ កាត់បន្ថយការរំអេងភ្ជាសក្នុងថ្នាក់រៀនដែលធ្វើឱ្យប៉ះពាល់អារម្មណ៍ និងសេដ្ឋកិច្ចរបស់សិស្ស<br>– មិនទទួលយកអំណោយពីសិស្ស<br>– ជួយជាសម្ភារៈសិក្សា ថវិកាផ្ទាល់ខ្លួនសម្រាប់សិស្សដែលលំបាក<br>– ស្វែងរកមូលនិធិ ជំនួយពីអង្គការជួយសិស្សក្រីក្រ<br>– លើកទឹកចិត្តសិស្សឱ្យចេះចាយវាយត្បិតត្បៀត ចំណាយឱ្យចំគោលដៅ ចេះសន្សំសំចៃនិងគិតគូរដល់គ្រួសារ។<br>– ករណីមានការចំណាយក្នុងថ្នាក់ត្រូវមានការឯកភាពពីគណៈគ្រប់គ្រងសាលានិងអាណាព្យាបាល |

## ៤.៧- ការពិភាក្សាលើកម្រងសំណួរស្តីពីការចូលរួមរបស់សាលារៀនក្នុងការកាត់បន្ថយលើចំណាយការសិក្សារបស់សិស្សានុសិស្ស

ផ្អែកតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវ បានបង្ហាញថាការចូលរួមរបស់សាលារៀនក្នុងការកាត់បន្ថយចំណាយការសិក្សារបស់សិស្សពិតជាសំខាន់។ តាមការឆ្លើយតបរបស់សិស្សនិងមាតាបិតាអាណាព្យាបាលបានបង្ហាញថា ពួកគេបានមើលឃើញពីគុណតម្លៃនៃការចូលរួមចំណែកយ៉ាងសំខាន់របស់សាលារៀន តាមរយៈការផ្តល់ជូនផ្នែកសម្ភារៈ ថវិកា និងស្មារតី។ ស្របនឹងការសិក្សារបស់លោក (Bray, 1999) សាលារៀនជាថ្នាលផ្តល់ចំណេះដឹង ព្រមទាំងបានជួយសម្របសម្រួលសិស្សានុសិស្សដោយផ្ទាល់និងប្រយោល។ យោងតាមច្បាប់ស្តីពីការអប់រំ ២០០៧ បានផ្តល់សិទ្ធិចំពោះអ្នកគ្រប់គ្រងគ្រឹះស្ថានសិក្សា មានសិទ្ធិក្នុងការកៀរគរធនធានស្របច្បាប់នានាពីគ្រប់ប្រភពដើម្បីអភិវឌ្ឍគ្រឹះស្ថានសិក្សា។ សាលារៀនដែល

មានគណៈគ្រប់គ្រងសាលាជាអ្នកតំណាងក្នុងការទទួល និងចាត់ចែងអាហារូបករណ៍ដល់សិស្សក្រីក្រ និងបានដើរតួជាអ្នកស្វែងរកមូលនិធិដោយផ្ទាល់ទៀតផង។ តាមការសិក្សារបស់លោក Bray and Seng 2005 ការសម្របសម្រួលក្នុងអង្គភាព ការអនុគ្រោះ ការលើកទឹកចិត្ត ពិតជាបានផ្តល់ឱកាសដល់កុមារក្រីក្រជាច្រើនសម្រាប់ការអប់រំ ដោយសារវាបានជួយសម្រួលបន្ទុកនៃការចំណាយរបស់គ្រួសារ និងបានផ្តល់អារម្មណ៍ល្អសម្រាប់កុមារគ្រប់រូបប្រកបដោយសមធម៌។ អារម្មណ៍រីករាយ ការជំរុញទឹកចិត្ត និងការកាត់បន្ថយចំណាយចំពោះសិស្សក្រីក្រទាំងនេះហើយបានចូលរួមចំណែកដល់ការកាត់បន្ថយអត្រាបង់បោះការសិក្សានិងផ្តល់ឱកាសឱ្យឪពុកម្តាយនិងសិស្សមានពេលដកឃ្លាក្នុងការសម្រេចចិត្តបញ្ចប់ថ្នាក់គ្រប់កម្រិត។ វាពិតជាសំខាន់សម្រាប់ការចំណាយរបស់គ្រួសារនីមួយៗ ជាពិសេសខណៈពេលដែលស្ថានភាពសង្គមកំពុងជួបវិបត្តិ។ ការចូលរួមទាំងនេះ បានលើកកម្ពស់ដល់ការអប់រំរបស់កុមារដែលស្ថិតក្នុងគ្រួសារក្រីក្រដើម្បីមានឱកាសអាចបន្តការសិក្សាបានខ្ពង់ខ្ពស់ផងដែរ។ ទន្ទឹមនឹងនេះ ការចូលរួមរបស់មាតាបិតានិងសហគមន៍នៅតែសំខាន់មិនអាចខ្វះបាន ដោយហេតុថាវាជាប់ទាក់ទងទៅនឹងលំហូរសេដ្ឋកិច្ចក្នុងគ្រួសារនិងសេដ្ឋកិច្ចជាតិ រួមទាំងការសម្រេចចិត្តរបស់មាតាបិតាអាណាព្យាបាល។ ស្របតាមការលើកឡើងរបស់ (Menon, 2013)ដំណើរការសាលារៀននិងលទ្ធផលសិក្សារបស់សិស្សនឹងទទួលបានប្រសិទ្ធភាពកម្រិតទាប ប្រសិនបើគ្មានការចូលរួមជួយពីឪពុកម្តាយ។ ប្រសិនបើគ្មានការគាំទ្រពីសហគមន៍ នោះការអប់រំនឹងជួបការលំបាក បើគ្មានការជំរុញនិងផ្តល់ឱកាសពីឪពុកម្តាយ នោះជោគវាសនារបស់កុមារទាំងអស់នឹងត្រូវបានបញ្ចប់។ ការកាត់បន្ថយចំណាយ គឺមិនមែនមានន័យថាមាតាបិតា អាណាព្យាបាលត្រូវខិតខំប្រឹងប្រែងរកវិធីធ្វើយ៉ាងណាចាកចេញពីការចំណាយទាំងស្រុងនោះទេ ប៉ុន្តែជាការព្យាយាមស្វែងរកប្រភពនៃការចំណាយដែលចាំបាច់និងមិនចាំបាច់ ហើយចាប់ផ្តើមការរៀនសូត្រនិងការចូលរួមចែករំលែក លើកស្ទួយនៅក្នុងវិស័យអប់រំកាន់តែប្រសើរ។

ដូចនេះ សាលារៀនពិតជាបានចូលរួមចំណែកក្នុងការចំណាយការសិក្សារបស់សិស្សប្រាកដមែនពិសេសសម្រាប់កុមារដែលមានជីវភាពខ្វះខាតអាចទទួលបានឱកាសសិក្សាចប់កម្រិតថ្នាក់។ ទន្ទឹមនឹងនេះ មាតាបិតាអាណាព្យាបាលក៏នៅតែជាតួអង្គសំខាន់មិនកាត់ផ្តាច់ចេញពីគ្នាបានឡើយ ដោយហេតុថាមាតា

បិតាគឺជាអ្នកផ្តល់ឱកាសដល់កូនដំបូងគេក្នុងការសិក្សាទាំងពេលវេលា ហិរញ្ញវត្ថុ លើកទឹកចិត្តដល់កូនៗ។ ដើម្បីដោះស្រាយបញ្ហាប្រឈម និងអាចចូលរួមជាមួយសាលារៀនក្នុងការកាត់បន្ថយបន្ទុកចំណាយគ្រួសារលើការសិក្សារបស់កូនៗ មាតាបិតាគួរតែ៖ ទី១- គួរបង្កើតមុខរបរ បន្ថែមការងារ បង្កើនចំណូលដើម្បីឱ្យមានតុល្យភាពរវាងចំណូលនិងចំណាយ ទី២-ទម្លាប់ឱ្យកូនចេះរៀបចំអាហារពីផ្ទះជាជាងញ៉ាំអាហារខាងក្រៅ ទី៣-គ្រួសារមានស្ថានភាពសេដ្ឋកិច្ចប្រសើរ គួរតែចូលរួមគាំទ្រ ជ្រោមជ្រែងសាលារៀនទាំងគំនិត ស្មារតី សម្ភារៈ និងថវិកា ដើម្បីជំរុញដល់ដំណើរការសាលារៀន ទី៤- សិក្សាស្វែងយល់ពីចំណេះដឹងហិរញ្ញវត្ថុក្នុងគ្រួសារ ទី៥-គួរតែព្យាយាមបង្ហាញឱ្យកូនៗបានយល់ច្បាស់រវាងចំណាយអាទិភាព និងបន្ទាប់បន្សំ។

សម្រាប់ការឆ្លើយតបរបស់គណៈគ្រប់គ្រងសាលារៀន ក្នុងការចូលរួមលើការកាត់បន្ថយចំណាយការសិក្សារបស់សិស្សបង្ហាញថា សាលារៀនពិតជាសំខាន់ក្នុងការអនុវត្តការងារជាមួយសិស្សានុសិស្សនិងបានយល់ពីការចំណាយរបស់សិស្សជាងគេ។ សាលារៀនជាប្រភពនៃការចំណាយប្រាក់ដ៏ច្រើនរបស់សិស្ស ដូច្នេះសាលាគួរជាកន្លែងកាត់បន្ថយការចំណាយដល់សិស្សដូចគ្នា។ តាមការសិក្សារបស់ Bray & Seng (2005) ការយកចិត្តទុកដាក់របស់គណៈគ្រប់គ្រងមិនត្រឹមតែសម្រួលបន្ទុកចំណាយរបស់គ្រួសារប៉ុណ្ណោះទេ ប៉ុន្តែបានផ្តល់អារម្មណ៍ល្អ ពេលវេលា សម្ភារៈសិក្សាគ្រប់គ្រាន់ដល់សិស្ស រុញច្រានឱ្យការសិក្សារបស់ពួកគេកាន់តែល្អប្រសើរ។ ក្រៅពីនោះ សិស្សកាន់តែមានទំនុកចិត្តនិងភាពជឿជាក់ ពិសេសការអប់រំប្រកបដោយសមធម៌ ពោលសិស្សពិការមិនទុកចោល សិស្សក្រីក្រមិនបោះបង់ សិស្សទូទៅមិនលែងដៃ។ យោងតាមក្រសួងអប់រំ យុវជន និងកីឡា(២០០៩) បានលើកឡើងថា ការចូលរួមរបស់សាលារៀន ក្រោមការដឹកនាំនិងគ្រប់គ្រងរបស់គណៈគ្រប់គ្រងសាលារៀន ពិតជាអាចជំរុញឱ្យលទ្ធផលសិក្សារបស់សិស្សកាន់តែមានប្រសិទ្ធភាព អត្រាបោះបង់កាន់តែថយចុះ អត្រាឡើងថ្នាក់កើនឡើង។

ដូចនេះ សាលារៀនពិតជាសំខាន់និងបានរួមចំណែកជាច្រើនក្នុងការកាត់បន្ថយចំណាយលើការសិក្សារបស់សិស្ស។ ទោះជាយ៉ាងនេះក្តី សាលារៀនដែលបានចូលរួមលើការស្រាវជ្រាវនេះនៅមិនទាន់បានឆ្លើយតបល្អប្រសើរនៅឡើយ ដោយហេតុថាសាលារៀនមិនបានរៀបចំយន្តការត្រឹមត្រូវនិងផ្តោតលើការ

ការងារនេះឱ្យអស់លទ្ធភាពនៅឡើយ។ ដូច្នេះ ដើម្បីឱ្យដំណើរការអនុវត្តការងារនេះសម្រេចបានដោយភាពជោគជ័យ សាលារៀនគួរចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្ត្រនិងដាក់ចេញផែនការសកម្មភាព កំណត់យន្តការឱ្យបានត្រឹមត្រូវច្បាស់លាស់។

តាមរយៈការឆ្លើយតបរបស់គ្រូបង្រៀន បានបង្ហាញថា ការចូលរួមរបស់សាលារៀនពិតជាសំខាន់ក្នុងការកាត់បន្ថយចំណាយការសិក្សារបស់សិស្សានុសិស្ស ជាពិសេសគ្រូបង្រៀន។ យោងតាមក្រសួងអប់រំ (២០១៦)ការគិតគូរពីផលលំបាករបស់សិស្សគឺជាការខ្វាយខ្វល់ពីលទ្ធផលសិក្សារបស់សិស្ស។ តាមការសិក្សារបស់លោក (Bray, 1999) មាតាបិតា អាណាព្យាបាលនឹងត្រេកអរនៅពេលដែលគ្រូបង្រៀន និងសាលារៀនបានយកចិត្តទុកដាក់លើការសិក្សារបស់កូនៗ រីឯកុមារទាំងអស់នឹងមានអារម្មណ៍សប្បាយ មិនមានសម្ពាធក្នុងថ្នាក់រៀន មករៀនទៀងទាត់ ក្លាហាន មានជំនឿជាក់លើខ្លួនឯង។ ការលុបបំបាត់ការចំណាយដែលមិនសមគួរ ជួយសម្រាលបន្ទុកដល់គ្រួសារសិស្ស កាត់បន្ថយអត្រាបោះបង់ការសិក្សា តម្លៃរបស់គ្រូបង្រៀននឹងរក្សាបានល្អ ទប់ស្កាត់ការយកលេសរបស់សិស្សសុំប្រាក់ពីឪពុកម្តាយ។

ដូចនេះ គ្រូបង្រៀនពិតជាសំខាន់លើការបណ្តុះបណ្តាលធនធានមនុស្ស ពិសេសគ្រូបង្រៀនបានចូលរួមលើការកាត់បន្ថយចំណាយការសិក្សារបស់សិស្ស តាមរយៈការអនុវត្តការងារដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តិ ត្បិតថាការអនុវត្តនោះមិនទាន់មានភាពពេញលេញមួយរយភាគរយក៏ដោយ ប៉ុន្តែលទ្ធផលនេះស្ថិតក្នុងកម្រិតអាចទទួលយកបាន។ ដូច្នេះ ដើម្បីធានាបាននូវគុណភាពអប់រំ ប្រកបដោយសមធម៌និងបរិយាបន្នសម្រាប់ទាំងអស់គ្នា គ្រូបង្រៀនត្រូវប្រឹងប្រែងបន្ថែមទៀត ជាពិសេសប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន ប្រឹងប្រែងកែប្រែចំណុចអវិជ្ជមាន ចូលរួមអនុវត្តផែនការសាលារៀន កសាងទំនាក់ទំនងរវាងសិស្ស មាតាបិតា និងលើកទឹកចិត្តសិស្សក្រីក្រឱ្យបានច្រើនបំផុតតាមលទ្ធភាព។

សរុបជារួមមក ការចូលរួមរបស់សាលារៀនពិតជាសំខាន់មិនអាចខ្វះបានឡើយ។ ដូចនេះ សាលារៀនគួរតែរៀបចំនូវយន្តការតាមសាលារៀនដើម្បីជំរុញ គាំទ្រ និងលើកកម្ពស់គុណភាពសិក្សារបស់សិស្សានុសិស្ស ជាពិសេសសិស្សក្រីក្រខ្វះខាត។ យន្តការសាលារៀនសំខាន់ៗដែលអាចជួយដោះស្រាយប្រឈមខាងលើដោយផ្តោតលើការកាត់បន្ថយចំណាយទាំងនោះ រួមមាន៖

១-សាលារៀនមានដីធំទូលាយទុកទំនេរចោល ដូចនេះគួរប្រើប្រាស់ដីទំនេរនោះទាញជាប្រយោជន៍ ដោយការបង្កបង្កើនផលដំណាំណាមួយសម្រាប់លក់ទាញជាចំណូលសាលា។ សាលារៀនអាចជ្រើសយកពេលវេលាម៉ោងកសិកម្មឬម៉ោងទំនេររបស់សិស្ស ដោយបែងចែកតាមថ្នាក់ឬតាមវេនសម្រាប់អនុវត្តការងារនេះ។

២-សាលារៀនគួរផ្តល់ជំនាញដល់សិស្សឬបង្រៀនឱ្យសិស្សមានគំនិតច្នៃប្រឌិតបង្កើតថ្មី ដើម្បីពួកគេមានឱកាសបញ្ចេញស្នាដៃ និងអាចយកស្នាដៃទាំងនោះលក់បានជាកម្រៃ។

៣-សាលារៀនគួរបង្កើតកម្មវិធី ការតាំងពិពណ៌ស្នាដៃសិស្សឱ្យបានញឹកញាប់តាមលទ្ធភាព និងពេលវេលា។ កម្មវិធីទាំងនោះមានដូចជា រៀបចំបុណ្យបវេសនកាល រៀបចំបុណ្យក្នុងសាលារៀន រៀបចំពិព័រណ៍ស្នាដៃសិស្ស រៀបចំការសំដែងសិល្បៈ ការរៀបចំប្រកួតកីឡា ជាដើម។ ការរៀបចំកម្មវិធីនេះ នាយកសាលាត្រូវអញ្ជើញមាតាបិតា សហគមន៍ អាជ្ញាធរ ភាគីពាក់ព័ន្ធចូលរួម ដើម្បីទាក់ទាញចំណាប់អារម្មណ៍ អាចលក់ផលដំណាំ ហើយជួយដល់សិស្សអាចលក់ស្នាដៃរបស់ពួកគេផងដែរ។

៤-លើកផែនការ រៀបចំគម្រោងស្នើសុំថវិកាពីសប្បុរសជន អ្នកវិនិយោគ សហគ្រាស អាជីវករ អតីតសិស្សឱ្យមានការចូលរួម។

៥-កាត់បន្ថយការរែអង្គាសប្រាក់ ការផាកពិន័យជាប្រាក់ ការបង្ខិតបង្ខំដោយផ្ទាល់ឬប្រយោលក្នុងចេតនាឱ្យសិស្សមានការចំណាយ លុបបំបាត់ការបង់ថ្លៃសេវានានាដែលប៉ះពាល់ប្រយោជន៍អ្នកសិក្សា និងមិនគួរទទួលយកអំណោយពីសិស្ស

៦-កំណត់អត្តសញ្ញាណសិស្សឱ្យច្បាស់លាស់ ស្វែងរកឱ្យឃើញសិស្សដែលក្រីក្រពិតប្រាកដ ផ្តល់ប្រាក់អាហារូបករណ៍ចំគោលដៅ ហើយសិស្សក្រីក្រគួរលើកលែងរាល់ការចំណាយផ្សេងៗ។ សាលារៀនគួររៀបចំកាតពិសេសសម្គាល់ខ្លួនសម្រាប់សិស្សក្រីក្រ ដើម្បីឱ្យពួកគេអាចប្រើប្រាស់បង្ហាញនៅពេលធ្វើកង់ម៉ូតូ ថតចម្លងឯកសារ រៀនគួរក្រៅម៉ោងជាដើម។

៧-គ្រប់គ្រងតម្លៃនៃការលក់ចំណីអាហារឱ្យបានច្បាស់លាស់ និងមានការប្រជុំជាមួយអ្នកលក់ឱ្យបានញឹកញាប់ ដើម្បីផ្សព្វផ្សាយសេចក្តីណែនាំលេខ១៨ អយក.សណន

៨-រៀបចំផែនការបញ្ជ្រាបដល់មាតាបិតា អាណាព្យាបាលពីការរៀបចំអាហារពីផ្ទះ។ ការបង្កើតពេលវេលាប្រជុំជាសហគមន៍ប្រចាំខែ ការបង្កើតកម្មវិធីសំណេះសំណាលជាមួយមាតាបិតា ការផ្ញើលិខិតខ្លឹមសារតាមរយៈសិស្សានុសិស្ស ជាមធ្យោបាយមួយដែលអាចពញ្ញាក់ស្មារតីចំពោះសិស្ស និងអាណាព្យាបាលផងដែរ។

៩-បង្កើតយន្តការ ផ្សព្វផ្សាយ លើកទឹកចិត្តឱ្យសិស្សមានទម្លាប់ល្អ រៀបចំអាហារ ទឹកពីផ្ទះ។

១០-គ្រូបង្រៀនគួរប្រកាន់ខ្ជាប់ក្រមសីលធម៌វិជ្ជាជីវៈជាប្រចាំ។ ប្រសិនបើអនុវត្តអនុក្រឹត្យបានល្អគឺមានន័យថាគ្រូបង្រៀនក៏បានចូលរួមចំណែកយ៉ាងច្រើនលើបន្ទុកចំណាយរបស់សិស្សផងដែរ។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាននិងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី "ការសិក្សាពីមុខសញ្ញាចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ" មានគោលបំណងដើម្បីសិក្សាឈ្វេងយល់ពីមុខសញ្ញាចំណាយអំឡុងពេលសិក្សា និងបញ្ហាប្រឈមលើចំណាយការសិក្សា និងស្វែងរកលទ្ធភាពដែលសាលារៀនអាចចូលរួមដើម្បីកាត់បន្ថយចំណាយការសិក្សារបស់សិស្សានុសិស្ស ជាពិសេសសិស្សមានជីវភាពខ្វះខាតនៅកម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ។ ការសិក្សាស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្របែបបរិមាណវិស័យ និងគុណវិស័យ ដោយប្រើប្រាស់ភាគសំណាកសិស្ស ចំនួន ១៣៥ នាក់ មាតាបិតាសិស្ស ចំនួន ១៥ នាក់ គណៈគ្រប់គ្រងសាលារៀនចំនួន ៨នាក់ និងគ្រូបង្រៀនចំនួន១៥នាក់ នៃអនុវិទ្យាល័យចំនួនបីក្នុងខេត្តកំពង់ស្ពឺ។ ទិន្នន័យដែលប្រមូលបាន ត្រូវបានវិភាគដោយប្រើកម្មវិធី SPSS និង Microsoft Exel សម្រាប់សង់ក្រាប និងតារាង រួមទាំងការប្រមូលផ្តុំគំនិត ទស្សនៈការយល់ឃើញនានារបស់អ្នកផ្តល់បទសម្ភាសន៍ ដោយចាប់បញ្ចូលនូវចំណុចដែលដូចគ្នា ឬមានលក្ខណៈប្រហាក់ប្រហែលគ្នា ដើម្បីបន្ថែមព័ត៌មាន និងបង្ហាញគំនិតគាំទ្រចំពោះទិន្នន័យនៃការវិភាគតាមបែបបរិមាណវិស័យ។

លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ ត្រូវបានលើកមកបង្ហាញចំនួនបីចំណុចរួមមាន៖ ទី១- មុខសញ្ញាចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ ទី២- បញ្ហាប្រឈមលើចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ ទី៣- ការចូលរួមរបស់សាលារៀនលើការកាត់បន្ថយចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ។

១) មុខសញ្ញាចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ មានបួនសំខាន់ៗរួមមាន៖ ការចំណាយប្រចាំថ្ងៃ ការចំណាយថ្លៃសាលា ការចំណាយដើមឆ្នាំសិក្សា លើការចំណាយបន្ថែម។ ចំពោះការចំណាយដែលច្រើនជាងគេ គឺការចំណាយប្រចាំថ្ងៃដូចជា អាហារបរិភោគ/នំចំណី ការរៀនគួរក្រៅម៉ោង ចំណតកង់ ចំណតម៉ូតូ និងមធ្យោបាយធ្វើដំណើរ។ តាមការគណនាចំណាយ

សរុបរបស់សិស្សម្នាក់គិតជាមធ្យមសរុបចំនួន ២,១៩៩,៥៣៧ រៀល ស្មើនឹង ៥៣៦,៤៨ ដុល្លារអាមេរិក ក្នុងមួយឆ្នាំសិក្សា។ ក្នុងនោះ ការចំណាយប្រចាំថ្ងៃគិតជាមធ្យមសរុបចំនួន ១,៨៤៦,៩៣៣ រៀល ស្មើនឹង ៤៥០.៤៧ ដុល្លារ ស្មើនឹង៨៣.៩៧ ភាគរយ នៃការចំណាយសរុបក្នុងមួយឆ្នាំសិក្សា។

២) បញ្ហាប្រឈមលើការចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ គឺស្ថិតក្នុងកម្រិតមធ្យមដែលមានមធ្យមភាគ ស្មើនឹង ២.៦៨ គម្លាតស្តង់ដា ស្មើនឹង ០.០៦។ បញ្ហាប្រឈមដែលទទួលបានតម្លៃមធ្យមខ្ពស់ជាងគេ គឺបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចលើការចំណាយប្រចាំថ្ងៃ (ចំណីអាហារ គួរក្រៅម៉ោង និងមធ្យោបាយធ្វើដំណើរ)។ ការចំណាយខ្ពស់ទាំងនេះកើតឡើងដោយសារសិស្សមិនបានត្រៀមអាហារពីផ្ទះទើបត្រូវទិញអាហារពេលព្រឹក ឯសិស្សខ្លះបានបន្ថែមការចំណាយសម្រាប់អាហារថ្ងៃត្រង់ ភាពសម្បូរបែបនៃអាហារក្នុងសាលារៀនទាក់ទាញចិត្តសិស្សទិញ សាលារៀនឆ្ងាយទើបឪពុកម្តាយសម្រេចចិត្តឱ្យកូនជ្រើសរើសម៉ូតូជាមធ្យោបាយធ្វើដំណើររួមផ្សំការឡើងថ្លៃសាំងក្នុងបរិបទវិបត្តិពិភពលោក ការពេញនិយមការរៀនគួរ គ្រួសារដែលមានកូនសិក្សាច្រើន ចំណូលទាប ចំណាយខ្ពស់ ស្មើនឹង១០.៨០ភាគរយ នៃចំណូលសុទ្ធក្នុងមួយគ្រួសារគិតជាមធ្យមក្នុងមួយខែ និងស្មើនឹង១០.៧២ ភាគរយនៃចំណាយការប្រើប្រាស់ប្រចាំខែគិតជាមធ្យមក្នុងមួយគ្រួសារ ស្របពេលដែលត្រូវទទួលបន្ទុកចំណាយច្រើនផ្សេងទៀតដូចជា៖ម្ហូបអាហារ ការថែទាំសុខភាព តម្រូវចាំបាច់ផ្សេងៗ រួមជាមួយបំណុល។ បញ្ហានេះបានចោទខ្លាំងចំពោះគ្រួសារក្រីក្រ ដោយបានបង្ហាញពីក្តីព្រួយបារម្ភអំពីជោគវាសនាការសិក្សារបស់កូនៗ។ នៅពេលឪពុកម្តាយប្រឈមបញ្ហាសេដ្ឋកិច្ចមានចំណូលទាប ចំណាយច្រើន ជាប់បំណុល ធ្វើឱ្យជះឥទ្ធិពលដល់ការសម្រេចចិត្តរបស់មាតាបិតានិងប៉ះពាល់អារម្មណ៍របស់សិស្សផងដែរ។

៣) សម្រាប់ការចូលរួមរបស់សាលារៀន លើការកាត់បន្ថយចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ ពិតជាសំខាន់ដែលជាប់ទងនឹងផ្នែកសេដ្ឋកិច្ច ការសម្រេចចិត្ត និងលទ្ធផលរួមនៃការអប់រំ ពិសេសបានជួយសម្រួលបន្ទុកចំណាយគ្រួសារសិស្សដែលក្រីក្រជួបការលំបាក។ សកម្មភាពសំខាន់ៗនៃការចូលរួមរបស់សាលារៀនមានដូចជា កៀរគរមូលនិធិពីសប្បុរសជន កសាងទំនុកចិត្តសហគមន៍មកចូលរួមមូលនិធិសាលារៀន សម្រួលបន្ទុកចំណាយរបស់សិស្សតាមរយៈថវិកាសាលា

រៀនដែលទទួលបានពីរាជរដ្ឋាភិបាលឬចំណូលសាលារៀននិងផ្ទាល់ខ្លួន ផ្តល់សម្ភារៈដូចជាសម្លៀកបំពាក់ សៀវភៅសិក្សា ស្បែកជើង កង់ចំពោះសិស្សក្រីក្រ លុបបំបាត់ការចំណាយមិនចាំបាច់ក្នុងសាលារៀន កាត់បន្ថយការរំអែងគ្លាស ផ្តល់ជំនួយផ្នែកស្មារតីតាមរយៈការណែនាំសិស្សឱ្យចេះសន្សំសំចៃនិងការយកចិត្តទុកដាក់របស់សាលាផ្តល់អារម្មណ៍ល្អ និងជំនឿជាក់ដល់សិស្សមិនមានសម្ពាធ និងមករៀនទៀងទាត់។

ជារួម ការចំណាយលើការសិក្សារបស់សិស្សបច្ចុប្បន្ននេះគឺស្ថិតក្នុងកម្រិតមធ្យមដែលឪពុកម្តាយទូទៅអាចមានលទ្ធភាពរ៉ាប់រង និងប្រឹងប្រែងរកប្រាក់ចំណូលដើម្បីផ្តល់ឱកាសឱ្យកូនបានទៅសាលារៀន។ ទោះបីជាយ៉ាងណាក៏ដោយ កម្រិតនៃការចំណាយនេះគួរមានការអន្តរាគមន៍បន្ថែមដើម្បីសម្រួលដល់បន្ទុកចំណាយ ជាពិសេសផ្តោតដល់សិស្សក្រីក្រដែលកំពុងស្ថិតក្នុងស្ថានភាពប្រឈមបោះបង់ការសិក្សា។ ការសិក្សាស្រាវជ្រាវនេះ ក៏បានឆ្លុះបញ្ចាំងរវាងក្របខណ្ឌគតិយុត្តិ និងការអនុវត្តជាក់ស្តែងរបស់នាយកសាលា និងគ្រូបង្រៀនក្នុងការសម្រួលបន្ទុកចំណាយការសិក្សារបស់សិស្សគឺមានភាពបន្សុីគ្នាផងដែរ។ សាលារៀនព្យាយាមអនុវត្តការងារដោយអនុលោមតាមលិខិតបទដ្ឋាន គោលនយោបាយជាតិ គោលនយោបាយអប់រំ សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលសកម្មភាពទាំងនេះពិតជាសំខាន់បំផុតដើម្បីផ្តល់លទ្ធភាពដល់ក្រុមគ្រួសារនិងកុមារអាចទទួលបានសេវាអប់រំ បង្កើនបរិយាកាសសិក្សា និងជំរុញឱ្យលទ្ធផលសិក្សារបស់សិស្សកាន់តែមានប្រសិទ្ធភាព។ ទោះបីជាយ៉ាងនេះក្តី សាលារៀននៅមិនទាន់បានកំណត់ផែនការយុទ្ធសាស្ត្រនិងដាក់ចេញសកម្មភាព រៀបចំយន្តការក្នុងការចូលរួមចំណែកលើការចំណាយលើការសិក្សារបស់សិស្សនៅឡើយ។ ដូចនេះ សាលារៀននីមួយៗគួរចាប់ផ្តើមរៀបចំយន្តការឱ្យបានច្បាស់លាស់ដើម្បីឱ្យការងារទាំងនេះ សម្រេចបានប្រកបដោយប្រសិទ្ធភាពខ្ពស់បន្ថែមទៀត។

សរុបសេចក្តីមក ការអប់រំជាការវិនិយោគរយៈពេលវែងដែលត្រូវឆ្លងកាត់ឧបសគ្គជាច្រើនមុននឹងទទួលបានលទ្ធផល។ ការចំណាយជាកត្តាសំខាន់ក្នុងវិស័យអប់រំ គ្មានការអប់រំណាដែលគ្មានការចំណាយឡើយ ខុសគ្នានៅត្រង់ថាតិចឬច្រើន ដោយផ្ទាល់ឬប្រយោលប៉ុណ្ណោះ។ ការកំណត់ពីមុខសញ្ញាចំណាយជាចំណុចសំខាន់ត្រូវគិតគូរជាអាទិភាព សម្រាប់ឆ្លុះបញ្ចាំងឱ្យឃើញថាតើការចំណាយទាំងនោះមានការប្រឈមកម្រិតណាដើម្បីជាឱកាសស្វែងរកវិធីដោះស្រាយ។ ក្នុងស្ថានភាពណាបែបក៏ដោយ មានតែការ

សហការប៉ុណ្ណោះដែលជាមធ្យោបាយល្អបំផុត ពិសេសការចូលរួមរបស់សាលារៀនក្នុងការរៀបចំយន្តការដោះស្រាយបញ្ហាប្រឈមទៅជាឱកាសម្រាប់អនាគតកុមារ។ ក្រៅពីនេះ ត្រូវចូលរួមពីរដ្ឋាភិបាល ក្រសួងអប់រំ និងស្ថាប័នពាក់ព័ន្ធ សហគមន៍ ម្ចាស់ជំនួយ មាតាបិតាសិស្ស និងសិស្សានុសិស្សផ្ទាល់តែម្តង ពោលការចូលរួមនេះ មិនមែនជាបន្ទុក ឬការទទួលខុសត្រូវរបស់នរណាតែម្នាក់នោះទេ ប៉ុន្តែវាជាការទទួលខុសត្រូវរួមគ្នា ដើម្បីធានាគុណភាពអប់រំសម្រាប់កុមារគ្រប់រូបប្រកបដោយសមធម៌និងបរិយាបន្ន។

### ៥.២ សំណូមពរ

យោងតាមលទ្ធផលនៃការស្រាវជ្រាវនេះ បានរកឃើញពីមុខសញ្ញាចំណាយនិងបញ្ហាប្រឈមលើការចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ។ ដូច្នេះ ដើម្បីរួមចំណែកក្នុងដោះស្រាយបញ្ហាប្រឈមខាងលើនេះ អ្នកសិក្សាស្រាវជ្រាវសូមលើកយកនូវគំនិតយោបល់និងសំណូមពរដល់ភាគីពាក់ព័ន្ធដូចតទៅ៖

**ក. ក្រសួងអប់រំ យុវជន និងកីឡា**

- ពង្រីកនិងបន្តពង្រឹងលើកញ្ចប់ថវិកាសាលារៀនសម្រាប់គាំទ្រដល់ការសិក្សាសិស្សដូចជាផ្តល់ប្រាក់អាហារូបករណ៍ជូនដល់កុមារក្រីក្រជាអាទិភាពនិងចំគោលដៅ
- គួរតែរឹតបន្តឹងបន្ថែមលើសេចក្តីណែនាំលេខ១៨ អយក.សណន ស្តីពីការលើកកម្ពស់សុវត្ថិភាពចំណីអាហារនិងអាហារប្រកបដោយដោយសុខភាពតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនព្រមទាំងបន្ថែមលើការកំណត់ស្តង់ដាចំណីអាហារនិងតម្លៃបានច្បាស់លាស់

**ខ. សម្រាប់សាលារៀន**

- គួរគ្រប់គ្រងតម្លៃការលក់ដូរក្នុងសាលាឱ្យបានត្រឹមត្រូវ ប្រជុំជាមួយអ្នកលក់ដូរឱ្យបានញឹកញាប់
- បង្កើតយន្តការ ផ្សព្វផ្សាយ លើកទឹកចិត្តឱ្យសិស្សមានទម្លាប់ល្អ រៀបចំអាហារនិងទឹកពីផ្ទះ។
- បង្កើតប្រភពចំណូលសាលារៀន តាមរយៈការបង្កើតកម្មវិធីនានាក្នុងសាលារៀន ការតាំងពិព័រណ៍ ការប្រើប្រាស់ដីទំនេរធ្វើដំណាំសម្រាប់លក់ ឬទាញប្រយោជន៍ឱ្យបានពីដីទំនេរនោះ
- រៀបចំយន្តការបញ្ជ្រាបដល់មាតាបិតា អាណាព្យាបាលពីការរៀបចំអាហារពីផ្ទះសម្រាប់កូនៗ

- កាត់បន្ថយការអែអង្គាសប្រាក់ឬបង្កើតឱ្យមានចំណាយដែលមិនសំខាន់ធ្វើឱ្យប៉ះពាល់ដល់សិស្ស
- កំណត់អត្តសញ្ញាណសិស្សឱ្យបានច្បាស់លាស់ សិស្សក្រីក្រគួរលើកលែងរាល់ការចំណាយក្នុងសាលាដូចជាចំណាតកង់ ថតចម្លងឯកសារ ការប្រឡង ការរៀនគួរ ជាដើម។

**គ. មាតាបិតា អាណាព្យាបាល និងសហគមន៍**

- គួរបង្កើតមុខរបរ បន្ថែមការងារ បង្កើនចំណូល ដើម្បីឱ្យមានតុល្យភាពរវាងចំណូលនិងចំណាយ
- លើកទឹកចិត្តកូនជិះកង់ជំនួសម៉ូតូ និងទម្លាប់ឱ្យកូនចេះរៀបចំអាហារពីផ្ទះ
- មាតាបិតា និងសហគមន៍ ជាពិសេសគ្រួសារមានស្ថានភាពសេដ្ឋកិច្ចប្រសើរ គួរតែចូលរួមគាំទ្រជ្រោមជ្រែងសាលារៀនទាំងគំនិត ស្មារតី សម្ភារៈ និងថវិកា ដើម្បីជំរុញដល់ដំណើរការសាលារៀន
- គួរតែព្យាយាមបង្ហាញឱ្យកូនៗបានយល់ច្បាស់រវាងចំណាយអាទិភាព និងបន្ទាប់បន្សំ

**ឃ. សម្រាប់សិស្សានុសិស្ស**

- ព្យាយាមប្រើប្រាស់ថវិកាឱ្យបានចំគោលដៅ និងសន្សំសំចៃ កាត់បន្ថយចំណាយដែលមិនចាំបាច់
- ផ្លាស់ប្តូរទម្លាប់មិនល្អទាំងឡាយដែលធ្វើឱ្យឪពុកម្តាយមានបន្ទុកចំណាយកាន់តែធ្ងន់ ដូចជាការជ្រើសរើសកង់ជាមធ្យោបាយ ការទម្លាប់រៀបចំអាហារពីផ្ទះ
- លុបបំបាត់ភាពខ្មាសអៀន ហ៊ានប្រឈមភាពលំបាក បណ្តុះសេចក្តីក្លាហាន ហ៊ានលើកសំណើជូនគណៈគ្រប់គ្រង លោកគ្រូអ្នកគ្រូគ្រប់បញ្ហាប្រឈមទាំងឡាយដែលកើតមានក្នុងសាលារៀន

**ង. សម្រាប់អ្នកសិក្សាស្រាវជ្រាវបន្ត**

ការសិក្សាស្រាវជ្រាវនេះ ស្តីពីមុខសញ្ញាចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ ដែលផ្តោតលើគោលបំណងបីគឺ មុខសញ្ញាចំណាយការសិក្សា បញ្ហាប្រឈមលើការចំណាយ និងការចូលរួមរបស់សាលារៀន។ អ្នកសិក្សាស្រាវជ្រាវបន្ត គួរសិក្សាស្រាវជ្រាវទាក់ទងទៅនឹង៖

- សិក្សាពីមុខសញ្ញាចំណាយលើការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ
- ពង្រីកវិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវក្នុងតំបន់ផ្សេងៗទៀតនៃព្រះរាជាណាចក្រកម្ពុជា
- សិក្សាលើមុខសញ្ញាចំណាយ និងបញ្ហាប្រឈមរបស់សិស្សនៃសាលារៀនឯកជន

# ឯកសារយោង

ក្រសួងផែនការ, វ. (២០២០). *របាយការណ៍ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០.* ភ្នំពេញ: ក្រសួងផែនការ, វិទ្យាស្ថានជាតិស្ថិតិ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ.(២០២១). *របាយការណ៍ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលប្រចាំខែមីនាឆ្នាំ២០២១.* ភ្នំពេញ: ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងអប់រំយុវជននិងកីឡា. (២០០៩). *ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍.* ភ្នំពេញ: ក្រសួងអប់រំយុវជននិងកីឡា។

ក្រសួងអប់រំយុវជននិងកីឡា. (២០០៩). *ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍សម្រាប់ការបំប៉ននាយកសាលារៀនបឋមសិក្សានិងមធ្យមសិក្សា.* ភ្នំពេញ: ក្រសួងអប់រំយុវជននិងកីឡា។

ក្រសួងអប់រំយុវជននិងកីឡា. (២០១៨). *យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំយុវជននិងកីឡា២០១៨-២០២៣.* ភ្នំពេញ: ក្រសួងអប់រំយុវជននិងកីឡា។

ក្រសួងអប់រំយុវជននិងកីឡា. (២០១៨). *សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន.* ភ្នំពេញ: ក្រសួងអប់រំយុវជននិងកីឡា។

រាជរដ្ឋាភិបាលកម្ពុជា. (២០១៨). *គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០.* ភ្នំពេញ: រាជរដ្ឋាភិបាលកម្ពុជា.

ក្រសួងអប់រំយុវជននិងកីឡា. (២០១៩). *ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤.* ភ្នំពេញ: ក្រសួងអប់រំយុវជននិងកីឡា។

ក្រសួងអប់រំយុវជននិងកីឡា. (២០២១). *ផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាឆ្នាំ២០៣០.* ភ្នំពេញ: ក្រសួងអប់រំយុវជននិងកីឡា។

ក្រសួងអប់រំយុវជននិងកីឡា. (២០២២). *ស្ថិតិនិងសូចនាករអប់រំសាធារណៈ:២០២១-២០២២.* ភ្នំពេញ: ក្រសួងអប់រំយុវជននិងកីឡា។

ក្រុមប្រឹក្សាធម្មនុញ្ញ. (២០១៥). *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា.* ភ្នំពេញ: អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ។

នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ.(២០០៩). *ទំនាក់ទំនងរវាងសាលារៀននិងសហគមន៍.* ភ្នំពេញ: ក្រសួងអប់រំយុវជននិងកីឡា។

រាជរដ្ឋាភិបាល.(២០០៨). *អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន.*ភ្នំពេញ: រាជរដ្ឋាភិបាលកម្ពុជា.

ហង់ជួនណារ៉ុន. (២០១៦). *កំណែទម្រង់វិស័យអប់រំនៅកម្ពុជា.* ភ្នំពេញ: ក្រសួងអប់រំយុវជននិងកីឡា។

អគ្គនាយកដ្ឋានថវិកា. (២០២២). *ថវិកាសង្ខេបឆ្នាំ២០២២.* ភ្នំពេញ: ក្រសួងសេដ្ឋកិច្ច។

អគ្គនាយកដ្ឋានពន្ធដារ.(២០២២).*អត្រាប្តូរប្រាក់ផ្លូវការ.លេខ១៥៧៣០អពដ.*ភ្នំពេញ:ក្រសួងសេដ្ឋកិច្ច។

អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា(ខេប). (២០២២). *របាយការណ៍ការប្រចាំឆ្នាំ២០២១.* ភ្នំពេញ: អង្គការខេប។

ព្រះរាជាណាចក្រកម្ពុជា(២០០៧) *ច្បាប់ស្តីពីការអប់រំ.*ទាញចេញពីគេហទំព័រ http://www.moeys.gov.kh/images/moeys/laws-and-regulations/48/EducationLaw.pdf

AccountingTools. (2022). *https://www.accountingtools.com/.* Retrieved from https://www.accountingtools.com/: https://www.accountingtools.com/articles/expenditure.

Al-Samarrai, S. (2020). *The Impace of the Covid-19 Pandemic on Education Financing.* World Bank Group.

Bray, M. (1999). *The private costs of public schooling: Household and community financing of primary education in Cambodia.* International Institute for Educational Planning.

Bray, M. (1999). The Private Costs of Public Schooling: Household and Community Financing of Primary Education in Cambodia. *International Institute for Education Planning/UNESCO*, 48-60.

Bray, Mark (1999b): *The Shadow Education System: Private Tutoring and its Implications for Planners. Fundamentals of Educational Planning 61,* Paris: UNESCO International Institute for Educational Planning.

Bray, Mark (2003a): *Adverse Effects of Private Supplementary Tutoring: Dimensions, Implications and Government Responses.* Paris: UN ESCO International Institute for Educational Planning.

Bray, Mark (2004): *The Costs and Financing of Education: Trends and Policy Implications. Series: ' Education in Developing Asia ‘. Hong Kong: Comparative Education Research Centre, The University of Hong Kong, and Manila:* Asian Development Bank.

Bray, M., & Silova, I. (2006). *The private tutoring phenomenon: International patterns and perspectives.* Education in a hidden marketplace: Monitoring of private tutoring, 27-40.

Colclough, C., Al - Samarrai, S., Rose, P. & Tembon, M. (2003): *Achieving Schooling for All in Africa: Costs, Commitment and Gender. Alder shot,* UK: Ashgate.

Chhaing, S. (2021). Causes of students' dropout at lower secondary level in Rural Cambodia: Parental Insights. *Scienceweb Publishing*, 13-20.

Epstein, J. L. (2022). *https://www.sps186.org/downloads/table/13040/6typesj.epstien.pdf.* Retrieved from file:///C:/Users/ASUS/Downloads/Documents/6TypesJ.Epstien_2.pdf

Foondun, A. Raffick (2002): *" The Issue of Private Tuition: An Analysis of the Practice in Mauritius and Selected South - East Asian Countries '.* International Review of Education, Vol.48, No.6, pp.485-515.

Hom, S. (2008). *Difficulties Faced by Female Students and Opportunity for Their Lower Secondary Education.* Phom Penh: Royal University of Phnom Penh.

IES. (2020). *Revenues and Expenditures for Public Elementary and Secondary Education:FY 18.* U.S: National Center for Education Statistics at IES.

James, Estelle, King, Elizabeth M. & Suryadi, Ace (1996): ' *Finance, Management, and Costs of Public and Private Schools in Indonesia ‘. Economics of Education Review, Vol. 15, No.4, pp.387-398.*

Jimenez, Emmanuel & Paqueo, Vicente (1996): ' *Do Local Contributions Affect the Efficiency of Public Primary Schools? ' . Economics of Education Review, Vol. 15, No.4, pp.379-380.*

King, E. (1997). *Who Really Pays for Education? The roles of government and families in Indonesia.* Marketizing education and health in developing countries: Miracle or mirage, 165-182.

Kwok, Percy (2004): *' Examination - Oriented Knowledge and Value Trans formation in East Asian Cram Schools ‘.* Asia Pacific Education Re view, Vol.5, No.1, pp.64-75.

Lepisto, E., and E. Kazimzade. (2008). *Coercion or compulsion? Rationales behind informal payments for education in Azerbaijan.* European Education: Issues and Studies 40, no. 4: 70–92.

Lin, T., & Lv, H. (2017). *The effects of family income on children's education: An empirical analysis of CHNS data.* Research on Modern Higher Education, 4, 49-54.

Lvailo, L., Huot, C., Sodeth, L., Paavo, E., Timothy, J., Emre, O., Suhas, P., Leah, A. (២០១១). *ប្រទេសកម្ពុជាបង្កើនប្រសិទ្ធភាពចំណាយរបស់រដ្ឋាភិបាលដើម្បីកំណើនខ្ពស់ និងមានមូលដ្ឋានទូលាយជាងមុន ការវាយតម្លៃចំរុះលើទំនុកចិត្តនិងការពិនិត្យសើរើឡើងវិញលើចំណាយសាធារណៈ (IFAPER).* ភ្នំពេញ: ធនាគារពិភពលោក.

Manzon, Maria (2004): *Building Alliances: Schools, Parents and Communities in Hong Kong and Singapore.* Hong Kong: Comparative Education Research Centre, The University of Hong Kong.

Mark Bray and Seng Bunly. (2005). *Household Financing of Basic Education in Cambodia.* WorldBank.

Micklewright, J. (2000). *Education, inequality, and transition. Innocenti Working Papers, Economic and Social Policy Series no. 74, UNICEF Innocenti Research Center, Florence.*

Miller-Grandvaux, Yolande &Yoder, Karla (2002): *A Literature Review of Community School in Africa.* Washington DC: USAID Bureau for Africa, Office of Sustainable Development.

Menon, A. (2013). Barriers to Parental Involvement in Early Childhood Education Classrooms in Mumbai Slums as Perceived by Parents . *Literacy Information and Computer Education Journal (LICEJ)*, 1314-1318.

Mehrotra, Santosh & Delamonica, Enrique (1998). ' *Household Costs and Public Expenditure on Primary Education in Five Low - income Countries: A Comparative Analysis* ‘. International Journal of Educational Development, Vol. 18, No.1, pp.41-61.

NGO Education Partnership, N. (2007) (2015). *THE IMPACT OF INFORMAL SCHOOL FEES ON FAMILY EXPENDITURE.* Phnom Penh: Asian South Pacific Bureau for Adult Education (ASPBAE).

Özkanca, Katia & Tim Carter, Goldstein, T. Kuru. (2022, May 30). *https://dictionary.cambridge.org/.* Retrieved from https://dictionary.cambridge.org/: https://dictionary.cambridge.org/dictionary/english/expenditure

Samarrai, S. A. (២០២០). *ផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ-១៩ស្តីពីការផ្តល់ហិរញ្ញប្បទានការអប់រំ.* ភ្នំពេញ: ធនាគារពិភពលោក.

Selda and Ozturk. (2021). Household education expenditures in Turkey for higher education exam preparation. *ACADEMIC JOURNALS*, 256-264.

Silova, I., V. Budiene, and M. Bray, eds. (2006). *Education in a hidden marketplace: Monitoring of private tutoring.* New York: Open Society Institute.

Silova, I. (2010). Private tutoring in Eastern Europe and Central Asia: policy choices and implications . *Compare: A Journal of Comparative and International Education* , 327-344.

Sylvie and Isabelle. (2022, 07 01). *https://www.erudit.org/en/journals/rse/1900-v1-n1-rse1834/032032ar/.* Retrieved from https://id.erudit.org/iderudit/032032ar

Truong, T.K.C., Thai, T.N.D. & Bach, H.V. (1999): ' *Educational Enrolments in Lower Secondary School ',* in Houghton, D., Haughton, J., Bales, S., Truong, T.K.C. & Nguyen, N.N. (eds.), Health and Wealth in Vietnam: An Analysis of Household Living Standards. Singapore: Institute of Southeast Asian Studies, pp.121-138.

UNDP, C. (2014). *ការទប់ស្កាត់ការបង្រៀនឯកជន និងថ្លៃក្រៅផ្លូវការក្នុងការអប់រំមូលដ្ឋានរបស់កម្ពុជា.* Phnom Penh: UNDP Cambodia.

UNESCO Institute for Statistics. (2009). *Global education digest*. Quebec: UNESCO Institute for Statistics.

Unicef. (2018). *Child Protection and Education, Needs for the Children and Adolescents of Phnom Penh's Urban Poor Communities.* Phnom Penh: Unicef. Retrieved from http://www.unicef.org.kh/.

Urwick, James (2002): ' *Determinants of the Private Costs of Primary and Early Childhood Education: Findings from Plateau State, Nigeria '. International Journal of Educational Development, Vol.22, No.2, pp.131 144.*

Wannatawee, K., Worakham, P., & Panya, P. (2017). *Development of and Assessment Model on Parallel Educational Management in the Academy Schools under office of the Basic Education Commission.* Europe Journal of Education Studies, 3 (9), 305-316.

WCEFA [ World Conference on Education for All] (1990a): *World Conference on Education for All: Final Report.* New York: Inter - Agency Commission, WCEFA.

WorldBank. (2005). *Cambodia: Quality basic education for all.* TheWorld Bank.

Yolcu. (2011). The Factors Which Affect Education Expenditure of Household:A Theoretical Study. *Mehmet AkifErsoy University Journal of Social Sciences Institute,* 12-35.

Yoo, Yoon Ha (2002): *Economics of Private Tutoring: In Search for its causes and Effective Cures.* Seoul: Korea Development Institute.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ (ក)៖ កម្រងសំណួរសម្រាប់សិស្សានុសិស្ស

### កម្រងសំណួរក្នុងការប្រមូលទិន្នន័យ សម្រាប់សិស្សអនុវិទ្យាល័យឆាយឆុប អនុវិទ្យាល័យត្រពាំងឈូក និងវិទ្យាល័យសម្តេចជាស៊ីមឱរ៉ាល់

ខ្ញុំបាទឈ្មោះ **ខ៊ាន់ សំរេច** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ នៅវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទស្តីពី "ការសិក្សាពីមុខសញ្ញាចំណាយលើការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិខេត្តកំពង់ស្ពឺ" ដើម្បីបញ្ចប់ការសិក្សា។

គោលបំណងនៃការប្រមូលទិន្នន័យនេះ គឺដើម្បីសិក្សាឈ្វេងយល់ពីមុខសញ្ញាចំណាយអំឡុងពេលសិក្សា និងបញ្ហាប្រឈមលើចំណាយការសិក្សា និងស្វែងរកលទ្ធភាពដែលសាលារៀនអាចចូលរួមដើម្បីកាត់បន្ថយចំណាយការសិក្សារបស់សិស្សានុសិស្ស ជាពិសេសសិស្សមានជីវភាពខ្វះខាតនៅកម្រិតមធ្យមសិក្សាបឋមភូមិ ខេត្តកំពង់ស្ពឺ។ ទិន្នន័យប្រមូលបានពីសិស្ស មានគោលបំណងយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ ដើម្បីបានព័ត៌មានជាក់លាក់យកមកវិភាគ ឆ្លើយតបទៅនឹងប្រធានបទខាងលើ។

ទិន្នន័យដែលប្រមូលបាននេះ គឺប្រើសម្រាប់តែសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ ក្នុងន័យនេះ សូមប្អូនៗមេត្តាជួយផ្តល់ព័ត៌មានពិតជាក់ស្តែង ដើម្បីឱ្យខ្ញុំបាទអាចមានទិន្នន័យ និងហេតុផលគ្រប់គ្រាន់តាមបែបវិទ្យាសាស្រ្ត សម្រាប់ទាញអំណះអំណាងយកមកសិក្សាបកស្រាយទៅលើការសរសេរនិក្ខេបបទក្នុងការសិក្សាស្រាវជ្រាវនេះ។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមរបស់ប្អូនៗសិស្សានុសិស្ស។

**ផ្នែកទី១៖ ព័ត៌មានប្រជាសាស្រ្ត**

**ការណែនាំ៖** សូមប្អូនៗ គូសសញ្ញា(✓) ក្នុងប្រអប់នីមួយៗ ទៅតាមស្ថានភាពជាក់ស្តែងដូចខាងក្រោម៖

១. ភេទ៖ ☐ ស្រី ☐ ប្រុស

២. អាយុ៖ ..........................ឆ្នាំ

៣. ថ្នាក់ទី៖ ☐ ថ្នាក់ទី៧ ☐ ថ្នាក់ទី៨ ☐ ថ្នាក់ទី៩

៤. រៀននៅ៖ ☐ អនុវិទ្យាល័យឆាយឆុប

☐ អនុវិទ្យាល័យត្រពាំងឈូក

☐ វិទ្យាល័យសម្តេចជាស៊ីមឱរ៉ាល់

**ផ្នែកទី២៖ ការឆ្លើយតបរបស់សិស្សទៅលើមុខសញ្ញាចំណាយការសិក្សា**

**ការណែនាំ៖** សំណួរខាងក្រោមនេះ គឺឆ្លុះបញ្ចាំងពីការចំណាយជាក់ស្តែងក្នុងអំឡុងពេលសិក្សារបស់សិស្សានុសិស្សកម្រិតមធ្យមសិក្សាបឋមភូមិ ខេត្តកំពង់ស្ពឺ។ សូមប្អូនៗ អានចំណុចនីមួយៗឱ្យបានច្បាស់លាស់ បន្ទាប់មកឆ្លើយតាមភាពជាក់ស្តែងដូចខាងក្រោម៖

១. តើប្អូនប្រើប្រាស់មធ្យោបាយអ្វីដើម្បីមកសាលារៀន?

☐ ថ្មើរជើង ☐ កង់ ☐ ម៉ូតូ

☐ រថយន្តឈ្នួល ☐ សុំអ្នករួមដំណើរផ្លូវជិះជាមួយ ☐ គ្រួសារជូនទៅមក

២. តើប្អូនៗបានចំណាយលើការសិក្សាជាប្រចាំប៉ុន្មានរៀលក្នុងមួយថ្ងៃ? ..........................រៀល

៣. តើប្អូនៗបានចំណាយលើការសិក្សាជាប្រចាំប៉ុន្មានរៀលក្នុងមួយសប្តាហ៍? ....................រៀល

៤. តើប្អូនៗបានចំណាយលើការសិក្សាជាប្រចាំប៉ុន្មានរៀលក្នុងមួយខែ? ..........................រៀល

៥. តើប្អូនៗរៀនគួរក្រៅម៉ោងរដ្ឋប៉ុន្មានមុខវិជ្ជាក្នុងមួយថ្ងៃ?............................................មុខវិជ្ជា

៦. តើប្អូនរៀនគួរក្រៅម៉ោងរដ្ឋប៉ុន្មានថ្ងៃក្នុងមួយសប្តាហ៍?...............................................ថ្ងៃ

៧. តើប្អូនបានចំណាយប្រាក់រៀនគួរក្រៅម៉ោងរដ្ឋប៉ុន្មានរៀលក្នុងមួយមុខវិជ្ជា?.....................រៀល

៨. តើប្អូនៗបានចំណាយលើការសិក្សាអ្វីខ្លះ? *ដើម្បីឆ្លើយសំណួរនេះ សូមអានការណែនាំខាងក្រោម៖*

**ការណែនាំ៖** សូមប្អូនៗអានចំណុចនីមួយៗខាងក្រោមឱ្យបានច្បាស់លាស់ បន្ទាប់មកសូមបំពេញចំនួនទឹកប្រាក់តាមមុខសញ្ញាចំណាយលើការសិក្សារបស់ប្អូនៗតាមភាពជាក់ស្តែង។

| ល.រ | មុខសញ្ញាចំណាយលើការសិក្សា | ចំនួនទឹកប្រាក់ (គិតជារៀល) |
|---|---|---|
| **ក. ការចំណាយប្រចាំថ្ងៃ** | | |
| ១ | អាហារបរិភោគ/នំចំណី | .......................................... |

| | | |
|---|---|---|
| ២ | គួរក្រៅម៉ោង | ........................................... |
| ៣ | ចំណតកង់ | ........................................... |
| ៤ | ចំណតម៉ូតូ | ........................................... |
| ៥ | មធ្យោបាយធ្វើដំណើរ/កន្លែងស្នាក់នៅ | ........................................... |
| **ខ. ការចំណាយថ្លៃសាលារៀន** | | |
| ១ | ចំណាយលើគ្រូបង្រៀន | ........................................... |
| ២ | ឯកសារបង្រៀន/ ទិញមេរៀនគ្រូ | ........................................... |
| ៣ | ក្រដាសប្រឡង/ ឯកសារប្រឡង | ........................................... |
| ៤ | សៀវភៅតាមដាន | ........................................... |
| ៥ | បង់ថ្លៃជាប់មធ្យមភាគ | ........................................... |
| ៦ | ការរៃអង្គាសមូលនិធិ | ........................................... |
| ៧ | អគ្គិសនី | ........................................... |
| ៨ | ផាកពិន័យអវត្តមានជាទឹកប្រាក់ | ........................................... |
| ៩ | ផាកពិន័យមករៀនយឺតជាទឹកប្រាក់ | ........................................... |
| **គ. ការចំណាយដើមឆ្នាំសិក្សា** | | |
| **ចំណាយលើឯកសណ្ឋានសាលា** | | |
| ១ | ឯកសណ្ឋានប្រចាំថ្ងៃ | ........................................... |
| ២ | ឯកសណ្ឋានកីឡា | ........................................... |
| ៣ | ស្បែកជើងប៉ាត់តាទៅសាលា | ........................................... |
| ៤ | ស្បែកជើងកីឡា | ........................................... |
| ៥ | កាតសិស្ស | ........................................... |
| **ចំណាយលើសម្ភារៈសិក្សា** | | |
| ១ | កាបូបស្ពាយ | ........................................... |
| ២ | សៀវភៅសរសេរ | ........................................... |
| ៣ | សៀវភៅអាន | ........................................... |
| ៤ | សៀវភៅលំហាត់ | ........................................... |
| ៥ | ប៊ិក ខ្មៅដៃ បន្ទាត់ | ........................................... |
| ៦ | គម្របសៀវភៅ/អ៊ុតសៀវភៅ | ........................................... |

| | | |
|---|---|---|
| | **ចំណាយលើការចុះឈ្មោះចូលរៀន** | |
| ១ | ពាក្យសុំចូលរៀន | ........................................... |
| ២ | សេវាបំពេញទម្រង់ពាក្យ | ........................................... |
| ៣ | រូបថត | ........................................... |
| ៤ | បង់កីឡាប្រចាំឆ្នាំ | ........................................... |
| **ឃ. ការចំណាយបន្ថែម** | | |
| ១ | ការផ្គត់ផ្គង់សម្ភារៈសិក្សា | ........................................... |
| ២ | ការផ្គត់ផ្គង់ថ្នាក់រៀន | ........................................... |
| ៣ | ការជួសជុលកង់/ម៉ូតូ | ........................................... |
| ៤ | ការជូនអំណោយគ្រូ | ........................................... |
| ៥ | ការរៀបចំកម្មវិធី | ........................................... |

**ផ្នែកទី៣៖ បញ្ហាប្រឈមលើចំណាយការសិក្សារបស់សិស្ស**

**ការណែនាំ៖** សំណួរខាងក្រោមនេះ គឺឆ្លុះបញ្ចាំងពីបញ្ហាប្រឈមលើចំណាយការសិក្សាដែលសិស្សជួបប្រទះក្នុងអំឡុងពេលសិក្សា។ សូមប្អូនៗ អានចំណុចនីមួយៗឱ្យបានច្បាស់លាស់ បន្ទាប់មកសូមគូសសញ្ញា(√) ចំពោះមុខសញ្ញាចំណាយលើការសិក្សាដែលបានផ្តល់ផលជះដល់ការសិក្សារបស់ប្អូនៗ ទៅតាមកម្រិតជាក់ស្តែង។

***កម្រិតចង្អុលបង្ហាញ៖***

***១= តិចបំផុត***

***២= តិច***

***៣= មធ្យម***

***៤= ខ្លាំង***

***៥= ខ្លាំងបំផុត***

| ល.រ | បញ្ហាប្រឈមលើចំណាយការសិក្សារបស់សិស្ស | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| **សតិអារម្មណ៍និងភាពជឿជាក់** | | | | | | |
| ១ | ខ្ញុំខ្មាសអៀន/មិនហ៊ានជួបមុខគ្រូ ព្រោះមិនបានរៀនគួរក្រៅម៉ោងជាមួយគាត់ | | | | | |
| ២ | ខ្ញុំអវត្តមានច្រើន ព្រោះមិនហ៊ានចូលរៀនមុខវិជ្ជាដែលមិនបានរៀនគួរ | | | | | |
| ៣ | ខ្ញុំមករៀនយឺត ព្រោះសាលាឆ្ងាយពីផ្ទះ | | | | | |
| ៤ | ខ្ញុំមានបងប្អូនរៀនច្រើន ចំណាយច្រើន | | | | | |
| ៥ | ខ្ញុំអវត្តមានពេលប្រឡង ព្រោះមិនមានប្រាក់បង់ថ្លៃក្រដាស | | | | | |
| ៦ | ខ្ញុំមានអារម្មណ៍តានតឹងនៅពេលដែលសាលាផាកពិន័យសិស្សជាទឹកប្រាក់ | | | | | |
| ៧ | គ្រូតែងហៅសិស្សដែលមិនបានរៀនគួរជាមួយគាត់ឡើងឈរមុខក្ដារខៀន | | | | | |
| ៨ | គ្រូបង្រៀនមិនអស់ចំណុច/ខ្លឹមសារ ពន្យល់មិនបានក្បោះក្បាយក្នុងម៉ោងរដ្ឋ | | | | | |
| ៩ | គ្រូលម្អៀងរវាងសិស្សរៀនគួរ និងសិស្សមិនបានរៀនគួរជាមួយគាត់ | | | | | |
| **សេដ្ឋកិច្ច** | | | | | | |
| **ក. ការចំណាយប្រចាំថ្ងៃ** | | | | | | |
| ១ | អាហារបរិភោគ/នំចំណី | | | | | |
| ២ | គួរក្រៅម៉ោង | | | | | |
| ៣ | ចំណតកង់ | | | | | |
| ៤ | ចំណតម៉ូតូ | | | | | |
| ៥ | មធ្យោបាយធ្វើដំណើរ/កន្លែងស្នាក់នៅ | | | | | |
| **ខ. ការចំណាយថ្លៃសាលារៀន** | | | | | | |
| ១ | ចំណាយលើគ្រូបង្រៀន | | | | | |
| ២ | ឯកសារបង្រៀន/ទិញមេរៀនគ្រូ | | | | | |
| ៣ | ក្រដាសប្រឡង/ឯកសារប្រឡង | | | | | |
| ៤ | សៀវភៅតាមដាន | | | | | |
| ៥ | បង់ថ្លៃជាប់មធ្យមភាគ | | | | | |
